ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- ៧ មករា
- សូមគោរពជូនមិត្តភក្តិទាំងអស់គ្នាជាទីមេត្រី

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ៣០១ ខែមករា ឆ្នាំ២០២៥

# ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា


### សំបុត្រ

◆ ៧ មករា ........................................ ១

◆ សូមគោរពជូនមិត្តភក្តិទាំងអស់គ្នាជាទីមេត្រី.... ៤

### ផ្នែកឯកសារ

◆ ករណី កែវ សំណាង អនុប្រធានគណៈយោធភូមិភាគបូព៌ា តាមចម្លើយរបស់ សុជាន............. ៦

◆ លួន ឡុំ ហៅ វ៉ាន៖ សមាជិកអនុសេនាធំ..... ១០

### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ

◆ មូលហេតុអ្វីបានរបបខ្មែរក្រហមដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩?................ ១៤

◆ ការស្លាប់របស់ ប៉ុល ពត និងការបែកបាក់.... ១៨

◆ មជ្ឈមណ្ឌលឯកសារកម្ពុជាដំឡើងស្លាក ..... ២៣

◆ សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ព្រះរាជទាន........ ២៥

◆ យុវតីមកពីសហគមន៍ចាម នៅភូមិចុងខ្នុង ... ២៨

◆ ឃិន សាវ៉ន៖ កម្មករនៅការដ្ឋានក្រសួង...... ៣០

◆ ជឿលើសន្យារបស់អង្គការ.................... ៣៣

◆ ញ៉ាញ់ មៀវ៖ បណ្តាំម្តាយ .................... ៣៧

◆ សា អែស៊ះ៖ បើមានសំឡេងក្មេងយំ នឹង..... ៤០

◆ តួនាទីនីរសារ ក្នុងរបបខ្មែរក្រហម............ ៤៣

◆ សេង អួន ពេទ្យកងទ័ពតំបន់២២ ........... ៤៦

◆ ឡេង ឈៀង៖ អតីតយោធាខ្មែរក្រហម..... ៤៨

### ផ្នែកវេទិកាពិភាក្សាសាធារណៈ

◆ គ្រូបង្រៀន និងសិស្សានុសិស្សចំនួន៧៥នាក់ មកពីសាលាពន្លឺវិជ្ជាអន្តរជាតិ.................. ៥១

◆ មជ្ឈមណ្ឌលផ្សះផ្សាវាលវែងរៀបចំវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដល់សិស្សមកពីវិទ្យាល័យប្រម៉ោយ............. ៥៤




លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា នៅឃុំបានកាម ស្រុកព្រៃកប្បាស ខេត្តតាកែវ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)


◆ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងរៀបចំវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដល់សិស្សមកពីអនុវិទ្យាល័យថ្នាត .......... ៥៨

### ផ្នែកស្រាវជ្រាវរកគ្រួសារ

◆ បងៗរបស់ខ្ញុំ៣នាក់ អង្គការស្នើយកទៅរៀនសូត្រ ចំនួន៣ថ្ងៃ តែបាត់ខ្លួនរហូតដល់បច្ចុប្បន្ន...... ៦២


**រក្សាសិទ្ធិ**
មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឱ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៣៧៥ព.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្មេរលេខនេះ៖** ឆាំង យុ, ដេង ពង្សរ៉ាស៊ី, ឡុង ដានី, សូ ហ្វារីណា, អេង សុខម៉េង, សុភ័ក្ត្រ ភាណា, វី ស៊ីថា, ស៊ាង ចិន្តា, ចាន់ ណារិទ្ធ, ឈុំ វ៉ា, លី សុខឃាង និង សាំង ចាន់ធូ
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** មីន សាណាស់ **អ្នកបកប្រែ៖** លីម អ៊ិកឹង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន
**ជំនួយការនិពន្ធនាយក៖** ដារ៉ារដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ផេង ពៅ

Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiasri.org

# ៧ មករា

ឆាំង យុ



រថយន្តដឹកអ្នកដំណើរពីភ្នំពេញទៅតាមបណ្តាខេត្តផ្សេងៗ នៅអំឡុងទសវត្សរ៍ឆ្នាំ១៩៨០។ (ដេវីត ហក/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខណៈ ប្រជាជនកម្ពុជា ប្រារព្ធការរំឭកអំពីថ្ងៃ ៧ មករា ទិវាជ័យជម្នះលើរបបប្រល័យពូជសាសន៍ខ្មែរក្រហម យើងចាំបាច់ត្រូវឆ្លុះបញ្ចាំងអំពីសំណួរមួយចំនួន ដែលត្រូវជជែកវែកញែករហូតមកទល់ពេលសព្វថ្ងៃ ពាក់ព័ន្ធទៅនឹងប្រធានបទនេះ។

ទោះបីជារបបប្រល័យពូជសាសន៍ខ្មែរក្រហមបានដួលរលំទៅអស់រយៈកាលប្រមាណជិតកន្លះសតវត្សរ៍ទៅហើយក្តី គ្មានសំណួរណាមួយដែលបានផ្តោតទៅលើផលប៉ះពាល់បន្តឡើងដោយរបបនេះនៅក្នុងប្រទេសកម្ពុជាទេ។ គ្មានក្រុមគ្រួសារ, សហគមន៍ ឬស្ថាប័នកម្ពុជាណាមួយ ដែលមិនទទួលរងផលប៉ះពាល់ពីរបបនេះ ហើយបច្ចុប្បន្ន ផលពិបាកបន្តឡើងដោយរបបខ្មែរក្រហម អាចត្រូវបានកត់សម្គាល់យ៉ាងងាយនៅក្នុងវប្បធម៌និងនៅតាមស្ថាប័ននានា។ ប្រសិនបើផ្តោតទៅលើគោលគំនិតជាសកលណាមួយ ប្រាកដណាស់ នេះគឺជាផលប៉ះពាល់នៃឧក្រិដ្ឋកម្មឃោរឃៅ ដែលមិនបានសាបរលាប ឬលុបចេញក្នុងរយៈកាលជាក់លាក់ណាមួយ។

មានមតិយល់ឃើញនានា ទាក់ទងទៅនឹងថ្ងៃ ៧ មករា ដែលជំរុញឱ្យមានការឆ្លុះបញ្ចាំងផ្សេងៗ ដូចជា




ផែនទីវាយរំដោះប្រជាជន និងទឹកដីប្រទេសកម្ពុជាពីរបបខ្មែរក្រហមនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





ប្រជាជនកម្ពុជាប្រណិប័តន៍សាសនាជំនឿសាសនារបស់ខ្លួនឡើងវិញ បន្ទាប់ពីរបបខ្មែរក្រហម ដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ (ដេវីត ហក/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ហេតុអ្វីបានជារបបខ្មែរក្រហមដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ តែមិនមែននៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៨, ឆ្នាំ១៩៧៧ ឬឆ្នាំ១៩៧៦? ហេតុអ្វីបានជារបបខ្មែរក្រហមអាចឡើងកាន់អំណាចលើប្រទេសកម្ពុជា? ហេតុអ្វីបានជាកងកម្លាំងខ្មែរក្រហមនៅតែរឹងត្អឹង ក្នុងការប្រឆាំងជាមួយនឹងរដ្ឋាភិបាល និងប្រជាជនកម្ពុជាអស់រយៈកាលជាងមួយទសវត្សរ៍បន្ទាប់ពីរបបនេះដួលរលំទៅ? សំណួរទាំងអស់នេះតែងតែត្រូវបានចោទសួរ ទោះបីមិនមែនជាសាធារណៈក៏ធ្វើឡើងដោយស្ងៀមស្ងាត់ នៅក្នុងវេទិកាអប់រំសាធារណៈនានា ដែលរៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។ ទោះបីជាយ៉ាងណាក្តី គ្មានចម្លើយណាមួយ ដែលអាចឆ្លើយតបឱ្យបានសមស្របចំពោះសំណួរទាំងនេះឡើយ។

មនុស្សជាតិតែងតែត្រូវបែកបាក់នៅពេលមានវគ្គមានអំពើហិង្សា, ឧក្រិដ្ឋកម្មឃោរឃៅ និងអំពើប្រល័យពូជសាសន៍ដែលទាមទារឱ្យមានការឆ្លើយតបប្រកបដោយការប្តេជ្ញា។ ជាក់ស្តែង មកទល់ពេលបច្ចុប្បន្នឧក្រិដ្ឋកម្មឃោរឃៅនៅតែត្រូវបានបន្តប្រព្រឹត្តឡើងនៅតាមបណ្តាប្រទេសជាច្រើនហើយជម្លោះនៅតែបន្តកើតមាននៅទូទាំងសកលលោក។ សំណួរដ៏ត្រឹមត្រូវបំផុតដែលយើងត្រូវចោទសួរ គឺមិនមែនថា «តើយើងគួរធ្វើសកម្មភាពឬអត់» និង «នៅពេលណានោះទេ» ក៏ប៉ុន្តែយើងគួរតែចោទសួរថា «ហេតុអ្វីបានជាយើងមិនប្រតិកម្ម» និង«គួរប្រតិកម្មយ៉ាងដូចម្តេច?»



លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



អដ្ឋិធាតុរបស់ជនរងគ្រោះពីរបបខ្មែរក្រហម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ឆ្លើយតបចំពោះសំណួរថា «ហេតុអ្វីបានជាយើងមិនប្រតិកម្ម» មូលហេតុជាច្រើនត្រូវបានលើកឡើង ដែលរួមមាន ចាប់ពីចំណាយផ្នែកសេដ្ឋកិច្ច រហូតដល់ការគិតគូរពិចារណាអំពីមូលន័យផ្នែកនយោបាយ, ផ្នែកច្បាប់ និងផ្នែកយោធា ពាក់ព័ន្ធទៅនឹងការចូលរួមណាមួយ ដែលអាចរុញច្រានឱ្យបុគ្គលដែលមានសន្តានចិត្តល្អ ត្រូវប្រឈមជាមួយនឹងហានិភ័យ និងការវាយប្រហារពីគោលគំនិតអន្តរជាតិស្តីពីដែនអធិបតេយ្យភាព និងសណ្តាប់ធ្នាប់ជាដើម។ មូលហេតុទាំងនេះគឺសុទ្ធតែសមហេតុសមផល ក៏ប៉ុន្តែមិនទាន់គ្រប់គ្រាន់នៅឡើយ។ មូលហេតុទាំងនេះ មិនគ្រប់គ្រាន់សម្រាប់ប្រពន្ធម្នាក់ ដែលប្តីរបស់ខ្លួនត្រូវបានឃាត់ខ្លួន និងទទួលរងទារុណកម្មទេ។ មូលហេតុទាំងនេះមិនគ្រប់គ្រាន់សម្រាប់ឪពុកម្នាក់ដែលមើលឃើញកូនរបស់ខ្លួនត្រូវដាច់ពោះស្លាប់។ មូលហេតុទាំងនេះថែមទាំងមិនគ្រប់គ្រាន់ចំពោះម្តាយម្នាក់ ដែលកូនរបស់ខ្លួនត្រូវបានសម្លាប់។ ហើយមូលហេតុទាំងនេះគឺមិនគ្រប់គ្រាន់សម្រាប់កូនៗ ដែលបន្តសួរនាំរហូតមកទល់បច្ចុប្បន្ន ថាតើហេតុអ្វីឪពុកម្តាយ និងជីដូនជីតារបស់ខ្លួន ត្រូវស្លាប់ដោយគ្មានមូលហេតុ។

ខណៈយើងឆ្លុះបញ្ចាំងអំពីថ្ងៃ ៧ មករា យើងគួរធ្វើការឆ្លុះបញ្ចាំងមិនមែនត្រឹមតែទៅលើសំណួរនានា ដែលផ្តើមចេញពី «មានរឿងអ្វីកើតឡើង» «ដោយសារអ្វី» និង«អាចទៅជាយ៉ាងម៉េចវិញ» ប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងត្រូវចោទសួរថា «ហេតុអ្វីបានជាយើងមិនប្រតិកម្ម» និង«គួរប្រតិកម្មយ៉ាងដូចម្តេច»។ កម្ពុជា អាចដឹកនាំពិភពលោកក្នុងការជជែកវែកញែកទៅលើប្រធានបទនេះ មិនមែនត្រឹមតែក្នុងនាមជាជនរងគ្រោះ និងអ្នករស់រានមានជីវិតពីឧក្រិដ្ឋកម្មឃោរឃៅតែប៉ុណ្ណោះទេ ប៉ុន្តែក្នុងនាមជាអ្នកឈ្នះ។

លោក **ឆាំង យុ** គឺជានាយកនៃមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាអ្នករស់រានមានជីវិតពីវាលពិឃាតនៃរបបប្រល័យពូជសាសន៍ខ្មែរក្រហម។

# សូមគោរពជូន មិត្តភក្តិទាំងអស់គ្នាជាទីមេត្រី

ឆាំង យុ



លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា នៅឃុំបានកាម ស្រុកព្រៃកប្បាស ខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខណៈ យើងបោះជំហានឈានចូលឆ្នាំ២០២៥ ដែលជាខួបលើកទី៣០ នៃការបង្កើតមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំសូមឆ្លៀតឱកាសនេះ ឆ្លុះបញ្ចាំងអំពីប្រវត្តិរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា, គម្រោងនាពេលអនាគត និងអ្វីដែលអ្នកអាចចូលរួមចំណែកបាននៅក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅក្នុងសតវត្សរ៍ទី២១នេះ។

មជ្ឈមណ្ឌលឯកសារកម្ពុជា ចាប់បដិសន្ធិឡើងនៅក្នុងឆ្នាំ១៩៩៥ ដើម្បីប្រមែប្រមូលវត្ថុតាងប្រវត្តិសាស្ត្រ និងចងក្រងឯកសារប្រវត្តិសាស្ត្រ ពាក់ព័ន្ធជាមួយនឹងរបបប្រល័យពូជសាសន៍ខ្មែរក្រហម ដែលបានកើតមានឡើងនៅក្នុងប្រទេសកម្ពុជា។ ការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ពិតជាចាំបាច់ចំពោះដំណើរការសវនាការរបស់សាលាក្តីរួមគ្នារវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា គឺ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ទន្ទឹមនឹងនេះ មជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាឃ្លាំងផ្ទុកដ៏សំខាន់មួយនៃឯកសារដែលមានសារប្រយោជន៍ជាសារវន្តស្តីអំពីឧក្រិដ្ឋកម្មឃោរឃៅនៃរបបខ្មែរក្រហម រួមមានដែនទីបង្ហាញទីតាំងរណ្តៅ

សាកសព និងមន្ទីរសន្តិសុខខ្មែរក្រហម ក៏ដូចជាប្រវត្តិសាស្ត្រផ្ទាល់មាត់របស់អ្នករស់រានមានជីវិតពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម។

ទោះបីជាយ៉ាងណាក្តី មជ្ឈមណ្ឌលឯកសារកម្ពុជា គឺមិនមែនមានតួនាទីត្រឹមជាបណ្ណសារដ្ឋានតែប៉ុណ្ណោះទេ។ ក្នុងរយៈកាលជាច្រើនឆ្នាំកន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជា បានដើរតួនាទីជាគំរូមួយ សម្រាប់ស្ថាប័ននានា ប្រទេសដទៃទៀត និងពិភពលោក ក្នុងការអប់រំអំពីការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ។ មជ្ឈមណ្ឌលឯកសារកម្ពុជា បានបំពេញមុខងារជាទីប្រឹក្សាសម្រាប់ប្រទេសជាច្រើនសន្ធឹកសន្ធាប់ នៅក្នុងតំបន់មជ្ឈិមបូព៌ា, តំបន់អាហ្វ្រិក, តំបន់អាស៊ី និងតំបន់អាមេរិកខាងត្បូង ទៅលើប្រធានបទស្តីអំពីការចងក្រងឯកសារ ទាក់ទងទៅនឹងឧក្រិដ្ឋកម្មឃោរឃៅ។ មិនតែប៉ុណ្ណោះ មជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាកម្លាំងចលករដ៏សំខាន់នៃការបង្កើតជាមូលន័យថ្មីនៃយុត្តិធម៌ ដូចជា ការគាំពារចំពោះសុខភាពផ្លូវចិត្តនិងផ្លូវកាយរបស់អ្នករស់រានមានជីវិតពីឧក្រិដ្ឋកម្មឃោរឃៅនានា។ មជ្ឈមណ្ឌលឯកសារកម្ពុជា បានគាំទ្រចំពោះបុព្វហេតុទប់ស្កាត់វត្តមាននៃឧក្រិដ្ឋកម្មឃោរឃៅ នៅក្នុងប្រទេសកម្ពុជា, នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ និងអាស៊ីខាងត្បូង និងនៅទូទាំងពិភពលោក។

មជ្ឈមណ្ឌលឯកសារកម្ពុជា បានពង្រីកខ្លួន ពីបន្ទប់ការិយាល័យតូចមួយដែលមានកុំព្យូទ័រ១គ្រឿង នៅក្នុងទីក្រុងភ្នំពេញ ទៅជាមជ្ឈមណ្ឌលឯកសារ, អគារសិក្សាស្រាវជ្រាវ និងទីតាំងប្រវត្តិសាស្ត្រនៅតាមបណ្តាខេត្តចំនួន១៩ គ្របដណ្តប់ស្ទើរទូទាំងខេត្តក្រុងនៅក្នុងប្រទេសកម្ពុជា។ បន្ថែមលើសពីនេះទៅទៀត ដោយរួមសហប្រតិបត្តិការជាមួយនឹងការិយាល័យរបស់ទីប្រឹក្សាពិសេសស្តីពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍របស់អង្គការសហប្រជាជាតិ មជ្ឈមណ្ឌលឯកសារកម្ពុជា បានរៀបរៀងបង្កើតជាកម្មវិធីសិក្សាគាំពារដល់ការអប់រំស្តីពីការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅនៅក្នុងប្រទេសនានានៅក្នុងតំបន់អាស៊ីអាគ្នេយ៍។

ថ្វីត្បិតតែសម្រេចបាននូវជោគជ័យនិងសមិទ្ធផលគួរជាទីកត់សម្គាល់ទាំងនេះក្តី មជ្ឈមណ្ឌលឯកសារកម្ពុជា នៅតែរក្សាជំហរ **ងើយស្កក ឱនដាក់គ្រាប់** ក្នុងការបន្តបំពេញការងារឆ្លើយតបចំពោះតម្រូវការចាំបាច់របស់អ្នករស់រានមានជីវិតពីឧក្រិដ្ឋកម្មឃោរឃៅ និងក្រុមគ្រួសារ ក៏ដូចជាការជម្នះរាល់ឧបសគ្គសំខាន់ៗចំពោះមុខ ដើម្បីធានាផ្តល់នូវកម្មវិធីមួយប្រកបដោយនិរន្តរភាព ក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅពីការកើតមាននាពេលអនាគត នៅក្នុងប្រទេសកម្ពុជា, នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ និងអាស៊ីភាគខាងត្បូង និងនៅទូទាំងពិភពលោក។ នៅក្នុងឆ្នាំ២០២៥ មជ្ឈមណ្ឌលឯកសារកម្ពុជា រំពឹងយ៉ាងមុតមាំក្នុងការអនុវត្តសកម្មភាពនៅតាមមូលដ្ឋាន ពង្រីកកិច្ចសហការជាដៃគូនិងកិច្ចសហប្រតិបត្តិការអន្តរជាតិព្រមទាំងពង្រឹងជំហរមធ្យ័តក្នុងការបង្កើនការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ។

ខ្ញុំសង្ឃឹមថានៅក្នុងឆ្នាំថ្មីនេះ អ្នកនឹងឆ្លៀតឱកាសទៅកាន់ទីតាំងណាមួយ ក្នុងចំណោមមជ្ឈមណ្ឌលតាមបណ្តាខេត្តទាំង១៦ និងទីតាំងសិក្សាស្រាវជ្រាវទាំង៣ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ ខ្ញុំរំពឹងថាអ្នកអាចចូលរួមជាមួយគ្នាក្នុងការសាទរកេរដំណែលដ៏មានសារសំខាន់នេះ។ កាយវិការដ៏សប្បុរសទាំងអស់នេះ គឺជាការគាំទ្រចំពោះការសម្រេចបានចក្ខុវិស័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងការបង្កើតជាទីតាំងអចិន្ត្រៃយ៍របស់ខ្លួន ដែលនោះគឺជាវិទ្យាស្ថាន- សារមន្ទីរ មួយដែលបំពេញមុខងារទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ នៅក្នុងប្រទេសកម្ពុជា, នៅក្នុងតំបន់ និងនៅទូទាំងពិភពលោក។

សូមប្រសិទ្ធពរជ័យឆ្នាំថ្មី ឆ្នាំ២០២៥! សូមឱ្យឆ្នាំថ្មីផ្តល់ឱ្យអ្នកមានសុខភាពល្អបរិបូរណ៍, មានការចងចាំដ៏ប្រពៃ និងជោគជ័យជាច្រើន។

ថ្ងៃចន្ទ ១កើត ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៤

**ឆាំង យុ**
នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា

# ករណី កែវ សំណាង អនុប្រធានគណៈយោធាភូមិភាគបូព៌ា តាមចម្លើយរបស់ សុផាន, ផែន និង ចំណាររបស់ ឌុច

ផេង ពង្សរ៉ាស៊ី



កងទ័ពបដិវត្តន៍ខ្មែរក្រហមនៅសមរភូមិ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

កែវ សំណាង មានឈ្មោះបីគឺ ស៊ីថុន, ម៉ុន និង កែវ សំណាង។ ស៊ីថុន ជាឈ្មោះកំណើត។ កែវ សំណាង ជាឈ្មោះហៅក្រៅខណៈពេលដែល ស៊ីថុន ចូលបម្រើក្នុងចលនាតស៊ូប្រឆាំងនឹងអាណានិគមបារាំងមុនឆ្នាំ១៩៦០។ ចំណែក ម៉ុន ជាឈ្មោះបដិវត្តន៍ខណៈពេលដែលគាត់បានចូលទៅបង្កប់ខ្លួននៅក្នុងជួរបដិវត្តន៍ដើម្បីបំផ្លាញបដិវត្តន៍ ចាប់ពីឆ្នាំ១៩៧៤ រហូតមក។

ឯកសារជាច្រើនតម្កល់នៅបណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា ពុំបានបង្ហាញពីប្រវត្តិរូប ឬចម្លើយសារភាពរបស់កែវ សំណាង ឡើយ ក្រៅតែពីការឆ្លើយដាក់ពីសំណាក់កម្មាភិបាលខ្មែរក្រហមមួយចំនួនដែលអង្គការបានចាប់ខ្លួនមកដាក់នៅមន្ទីរ ស-២១ ក្នុងអំឡុងឆ្នាំ១៩៧៦។ តាមរយៈការអានឯកសារចម្លើយសារភាពរបស់ សុផាន និង ផែន, សៅ គា, និង ឈុំ ឈាង កែវ សំណាង គឺជាខ្មែរសេរីបង្កប់ស៊ីរូងផ្ទៃក្នុងបក្សកុម្មុយនីស្តកម្ពុជាដ៏មានឥទ្ធិពលម្នាក់ ដែលមានឋានៈជាកម្មាភិបាលខ្មែរក្រហមជាន់ខ្ពស់នៅក្នុង

ភូមិភាគបូព៌ា បន្ទាប់ពី ឈូក និង សោ ភឹម។ ទោះបីជាយ៉ាងដូច្នេះក៏ដោយ ក៏ចម្លើយរបស់ សៅ គា និង ឈុំ ឈាង មិនបានរៀបរាប់លម្អិតពីផែនការសកម្មភាពរបស់ កែវ សំណាង ហៅ ម៉ុន ឡើយ ព្រោះថា អ្នកទាំងបីនាក់នេះស្គាល់ កែវ សំណាង ដោយប្រយោល គឺស្គាល់តាមរយៈការណែនាំពី សុខ ជាលេខាតំបន់២៥ នៃភូមិភាគនិរតីប៉ុណ្ណោះ។ ចំណែកចម្លើយសារភាពរបស់ សុផាន និង ផែនបានរៀបរាប់ច្រើនពីសកម្មភាពក្បត់របស់ កែវ សំណាង ហៅ ម៉ុន តាំងពីដើម (សម័យតស៊ូជាមួយអាណានិគមបារាំង) រហូតដល់ពាក់កណ្តាលឆ្នាំ១៩៧៦ ខណៈដែល សុផាន និង ផែន ត្រូវអង្គការចាប់ខ្លួន។

## សុផាន រៀបរាប់អំពីប្រវត្តិ និងសកម្មភាពរបស់ កែវ សំណាង

សុផាន (មិនស្គាល់នាមត្រកូល) គឺជាកម្មាភិបាលខ្មែរក្រហមបម្រើការនៅក្នុងកងពល១៧០ ត្រូវអង្គការចាប់ខ្លួនបញ្ជូនមកកាន់មន្ទីរ ស-២១ កាលពីជាងពាក់កណ្តាលឆ្នាំ១៩៧៦ ពីបទក្បត់បដិវត្តន៍។ ឯកសារចម្លើយសារភាពនេះ មិនមានផ្នែក ឬទំព័រណាមួយ រៀបរាប់អំពីសកម្មភាពក្បត់របស់ខ្លួនឡើយ។ ប៉ុន្តែគ្រប់ទំព័រ និងផ្នែកដែលមានសរសេរនៅក្នុងចម្លើយនេះទាំងអស់ គឺមាននិយាយរៀបរាប់ពីជីវភាពរស់នៅប្រចាំថ្ងៃ ប្រវត្តិគ្រួសារ និងសកម្មភាពរបស់ កែវ សំណាង។

សំណាង មានស្រុកកំណើតនៅភូមិព្រៃមាន់ ឃុំបន្ទាយចក្រី ស្រុកព្រះស្តេច តំបន់២៤។ នៅឆ្នាំ១៩៥២ សំណាង ត្រូវ ងិន ហោ និង ប៉ាយ បញ្ចុះបញ្ចូលឱ្យចូលបម្រើក្នុងអង្គការខ្មែរសេរី ដែលពេលនោះ «ចលនាខ្មែរសេរី» នៅមិនទាន់លេចរូបរាងឡើងនៅឡើយទេ។ ចាប់តាំងពីឆ្នាំ១៩៥៦មក ទើបចលនាខ្មែរសេរី ចាប់ផ្តើមធ្វើសកម្មភាពកាន់តែខ្លាំងឡើងៗ បន្ទាប់ពីកិច្ចខំប្រឹងប្រែងស្វែងរកការចរចារវាងមេដឹកនាំខ្មែរសេរី ជាមួយនឹងសម្តេចព្រះនរោត្តម សីហនុ ទទួលបរាជ័យ។ សឺង ង៉ុកថាញ់ គឺជាមេដឹកនាំចលនាខ្មែរសេរី។ សឺង ង៉ុកថាញ់ បានអូសទាញ ងិន ហោ និង ប៉ាយ ឱ្យចូលបម្រើក្នុងចលនាខ្មែរសេរី តាំងពីឆ្នាំ១៩៤៨មកម៉្លេះ គឺក្នុងពេលដែលប្រទេសកម្ពុជាកំពុងស្ថិតក្រោមការត្រួតត្រាពីអាណានិគមបារាំង។ សឺង ង៉ុកថាញ់ ក៏ធ្លាប់បានជួបពិភាក្សាពីផែនការអូសទាញកម្លាំងស្នូលបន្ថែមឱ្យកាន់តែច្រើនទៀតដែរ ជាមួយ ឈូក ក្រោមការចាត់តាំងរបស់ សោ យ៉ាន់ ហៅ សោ ភឹម កាលពីឆ្នាំ១៩៧៤។

មុនចូលបម្រើក្នុងចលនាខ្មែរសេរី ស៊ីផុន ហៅ កែវ សំណាង ហៅ ម៉ុន គឺជាអ្នកជួញដូរក្របីទៅលក់នៅវៀតណាមខាងត្បូង ហើយក៏ជាមេចោរមួយរូបនៅក្នុងភូមិដែរ។ ក្នុងអំឡុងពេលជាអ្នកតស៊ូប្រឆាំងនឹងអាណានិគមបារាំង សំណាង ទទួលបានតួនាទីជាស្នងការនយោបាយកងអនុសេនាតូចខាងសម្ភារ។ បន្ទាប់ពីប្រទេសកម្ពុជា ទទួលបានឯករាជ្យពីបារាំងនៅឆ្នាំ១៩៥៤ សំណាង ទទួលបានការចាត់តាំងឱ្យផ្លាស់ ប្តូរទីលំនៅមករស់នៅក្នុងចម្ការកៅស៊ូខេត្តកំពង់ចាមវិញ ដោយស្នាក់នៅក្នុងផ្ទះជាមួយ ប៊ុន សានី ដែលជាប្រធានចម្ការកៅស៊ូ។ នៅចម្ការកៅស៊ូ សំណាង មានតួនាទីជាកាប៉ូរ៉ាល់មើលការខុសត្រូវចម្ការកៅស៊ូ។ ក្រៅពីបម្រើការងារនៅក្នុងចម្ការកៅស៊ូ សំណាង បានប្រកបរបររកស៊ីជួញដូរគោ និងឈើហ៊ុបយកទៅលក់នៅព្រៃនគរ ប្រទេសវៀតណាម ដែលការងារនេះគ្រាន់តែជាមុខរបរបន្ទាប់បន្សំតែប៉ុណ្ណោះ។ តាមការពិត គោលបំណងនៃការផ្លាស់ប្តូរទីលំនៅនេះ គឺដើម្បីកសាងមូលដ្ឋានបង្អែកខ្មែរសេរីនៅក្នុងចម្ការកៅស៊ូកំពង់ចាម នៅជប់ ពាមជាំង និងមេមត់។ ក្រោយមកទៀត សំណាង ត្រូវ ស៊ីវ ហេង ដំឡើងឋានៈជាសមាជិកគណៈកម្មាធិការខេត្តកំពង់ចាម ក្រោយពីបានសង្កេតឃើញថា សំណាង ធ្វើការងារយ៉ាងសកម្មនៅក្នុងចលនារបស់ខ្លួនរួចមក។

បន្ទាប់ពី ស៊ីវ ហេង ក្បត់បដិវត្តន៍នៅឆ្នាំ១៩៥៩ សំណាង បានភៀសខ្លួនទៅរស់នៅក្នុងស្រុកឆ្លូង ខេត្តក្រចេះ ដើម្បីលាក់ខ្លួន។ ក្នុងពេលរស់នៅក្នុងខេត្តក្រចេះ ប្រពន្ធរបស់គាត់បានផិតក្បត់គាត់។

បន្ទាប់ពីបានដឹងរឿងហេតុនេះ សំណាង បានបង្ខំឱ្យអ្នកទាំងពីររៀបការនឹងគ្នាជាប្តីប្រពន្ធ ជាថ្នូរនឹងការមិនសម្លាប់បុរសដែលជាសាហាយស្មន់។ ចាប់តាំងពីពេលនោះមក សំណាង បានរៀបការជាមួយប្រពន្ធទីពីររបស់គាត់ ដែលមានស្រុកកំណើតនៅក្នុងខេត្តកំពង់ចាម។ ខណៈពេលដែល សំណាង កំពុងលាក់ខ្លួននៅខេត្តក្រចេះ ថ្នាក់លើរបស់គាត់បានបញ្ជូននិរសារឱ្យភ្ជាប់ខ្សែរយៈជាមួយគាត់ឡើងវិញ ដើម្បីរៀបចំផែនការក្បត់បដិវត្តន៍សារជាថ្មី។ ក្រោយមក សំណាង បានទទួលតួនាទីថ្មីជា ប្រធានយោធាតំបន់២០ ដែលមាន ធន ជាលេខាតំបន់។

បន្ទាប់ពីបានភ្ជាប់ខ្សែរយៈឡើងវិញ ចាប់តាំងពីឆ្នាំ១៩៦២ ដល់ឆ្នាំ១៩៦៤ ឈូក និង លី ផែន ឧស្សាហ៍ស្កាត់មកជួប សំណាង នៅផ្ទះ ប៊ុន សានី ដើម្បីត្រួតពិនិត្យទីតាំង និងស្ថានភាពមូលដ្ឋានបង្អែកខ្មែរសេរី។ នៅឆ្នាំ១៩៦៥ ចាន់ សេង ហុង និង ភួង បានទទួលបញ្ជាពី ឈូក ឱ្យ កែវ សំណាង ចូលបង្កប់ខ្លួនក្នុងជួរបដិវត្តន៍វិញ។ នៅឆ្នាំ១៩៦៧ និង ១៩៦៨ ឈូក បានមកជួប កែវ សំណាង ញឹកញាប់ ដើម្បីពង្រឹងផែនការកសាងកម្លាំងស្នូលខ្មែរសេរីនៅក្នុងជួរបដិវត្តន៍។ នៅឆ្នាំ១៩៦៨ដដែល សំណាង មានទំនាក់ទំនង ជាមួយ លី ផែន, ម៉ៃ ដួ និង នៅ មាន ជាសមាជិកក្រុមខ្មែរសេរី ព្រមទាំងកម្លាំងនៅក្រុងហាណូយ។ ការស្គាល់គ្នានេះ គឺដើម្បីរៀបចំផែនការចាត់តាំងកម្លាំងក្បត់នៅក្នុងជួរកងទ័ព និងរៀបចំសមាសភាពដែលជាសមាជិកក្នុងចលនាខ្មែរសេរីឱ្យដឹកនាំ និងគ្រប់គ្រងមន្ទីរនានាក្នុងភូមិភាគបូព៌ា។ នៅឆ្នាំ១៩៧០ សំណាង បានបង្ហាញមុខជាសាធារណៈ នៅក្នុងអង្គប្រជុំជាច្រើន ដែលមានការចូលរួមពី ឈូក ចក្រី និង លី ផែន ផង ដើម្បីទទួលផែនការ និងអនុវត្តផែនការ។ នៅខែកញ្ញា ឆ្នាំ១៩៧០ សំណាង និង ប៊ុន សានី បានរាយការណ៍ទៅកាន់គណៈមជ្ឈិមបក្សប្រចាំភូមិភាគបូព៌ា អំពីសភាពការណ៍រឹងមាំនៃមូលដ្ឋានបង្អែកខ្មែរសេរីនៅតំបន់២១។ នៅឆ្នាំ១៩៧៤ សំណាង បានដឹកនាំកងទ័ពមួយកងពលមកប្រយុទ្ធនៅសមរភូមិផ្លូវជាតិលេខ១ ដើម្បីបង្ហាញពីស្មារតីប្រយុទ្ធរបស់យុទ្ធមិត្តនៅចំពោះមុខភូមិភាគពិសេស។

នៅដើមឆ្នាំ១៩៧៦ បន្ទាប់ពីថ្ងៃជ័យជម្នះរបស់ខ្មែរក្រហមលើទីក្រុងភ្នំពេញ សំណាង បានជួបជាមួយ នៅ មាន ដើម្បីរៀបចំផែនការ «បង្កើនការវាយឈ្លប និង ពង្រីកទំនាស់ផ្ទៃក្នុងរវាងអង្គភាព និងកងទ័ព»។ នៅខែកុម្ភៈ ឆ្នាំ១៩៧៦ កែវ សំណាង, នៅ មាន, ឈូក និង លី ផែន បានជួបប្រជុំគ្នានៅព្រៃវែង ដើម្បីរៀបចំផែនការវាយកម្ទេចអង្គការនៅក្នុងខែកក្កដា ឆ្នាំ១៩៧៦ និងពង្រឹងសមត្ថភាពក្នុងការអនុវត្តផែនការដែលបានចាត់តាំងថ្មីដូចជា អប់រំកងទ័ពឱ្យខឹងនឹងអង្គការដឹកនាំ, ពង្រឹងខ្សែរយៈទាក់ទងជាមួយវៀតណាម, បង្កើតខ្សែរយៈមួយក្រុមផ្សេងទៀតទុកជំនួសក្រុមចាស់ដែលត្រូវអង្គការកម្ទេច, ត្រៀមស្បៀងអាហារសម្រាប់កងទ័ពប្រយុទ្ធ, ជ្រើសរើសកងទ័ពបន្ថែមទៀតដើម្បីបំពេញកងទ័ពដែលពលី, ពង្រីកកម្លាំងស្នូលខ្មែរសេរីនៅមូលដ្ឋានតំបន់២៤, ពង្រីកការជ្រើសរើសកម្លាំងខ្មែរសេរីបន្ថែមឱ្យបាន៥០០នាក់ក្នុងមួយខែ និង ប្រមូលស្រូវត្រៀមទុកតាមអង្គភាពទាំងអស់។

## ផែន រៀបរាប់ពីអត្តចរិក និងសីលធម៌រស់នៅរបស់ កែវ សំណាង ឬ ម៉ុន

ផែន គឺជាកម្មាភិបាលជាន់ខ្ពស់ខ្មែរក្រហមម្នាក់ដែលស្និទស្នាលជាមួយ សំណាង។ ផែន ធ្លាប់បានរស់នៅ ធ្វើការ និងរួមរស់ជីវភាពជាមួយ សំណាង តាំងពីចូលបម្រើបដិវត្តន៍ជាយូរមកហើយ។ ផ្នែកចុងក្រោយនៃចម្លើយសារភាពរបស់ សុផាន មានឯកសារសំណេរដោយដៃចំនួនបួនទំព័រ ដែលជាការរៀបរាប់ របស់ ផែន អំពីអត្តចរិក និងសីលធម៌រស់នៅរបស់ កែវ សំណាង តាំងពីគាត់បានស្គាល់គ្នាជាមួយ សំណាង រហូតមក។ ខាងក្រោមនេះ ជាការដកស្រង់សម្តីរបស់ ផែន៖

កែវ សំណាង មានអត្តចរិកក្អេងក្អាង អំណួតអួតអាង និងមិនស្តាប់មតិយោបល់របស់ថ្នាក់ស្មើគ្នា និងថ្នាក់ក្រោមឡើយ។ កាលពីស្ថិតនៅក្នុងតំណែងជា

ស្នងការអនុសេនាតូច ខាងសម្ភារ ក្នុងចន្លោះឆ្នាំ ១៩៦២ ដល់ឆ្នាំ ១៩៦៥ សំណាង បានធ្វើឱ្យមានផ្ទាំងផ្ទាក់ជាមួយ សមភាគីវៀតណាមដែលធ្វើការនៅក្នុងបុព្វហេតុតែមួយ។ សំណាង តែងតែអួតអាងពីគុណសម្បត្តិរបស់ខ្លួនក្នុងការអនុវត្តផែនការដែលទទួលបានជ័យជម្នះជាបន្តបន្ទាប់ ក្នុងការប្រមូលកម្លាំងក្បត់ចូលចលនាខ្មែរសេរី និងជ្រើសរើសកងទ័ព។ ដោយសារតែខ្លួនជាជនបង្កប់ឱ្យចលនាខ្មែរសេរី សំណាង បានបង្ហាញឱ្យគេឯងគ្រប់គ្នាឃើញថាខ្លួនមានសម្លៀកបំពាក់ស្អាតជាងគេ និងហ៊ឺហាជាងគេ។ សំណាង ចូលចិត្តផឹកស្រា និងបរិភោគម្ហូបអាហារឆ្ងាញ់ៗ។ ប្រាក់កាសដែលអង្គការប្រគល់ឱ្យសម្រាប់ផ្គត់ផ្គង់ស្បៀងអាហារក្នុងអង្គភាព ជាពិសេសកងទ័ពត្រូវសំណាងយកទៅចាយវាយ សប្បាយឥតកោតក្រែង។ សោ យ៉ាន់ (សោភឹម) និង ឈូកបានប្រគល់ឱ្យសំណាង នូវបារីទាំងសុងៗ ស្រាថ្លៃៗ ទាំងដបៗ និងចំណីអាហារឆ្ងាញ់ៗគ្រប់ពេលដែល សំណាង ត្រូវការ។

សំណាង ធ្លាប់ប្រព្រឹត្តកំហុសឆ្គងសីលធម៌ជាមួយនារីៗជាច្រើននាក់ តាំងពីនៅតំបន់២១ នៅសមរភូមិ និងនៅព្រៃវែង។ ឧទាហរណ៍ នៅក្នុងខេត្តព្រៃវែង សំណាង ធ្លាប់បានចាប់រំលោភកុមារីអាយុ១៥ឆ្នាំម្នាក់ ពេលដែលកុមារីរូបនោះកំពុងដេកលក់។ ក្រោយមក កុមារីនោះបានរាយការណ៍ពីការចាប់រំលោភនេះ ទៅកាន់កម្មាភិបាលភូមិភាគ ហើយរាល់សេចក្តីរាយការណ៍ដោយផ្ទាល់មាត់របស់កុមារីនោះត្រូវកម្មាភិបាលសួរចម្លើយ ថតសំឡេងទុកនៅក្នុងខ្សែអាត់សំឡេង។ ប៉ុន្តែនៅពេលដែលអង្គការចាប់ខ្លួន ផែន ខ្សែអាត់សំឡេងនោះបានធ្លាក់ទៅក្នុងដៃរបស់អង្គការ។

## កំណត់ហេតុរបស់ កាំងហ្គេចអ៊ាវ ហៅ ឌុច អំពីទង្វើរបស់ កែវ សំណាង ហៅ ម៉ុន ធ្វើនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៦

ឯកសារសរសេរដោយដៃចំនួនពីរទំព័រ ដែលជាសំណេររបស់ ឌុច ប្រធានមន្ទីរ ស-២១ បានបង្ហាញពីសេចក្តីសង្ខេបចម្លើយសារភាពរបស់អ្នកទោសបីនាក់ គឺ ព្រុំ មាន ហៅ អ៊ុយ ពិសិដ្ឋ ហៅ ខៀន, សោ គា និង ឈុំ ឈាង ជាកម្មាភិបាលថ្នាក់វរសេនាតូច នៃតំបន់២៥ ពាក់ព័ន្ធនឹងសកម្មភាពក្បត់របស់ កែវ សំណាង។ សេចក្តីសង្ខេបនេះ បានបង្ហាញពីភាពជាប់ទាក់ទងគ្នារវាង កែវ សំណាង និង សុក ដែលជាលេខាតំបន់ ២៥ ពាក់ព័ន្ធនឹងសកម្មភាពក្បត់បដិវត្តន៍ជាខ្សែរយៈ។ របាយការណ៍ដដែល បានរៀបរាប់ពីការបើកទូលាយឱ្យមានការរត់ទៅជ្រកកោននៅក្នុងអង្គភាពរបស់ កែវ សំណាង និង ចក្រី ពីសំណាក់ជនក្បត់អង្គការទាំងឡាយណាដែលបានអនុវត្តសកម្មភាព ហើយត្រូវការកន្លែងពួនសំងំលាក់ខ្លួនដើម្បីកុំឱ្យមានការចាប់ខ្លួនពីអង្គការ។ ជាចុងក្រោយ ឌុចបានសរុបថា អង្គភាពរបស់ កែវ សំណាង គឺវរសេនាធំ១២៦ ពុំមានជនក្បត់ណាម្នាក់បានរត់ទៅជ្រកកោន ឡើយ។ ការសន្និដ្ឋាននេះ គឺបន្ទាប់ពី ឌុចបានអានគ្រប់ចម្លើយសារភាពរបស់អ្នកទោសដែលពាក់ព័ន្ធនឹងករណីកែវ សំណាង និងបានរកឃើញថា អ្នកទោសដែលបានចាប់ខ្លួនមកកាន់មន្ទីរ ស-២១ ពុំបានរៀបរាប់ពីសកម្មភាពរបស់ខ្លួនចូលទៅពួនសំងំនៅក្នុងអង្គភាពរបស់ កែវ សំណាង ឡើយ។

## សេចក្តីសន្និដ្ឋាន

គ្រប់ចម្លើយសារភាពទាំងអស់ដែលបានអានរួមទាំងកំណត់ហេតុរបស់ ឌុច ជាប្រធានមន្ទីរ ស-២១ ផងដែល ទាក់ទងនឹងករណីឈ្មោះ កែវ សំណាង ហៅ ស៊ីថុន ហៅ ម៉ុន គឺពុំបានបង្ហាញឱ្យឃើញថា សាមីខ្លួនត្រូវបានសម្លាប់ ឬចាប់ខ្លួនមកដាក់ក្នុងមន្ទីរឃុំឃាំង ជាពិសេសមន្ទីរ ស-២១ ឡើយ ខណៈដែល សោភឹម, ឈូក, ចក្រី, សុផាន, ផែន និងកម្មាភិបាលជាន់ខ្ពស់ដទៃទៀត ត្រូវអង្គការចាប់ខ្លួន និងសម្លាប់បន្ទាប់ពីសួរចម្លើយរួច។ ចំណែកកម្មាភិបាលឯទៀតៗដែលជាបក្ខពួករបស់ សោភឹម ត្រូវបានចាប់ខ្លួនមកដាក់នៅមន្ទីរ ស-២១ ហើយភាគច្រើនទៀត ត្រូវបានសម្លាប់នៅ នឹង ទីតាំងសម្លាប់មនុស្សធំៗចំនួនបីកន្លែងគឺ បុស្សីសាញ់ និងភ្នំកំប្តុក ក្នុងខេត្តព្រៃវែង, និង ទួលពពកវិល ក្នុងខេត្តស្វាយរៀង។

# លួន ឡុំ ហៅ វ៉ាន ៖ សមាជិកអនុសេនាធំ៧១២ វរសេនាតូច៧១ ផ្នែកឃ្លាំងរដ្ឋ ឬស្សីកែវ

*មីន សាណាស់*



កម្មករនៅឃ្លាំងរដ្ឋក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) កំពុងដឹកជញ្ជូនជ័រក្រែប់ចេញពីកប៉ាល់យកទៅទុកក្នុងឃ្លាំង សម្រាប់នាំចេញទៅលក់នៅក្រៅប្រទេស។ ខែមីនា ឆ្នាំ១៩៧៨។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅចុងឆ្នាំ១៩៧៦ និងដើមឆ្នាំ១៩៧៧ ការស្រាវជ្រាវរកខ្មាំងបង្កប់ផ្ទៃក្នុងបានក្លាយជាកិច្ចការចម្បងរបស់ខ្មែរក្រហម។ ខ្មែរក្រហមបានបញ្ចុះបញ្ចូលអ្នកភូមិឱ្យបេះស៊ើបការណ៍ពីគ្នាទៅវិញទៅមក ដោយប្រើប្រាស់ពាក្យស្លោកថា «ត្រូវបេះតាមដានគ្នាទៅវិញទៅមក និង ត្រូវរាយការណ៍ជូនអង្គការ»។ មធ្យោបាយផ្សេងៗទៀតដែលខ្មែរក្រហមប្រើក្នុងការស្វែងរកចាប់ខ្លួនខ្មាំងបង្កប់រួមមាន ត្រូវមានឈ្លបយកការណ៍ របាយការណ៍ពីអ្នកយកការណ៍ ការធ្វើប្រវត្តិរូបផ្ទាល់ខ្លួនជាញឹកញាប់ និងចម្លើយសារភាព។

នៅក្នុងទំព័រទី៧ រហូតដល់ទំព័រ ៣៨ នៃឯកសារលេខ J០០០៨០ តម្កល់ក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជា បានបង្ហាញពីសំណេរសេចក្តីរាយការណ៍ ជូនអង្គការខ្មែរក្រហម អំពីប្រវត្តិសកម្មភាពក្បត់របស់ឈ្មោះ លួន ឡុំ ហៅ វ៉ាន ដែលមានតួនាទីមុនចាប់ខ្លួនជាសមាជិកកង៧១២ វរសេនាតូច៧១ វរសេនាធំឃ្លាំងរដ្ឋ តាំងពីថ្ងៃចាប់ខ្លួន រហូតដល់បញ្ជូនមកកាន់មន្ទីរ ស-២១។ ស្ថិតនៅក្នុងមន្ទីរសន្តិសុខស-២១ ដែលជាមន្ទីរសន្តិសុខ

កម្រិតខ្ពស់នៃរបបខ្មែរក្រហម ការសួរចម្លើយ និងការធ្វើទារុណកម្ម គឺជាសកម្មភាពធម្មតាប្រចាំថ្ងៃ។ តែតាមរយៈការសង្ខេបចម្លើយសារភាពពីសន្តិសុខក្នុងមន្ទីរស-២១ ដោយវាយអក្សរជាអង្គលីលេខបានសង្កត់ធ្ងន់ទោសកំហុសរបស់ លួន ឡុំ ហៅ វ៉ាន ពីបទការកសាងកម្លាំង កម្ទេចសេដ្ឋកិច្ចរបស់អង្គការ និងបង្កើតកម្លាំងក្នុងជួរបដិវត្តន៍ និង បំផុសចលនាប្រជាជនមូលដ្ឋានឱ្យរត់ចូលតំបន់ខ្មាំង។

**ខាងក្រោមនេះជាសេចក្តីរាយការណ៍របស់ លួន ឡុំ ហៅ វ៉ាន់ អំពីសកម្មភាពរបស់ខ្លួន៖**

ខ្ញុំឈ្មោះ លួន ឡុំ ហៅ វ៉ាន ភេទប្រុស អាយុ ២៧ឆ្នាំ(១៩៧៧) កើតនៅភូមិត្រពាំងព្រៃ ឃុំកៀនសង្កែ ស្រុកជីក្រែង ខេត្តសៀមរាប ស្ថិតក្នុងតំបន់១០៦ ភូមិភាគឧត្តរ។ មុនចាប់ខ្លួនខ្ញុំមានតួនាទីជាសមាជិកកងពល៧១២ វរសេនាតូច៧១ វរសេនាធំឃ្លាំងរដ្ឋ។ ខ្ញុំមានប្រពន្ធឈ្មោះ រៀម មានតួនាទីជាយុទ្ធនារីក្នុងអង្គភាពវរសេនាតូច៧៨ វរសេនាធំឃ្លាំងរដ្ឋ។ ប្រវត្តិកាលពីកុមារ ស្ថិតក្នុងឆ្នាំ១៩៦៣ ខ្ញុំបានចូលរៀននៅសាលាបឹងខ្យង ចាប់ពីថ្នាក់ទី១២ រហូតដល់ថ្នាក់ទី៩ ក្នុងឆ្នាំ១៩៦៨ ក៏បានឈប់រៀន។

ចូលមកដល់ចុងឆ្នាំ១៩៦៨ ឈ្មោះ ប៉ែន ជាអតីតមេឃុំកៀនសង្កែ បច្ចុប្បន្នស្លាប់ បានមកអប់រំខ្ញុំឱ្យចូលធ្វើជាគិញ ដើម្បីធ្វើការតាមដានខ្មែរក្រហម ដែលកាលនោះមានសមាជិកចូលរួម រួមទាំងខ្ញុំចំនួន ៩នាក់ ដូចជា៖ រឹម អតីតសិស្សថ្នាក់ទី៣ បច្ចុប្បន្នប្រធានឃុំជ្រនៀង ស្រុកស្រីស្នំ ខេត្តសៀមរាប តំបន់១០៦ ភូមិភាគឧត្តរ។ សុង អតីតស្មៀនឃុំ បច្ចុប្បន្នធ្វើជាជាងដែក សហករណ៍ឃុំកៀនសង្កែ ស្រុកជីក្រែង ខេត្តសៀមរាប តំបន់១០៦ ភូមិភាគឧត្តរ។ ឃួន អតីតគ្រូបង្រៀនបច្ចុប្បន្នអនុប្រធានសហករណ៍ភូមិត្រពាំងព្រៃឃុំកៀនសង្កែ ស្រុកជីក្រែង ខេត្តសៀមរាប តំបន់១០៦ ភូមិភាគឧត្តរ។ ឡុង អតីតសិស្សថ្នាក់ទី៥ បច្ចុប្បន្នធ្វើយោធាតំបន់១០៦ ភូមិភាគឧត្តរ។ ឡាញ់ អតីតសិស្សថ្នាក់ទី៧ បច្ចុប្បន្នធ្វើយោធាតំបន់១០៦។ ឈិត អតីតប្រជាជន បច្ចុប្បន្នប្រជាជនសហករណ៍ភូមិត្រពាំងព្រៃ ឃុំកៀនសង្កែ ស្រុកជីក្រែង ខេត្តសៀមរាប តំបន់១០៦ ភូមិភាគឧត្តរ។ ឈឿន អតីតសិស្សថ្នាក់ទី៦ បច្ចុប្បន្នប្រជាជនក្នុងសហករណ៍ភូមិត្រពាំងព្រៃ កៀនសង្កែ ស្រុកជីក្រែង ខេត្តសៀមរាប តំបន់១០៦ ភូមិភាគឧត្តរ។ រឿន អតីតសិស្សថ្នាក់ទី៦ បច្ចុប្បន្នបម្រើយោធាតំបន់១០៦។ ឡូន អតីតសិស្សថ្នាក់ទី៨ បច្ចុប្បន្នធ្វើជាយោធា។ ក្រោយមកខ្ញុំ, រឹម និង សុង បានទទួលផែនការពីមេឃុំ ប៉ែន ឱ្យតាមដានសកម្មភាពខ្មែរក្រហម យោសនាប្រជាជនប្រឆាំងខ្មែរក្រហម និង កសាងកម្លាំងគិញបន្ថែម។ ផែនការពាចំណុចនេះ ខ្ញុំក៏យកទៅសហការជាមួយឈ្មោះ ឃួន និង ឈឿន។

ឆ្នាំ១៩៦៩ ក្រុមខ្ញុំកសាងកម្លាំងបានម្នាក់ឈ្មោះ ង្លួន អតីតជាប្រជាជនបច្ចុប្បន្នជាសមាជិកសហករណ៍ភូមិត្រពាំងព្រៃ ឃុំកៀនសង្កែ ស្រុកជីក្រែង ខេត្តសៀមរាប ដោយលើកពីខ្លឹមសារអប់រំថា បុណ្យស័ក្តិមានចំពោះមុខ និង សកម្មភាពខ្មែរក្រហមរាល់ថ្ងៃ។ ង្លួនបានចូលរួមធ្វើសកម្មភាពជាមួយខ្ញុំរហូត។ ដោយសារឃើញ ង្លួន សកម្មនឹងការងារ ខ្ញុំក៏រាយការណ៍ទៅកាន់មេឃុំប៉ែន ដើម្បីយក ង្លួន ចូលជាខ្សែគិញ និងឱ្យដឹងពីផែនការច្បាស់ជាងមុន។ សកម្មភាពក្រោយមកទៀត ខ្ញុំនិងបក្ខពួកបានចាប់ប្រជាជន១គ្រួសារ នៅភូមិថ្នល់បែក និង២គ្រួសារនៅភូមិសាលាកកោះ ដែលបានលួចផ្តល់អង្ករជូនខ្មែរក្រហម។ ប្រជាជនដែលចាប់បាន ក្រុមខ្ញុំបានបញ្ជូនទៅឱ្យមេឃុំ ប៉ែនរួចក៏ ប៉ែន បញ្ជូនទៅឱ្យខាងខេត្តសៀមរាបបន្ត។

ឆ្នាំ១៩៧០បន្ទាប់ពីមានរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ចេញពីតំណែងព្រះប្រមុខរដ្ឋ មេឃុំប៉ែន បានហៅខ្ញុំនិងសមាជិកដទៃទៀតមកប្រជុំនៅសាលាឃុំ ដែលមានខ្លឹមសារចំនួន៣ គឺ យោសនាប្រជាជនធ្វើទាហានសាធារណរដ្ឋ, កសាងកម្លាំងគិញថ្មីបន្ថែម និង រកមូលដ្ឋានបដិវត្តន៍ដើម្បីកម្ទេច។ ប្រជុំចប់ខ្ញុំ និងណឺ បានកសាង អប់រំយុវជនពីរនាក់ ដែលជាអ្នកស្ម័គ្រចិត្តធ្វើជាទាហាន លន់ នល់ ឱ្យចូលក្នុងក្រុម។ ចូលមកដល់ពាក់កណ្តាលឆ្នាំ

១៩៧០ សភាពការណ៍ប្រែប្រួល កងទ័ពបដិវត្តន៍ចូលមកដល់ឃុំកៀនសង្កែ ផ្ទាល់ ជាហេតុនាំឱ្យមេឃុំ ប៉ែន នាំប្រពន្ធកូនរត់ទៅរស់នៅខេត្តសៀមរាប ខ្ញុំក៏ដាច់ខ្សែរយៈទាក់ទងធ្វើសកម្មភាពនានា។

ឆ្នាំ១៩៧១ ក្នុងភូមិស្ថិតក្រោមការគ្រប់គ្រងកងទ័ពបដិវត្តន៍ ខ្ញុំ, ហេង, រ៉ែម, ប៉ែន និង សុង បានអប់រំឈ្មោះ ជុំ ជាប្រជាជនក្នុងភូមិត្រពាំងព្រៃ និងឈ្មោះ យន់ អតីតជាប្រជាជន បច្ចុប្បន្នជាប្រធានសហករណ៍ត្រពាំងព្រៃឱ្យចូលរួមជាមួយបក្ខពួកខ្ញុំដើម្បីចាប់យុទ្ធជនបដិវត្តន៍ម្នាក់ឈ្មោះ ជួន សម្លាប់ចោលដោយសម្ងាត់ៗ ដើម្បីបានចេញចូលទៅខេត្តសៀមរាប បក្ខពួកខ្ញុំបានទាក់ទងឈ្មោះ រ៉ែម អតីតជាសិស្សថ្នាក់ទី៣ បច្ចុប្បន្នក្លាប់មិនបាន តែ រ៉ែម ជាគិញសម្ងាត់របស់ឈ្មោះ ហោ ជាស័ក្តិ៣ ប្រចាំក្នុងខេត្តសៀមរាប។ បន្ទាប់មកទៀត ក្រុមខ្ញុំបានដឹងពីទីតាំងឃ្លាំងអង្ករបស់អង្គការ ដែលស្តុកនៅរោងម៉ាស៊ីន លន់ ហុង ស្ថិតនៅឃុំដំដែក ស្រុកសូទ្រនិគម រួចយកទៅរាយការណ៍ប្រាប់ រ៉ែម។ រ៉ែម បានទទួលដំណឹងនេះរួចក៏នាំក្រុមខ្ញុំទៅជួបជាមួយ ហោ នៅទីរួមខេត្តសៀមរាប។ បន្ទាប់មក ហោ បានហៅខ្សែគិញមួយចំនួនមកប្រជុំមានឈ្មោះដូចជា៖ ហុង, ឡាញ់ និង យួន ដោយខ្លឹមសារគឺ ត្រូវកសាងកម្លាំងគិញឱ្យបានច្រើនជូនសាធារណរដ្ឋខ្មែរ, អប់រំប្រជាជនឱ្យរត់ចេញពីតំបន់រំដោះ ចូលសៀមរាប ដើម្បីរួបរួមកម្លាំងជាមួយសាធារណរដ្ឋខ្មែរ និង រកអ្នកមូលដ្ឋានដែលជាជនបដិវត្តន៍ ដើម្បីកម្ទេចទាំងកម្លាំង និង សេដ្ឋកិច្ច។ ចំណែកទីតាំងស្តុកអង្កររបស់ខ្មែរក្រហម ហោ បានហៅយន្តហោះបីគ្រឿងមកទម្លាក់គ្រាប់បែកឆេះអង្ករអស់មួយឃ្លាំង ព្រមទាំងស្លាប់មនុស្សមួយចំនួន។ រីឯគ្រឿងម៉ាស៊ីនសម្រាប់កិនស្រូវក៏ប្រើការលែងកើត។ ដល់ចុងឆ្នាំ១៩៧១ ក្រុមខ្ញុំបានដឹងពីទីតាំងសម្រាករបស់កងទ័ពបដិវត្តន៍ស្ថិតនៅភូមិកន្ទ្រាំង ឃុំអង្ក្រោង ស្រុកសូទ្រនិគម ក៏រាយការណ៍ជូន ហោ ដើម្បីធ្វើសកម្មភាពហៅយន្តហោះមកទម្លាក់ម្តងទៀត។ លើកនេះគឺមានយន្តហោះចំនួន៥គ្រឿងបានមកទម្លាក់គ្រាប់បណ្តាលឱ្យមានស្លាប់ប្រជាជនចំនួន៧ នាក់ និងកងទ័ពស្លាប់ ១៥នាក់ និងឆេះមន្ទីរសេដ្ឋកិច្ចទាំងមូល។

ខែឧសភា ឆ្នាំ១៩៧២ ខ្ញុំបានចូលក្នុងកងបដិវត្តន៍មានតួនាទីជាយោធានៅក្នុងអង្គភាពអនុសេនាតូចទី៣ អនុសេនាធំទី២ វរសេនាតូច៩០០ របស់តំបន់៣៥ ភូមិ៣០៤។ ចូលក្នុងកងបដិវត្តន៍ ខ្ញុំបានស្គាល់ប្រធានកងអនុសេនាតូចឈ្មោះ ហៃ និង ប្រធានកងអនុសេនាធំឈ្មោះ សាង អតីតស្មៀនសាលាស្រុកជីក្រែង។ លេខាវរសេនាតូចឈ្មោះ ស៊ាន អតីតជាគ្រូបង្រៀន បច្ចុប្បន្នអនុលេខាតំបន់១០៦ ភូមិភាគឧត្តរ។ រីឯការទាក់ទងជាមួយខ្សែគិញ ហោ ខាងសៀមរាប និង ក្រុមខ្ញុំមានដូចជា រ៉ែម, ហេង, ឈិត, សួរ, ឡុន, ទិត, វឿន, ឌិម និង ឡុង ក៏ត្រូវដាច់ធ្វើសកម្មភាពលែងកើត។ មកដល់ចុងឆ្នាំ១៩៧២ សាង បានអប់រំខ្ញុំឱ្យចូលក្នុង សេ-អ៊ី-អា ដើម្បីចូលរួមធ្វើសកម្មភាពជាមួយ។

ដើមឆ្នាំ១៩៧៣ ស៊ាន បានចាត់តាំងខ្ញុំ ជាមួយឈ្មោះ ស្តើង អតីតជាប្រជាជនឱ្យទៅទាក់ទងជាមួយឈ្មោះ សត្យា មានតួនាទីជាស័ក្តិពីរ គិញប្រចាំនៅសៀមរាប ឱ្យយកទាហានមកកៀរប្រជាជនក្នុងភូមិទួលការហេរ ឃុំបាគង ស្រុកសូទ្រនិគម និងមួយទៀតឱ្យបញ្ជូនយន្តហោះមកទម្លាក់គ្រាប់បែកនៅមន្ទីរពេទ្យ៧៣ របស់តំបន់៣៥ ភូមិភាគ៣០៤។ ដល់ព្រឹកឡើងទាហានក៏ចេញមកកៀរប្រជាជនចំនួន២៥គ្រួសារ និងមានយន្តហោះចំនួន៥គ្រឿងធ្វើសកម្មភាពទម្លាក់គ្រាប់បែកលើមន្ទីរពេទ្យ ៧៣ បណ្តាលឱ្យមានទាហានពិការចំនួន២០នាក់ស្លាប់ និងបុគ្គលិកពេទ្យចំនួន២នាក់បានស្លាប់។

ដើមឆ្នាំ១៩៧៤ ខ្ញុំ, លី មានតួនាទីជាលេខាវរសេនាតូច និង អ៊ាម មានតួនាទីជាលេខាកងធំទី១ បានអប់រំយុទ្ធជនពីរនាក់បន្ថែមទៀត គឺមានឈ្មោះ នួន និង ថៃ។ ខ្លឹមសារអប់រំអ្នកទាំងពីរមានដូចជា មនុស្សម្នាក់ៗចង់បានសុភមង្គលក្នុងសង្គម និង ចង់មានសុភមង្គលសម្រាប់អនាគតខ្លួនឯងដែរ ហេតុនេះ

បើចង់បានសុភមង្គល គឺត្រូវតែចូលរួមជាមួយរបបសាធារណរដ្ឋខ្មែរ ដើម្បីធ្វើសកម្មភាពបំផ្លាញបដិវត្តន៍។ ដល់ការងារបានសម្រេចរដ្ឋនឹងផ្តល់ជាប្រាក់ខែ បុណ្យស័ក្តិ និង កិត្តិយសជាការតបស្នង។ ដល់ពាក់កណ្តាលឆ្នាំ១៩៧៤ លី បាននាំខ្ញុំទៅ ទាក់ទងជាមួយឈ្មោះ ឯក មានតួនាទីជាអនុប្រធានមន្ទីរចាត់ការឃ្លាំងរដ្ឋ, ប្រើយ មានតួនាទីជាអនុលេខាកងធំទី៣ វរសេនាតូច៧៥ និង ណាង មានតួនាទីជាប្រធានកងតូចទី៣ កងធំទី២ នៃវរសេនាតូច៧១ ដើម្បីបំផុសយុទ្ធជននៅតាមកងអង្គភាពចំនួន៣នាក់ឱ្យរត់ចូលទៅខេត្ត សៀមរាប។ ចំណែក សត្យាស័ក្តិ២ ត្រូវកងទ័ពបដិវត្តន៍ចាប់បាន និងបញ្ជូនទៅមន្ទីរសន្តិសុខតំបន់៣៥ ភូមិភាគ៣០៤។

ក្រោយថ្ងៃរំដោះបានទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ឈ្មោះ សាង មានតួនាទីជាវរសេនាតូច៧៦២ វរសេនាធំ កងពលទី២ ភូមិភាគ៣០៤ និងឈ្មោះ ស៊ុនួន ប្រធានរោងចក្រស្រាភ្នំពេញបានហៅក្រុមខ្សែសេ-អ៊ី-អា មកប្រជុំនៅវត្តទឹកល្អក់ ទួលគោក ដើម្បីដាក់ផែនការធ្វើសកម្មភាពបំផ្លាញបដិវត្តន៍ ដូចជា៖១) កម្ទេចកម្លាំងដឹកនាំបដិវត្តន៍សំខាន់ៗ ត្រូវរកវិធីស្របច្បាប់។ ២) បំផុសយុទ្ធជនកម្មាភិបាលឱ្យសេរី ភ្លើតភ្លើនទៅតាមជ័យជម្នះថ្មីៗ ដើម្បីងាយស្រួលអូសទាញ និង ៣) បន្តបំផ្លាញសម្ភារបដិវត្តន៍។

ឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៧ ក្រុមខ្ញុំនៅតែបន្តសកម្មភាពបំផ្លាញអង្គការតាមខ្សែរយៈផ្សេងៗ។ ចំណែកអង្គការក៏ចាប់បានខ្សែរយៈសេ-អ៊ី-អាជាបន្តបន្ទាប់។ ខ្ញុំនិង លីបានសម្រេចចិត្តហៅខ្សែរយៈសេ-អ៊ី-អា មកប្រជុំដើម្បីងាយស្រួលភ្ជាប់ខ្សែសង្វាក់ឡើងវិញ។ ក្នុងអង្គប្រជុំ លី គឺជាអ្នកទទួលខុសត្រូវចំពោះផែនការទៅថ្ងៃមុខ ចំណែកខ្ញុំជាអ្នកដឹកនាំធ្វើសកម្មភាពផ្ទាល់។ ដើមឆ្នាំ១៩៧៧ ខ្ញុំ, ស៊ិន់, សិទ្ធ និង ប្រើយ បានបំផ្លាញម៉ាស៊ីនបូកខ្យល់ម៉ាស៊ីនកិនស្រូវធំៗអស់២គ្រឿង។ បន្ទាប់មកបំផ្លាញរថយន្តចំនួន៤គ្រឿងដែលទុកដឹកសម្ភារនៅឃ្លាំង និងគ្រោងបំផ្លាញម៉ាស៊ីនសម្រាប់សម្រិតសម្រាំងអង្ករនាំចេញទៅក្រៅប្រទេស។ ដល់ថ្ងៃទី៦ ខែឧសភា ឆ្នាំ១៩៧៧ អង្គការបានចាប់ខ្ញុំ និងជាថ្ងៃដែលខ្ញុំត្រូវបញ្ចប់ផែនការក្បត់។



កម្មករបដិវត្តន៍ខ្មែរក្រហម នៅឃ្លាំងរដ្ឋក្នុងក្រុងភ្នំពេញ កំពុងជញ្ជូនផលិតផល ភួយ ចេញពីឃ្លាំងយកទៅដាក់កាណូត និងកប៉ាល់ ដើម្បីចែកជូនកសិករសហករណ៍ និងកងទ័ពបដិវត្តន៍ នៅសមរភូមិមុខ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មូលហេតុអ្វីបានរបបខ្មែរក្រហមដួលរលំ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩?

ឡុង ដានី



កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពស្ម័គ្រចិត្តវៀតណាម ចូលមកដល់ក្រុងភ្នំពេញ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បើយើងមើលត្រឡប់ទៅប្រវត្តិសាស្ត្រប្រទេសកម្ពុជាកាលពីឆ្នាំ៤៦មុនថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ គឺជាថ្ងៃដែលរបបប្រល័យពូជសាសន៍ខ្មែរក្រហមបានដួលរលំ និងបានសង្គ្រោះអាយុជីវិតប្រជាជនប្រមាណ៥លាននាក់ឱ្យរួចផុតពីរបបប្រល័យពូជសាសន៍ និងមានឱកាសកសាងប្រទេសជាតិពីបាតដៃទទេឱ្យមានការរីកចម្រើនដូចសព្វថ្ងៃ។ តើមានមូលហេតុអ្វីខ្លះដែលបណ្តាលឱ្យរបបខ្មែរក្រហមដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩?

យោងតាមសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) បោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ឆ្នាំ២០២០ ត្រង់ជំពូកទី១២ បាននិយាយថា **មានមូលហេតុយ៉ាងតិចមានចំនួន៣ចំណុច** ដែលបណ្តាលឱ្យរបបប្រល័យពូជសាសន៍ខ្មែរក្រហមដួលរលំបន្ទាប់ពីដឹកនាំប្រទេសបានរយៈពេលតែ៣ឆ្នាំ៨ខែ២០ថ្ងៃដូចខាងក្រោម៖

**ចំណុចទី១៖** ការដែលខ្មែរក្រហមបង្ខំឱ្យប្រជាជនធ្វើការងារពលកម្មតាមទីវាល និងធ្វើស្រែចម្ការលើសពី១០ម៉ោងក្នុងមួយថ្ងៃ និងមួយសប្តាហ៍៧ថ្ងៃ មិនមានអាហារហូបចុកគ្រប់គ្រាន់មិនមានទឹកស្អាតប្រើប្រាស់ និងកន្លែងស្នាក់នៅសមរម្យ។ ដោយសារតែលក្ខខណ្ឌរស់នៅរបស់ប្រជាជនយ៉ាប់យ៉ឺនខ្លាំងដូច្នេះ ទើបបណ្តាលឱ្យស្ថានភាពសុខភាពរបស់ប្រជាជនចុះទ្រុឌទ្រោមខ្លាំង និងមានប្រជាជនរាប់ម៉ឺនសែននាក់បានស្លាប់ជាបន្តបន្ទាប់។

**ចំណុចទី២៖** ការចោទប្រកាន់ប្រជាជន កម្មាភិបាល និងកងទ័ពខ្លួនឯងថាបានក្បត់អង្គការបដិវត្តន៍ខ្មែរក្រហមពីមួយថ្ងៃទៅមួយថ្ងៃកាន់តែច្រើនឡើងៗ។ ការចោទប្រកាន់ប្រជាជន កម្មាភិបាល និងកងទ័ពខ្លួនឯងថាបានក្បត់នេះ គឺមានតាំងពីខ្មែរក្រហមបានឡើងកាន់កាប់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ប៉ុល ពត និងថ្នាក់ដឹកនាំខ្មែរក្រហមផ្សេងៗទៀតបានជឿជាក់ថាការប៉ះបោរប្រឆាំងនឹងថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាកើតមានកាន់តែច្រើនឡើងៗនៅគ្រប់ទីកន្លែង ក្នុងចំណោមប្រជាជន គណៈភូមិភាគ គណៈតំបន់ គណៈស្រុក និងគណៈបញ្ជាការកងទ័ពជាច្រើនរូបត្រូវបានចាប់ខ្លួន និងសម្លាប់។ ជាពិសេសនៅពេលដែលកងទ័ពវៀតណាមវាយចូលភូមិភាគបូព៌ានៅចុងឆ្នាំ១៩៧៧ កម្មាភិបាល កងទ័ពខ្មែរក្រហមនៅភូមិភាគបូព៌ា និងប្រជាជនដែលរស់នៅភូមិភាគនេះត្រូវបានចោទប្រកាន់ថាបានចូលដៃចូលជើងជាមួយវៀតណាម ដែលបក្សកុម្មុយនីស្តកម្ពុជាចាត់ទុកមនុស្សនៅភូមិភាគបូព៌ាថាមនុស្ស ក្បាលយួន ខ្លួនខ្មែរ។ ប៉ុល ពត បានបញ្ជូនកងទ័ពមជ្ឈិមជាច្រើនទៅវាយប្រហារ និងចាប់ខ្លួនកម្មាភិបាល កងទ័ព និងសម្លាប់ប្រជាជនភូមិភាគបូព៌ារាប់ម៉ឺននាក់ ជាហេតុបណ្តាលឱ្យកម្មាភិបាល កងទ័ព និងប្រជាជនរាប់ម៉ឺននាក់រត់ចូលក្នុងព្រៃងើបឡើងបះបោរប្រឆាំងនឹងរបបខ្មែរក្រហមវិញ។ ចំណែកកម្មាភិបាល កងទ័ព និងប្រជាជនមួយចំនួនទៀតបានភៀសខ្លួនទៅប្រទេសវៀតណាម ដើម្បីកសាងកងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជា សហការជាមួយកងទ័ពវៀតណាមវាយចូលមកប្រទេសកម្ពុជានៅចុងឆ្នាំ១៩៧៨។

**ចំណុចទី៣៖** ការធ្វើសង្គ្រាមតាមព្រំដែនជាមួយប្រទេសវៀតណាម គឺជាមូលហេតុចម្បងបំផុតមួយដែលបណ្តាលឱ្យរបបខ្មែរក្រហមដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ បន្ទាប់ពីខ្មែរក្រហមបានឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានចាប់ផ្តើមបង្កបញ្ហានៅតាមព្រំដែនជាមួយប្រទេសវៀតណាមបណ្តើរ ទាំងដីគោក និងដែនកោះដែលខ្មែរក្រហមគិតជាអតីតទឹកខ្មែរត្រូវតែវាយដណ្តើមយកមកកាន់កាប់វិញ។ ជម្លោះរវាងខ្មែរក្រហម និងវៀតណាមបានរីករាលកាន់តែខ្លាំងនៅចុងឆ្នាំ១៩៧៨ នៅពេលដែលកងទ័ពខ្មែរក្រហមបានវាយចូលទៅភូមិមួយចំនួនក្នុងខេត្តតៃនីញ និងខេត្ត





កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពស្ម័គ្រចិត្តវៀតណាម ចូលមកដល់ក្រុងភ្នំពេញ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

អានយ៉ាងរបស់ប្រទេសវៀតណាមបានសម្លាប់ប្រជាជនស៊ីវិលវៀតណាមអស់រាប់រយនាក់។ បន្ទាប់មក វៀតណាមបានវាយចូលក្នុងខេត្តស្វាយរៀង និងតំបន់ត្រើយខាងកើតទន្លេមេគង្គនៃខេត្តកំពង់ចាមរយៈពេលប្រមាណមួយខែនៅចុងឆ្នាំ១៩៧៧។ បន្ទាប់មករបបខ្មែរក្រហមបានប្រកាសផ្តាច់ទំនាក់ទំនងការទូតទាំងស្រុងរវាងរបបខ្មែរក្រហម និងប្រទេសវៀតណាមនៅដើមឆ្នាំ១៩៧៨។ ខ្មែរក្រហមបានបដិសេធក្នុងការចរចាជាមួយប្រទេសវៀតណាម ខ្មែរក្រហមក៏បានបញ្ជូនកងទ័ពបន្ថែមទៅកាន់ព្រំដែនកម្ពុជា វៀតណាម។ កងទ័ពខ្មែរក្រហមដែលបញ្ជូនទៅធ្វើសង្គ្រាមតាមព្រំដែនជាមួយប្រទេសវៀតណាមបានកើនឡើងរហូតដល់ចំនួន១៩កងពល។

នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៧៨ ប្រទេសវៀតណាមបានបើកប្រតិបត្តិការជាទ្រង់ទ្រាយធំវាយចូលប្រទេសកម្ពុជា ដោយប្រើប្រាស់កងកម្លាំងរបស់អង្គភាពទ័ពលេខ២ លេខ៣ លេខ៤ យោធភូមិភាគទី៥ ទី៧ ទី៩ រួមជាមួយអង្គភាពទ័ពផ្សេងទៀតសហការជាមួយកងកម្លាំងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែលមានកងកម្លាំងសរុបប្រមាណ២០ម៉ឺននាក់។ កងទ័ពវៀតណាមបានប្រើប្រាស់រថពាសដែកប្រមាណ៦០០គ្រឿង កាំភ្លើងធំចំនួនប្រហែល ៤០០ដើម យន្តហោះដឹកសម្ភារសឹក ស្បៀងថ្នាំពេទ្យ និងយន្តហោះចម្បាំងចំនួន១៣៩គ្រឿង និងរថយន្តប្រមាណ១ម៉ឺនគ្រឿងទៀត ។

កងទ័ពវៀតណាមស្ថិតក្រោមការដឹកនាំរបស់ឧត្តមសេនីយ៍ វ៉ាន់ ទៀនយុង (Van Tien Dung) នាយអគ្គសេនាធិការកងទ័ពប្រជាជនវៀតណាម និងឧត្តមសេនីយ៍ ឡេ ចុង ទិន (Le Trong Tan) មេបញ្ជាការប្រចាំសមរភូមិក្នុងប្រទេសកម្ពុជា។ មុខព្រួញដែលកងទ័ពវៀតណាម និងកងកម្លាំងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាវាយចូលមកក្នុងប្រទេសកម្ពុជាមានដូចខាងក្រោម៖

**មុខព្រួញទី១៖** កងកម្លាំងរបស់យោធភូមិភាគទី៥ រួមមានកងពល៣០៧ កងពល៣០៩ និងកងពលតូចដាក់កុង១៩៨ និងអង្គភាពកងទ័ពផ្សេងទៀត ដឹកនាំដោយឧត្តមសេនីយ៍ ដ័ន ឃ្វេ (Doan Khue) មេបញ្ជាការយោធភូមិភាគទី៥ បានចាប់ផ្តើមដឹកនាំកងកម្លាំងចេញពីខេត្តកុនទុំ-យ៉ា ឡាយ វាយចូលតាមច្រកព្រំដែនអូរយ៉ាដាវ ខេត្តរតនគិរី និងបានកាន់កាប់ ខេត្តរតនគិរីទាំងស្រុងតាំងពីចុងខែធ្នូ ឆ្នាំ១៩៧៨។ នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៧៨ កងកម្លាំងរបស់យោធភូមិភាគទី៥ បានបន្តធ្វើដំណើរឆ្លងកាត់ទន្លេស្រែពកនឹងបែងចែកកម្លាំងជាពីរផ្នែក គឺមួយផ្នែកវាយចូលកាន់កាប់ខេត្តមណ្ឌលគិរី និងមួយផ្នែកទៀតវាយកាន់កាប់ខេត្តស្ទឹងត្រែង និងខេត្តព្រះវិហារ។

**មុខព្រួញទី២៖** នៅដើមខែធ្នូ ឆ្នាំ១៩៧៨ កងកម្លាំងយោធភូមិទី៧ រួមមានកងពលលេខ៥ កងពល៣០២ កងពល៣០៣ និងអង្គភាពកងទ័ពផ្សេងទៀត ដឹកនាំដោយ ឧត្តមសេនីយ៍ ឡេ ឌឹក អញ (Le Duc Anh) មេបញ្ជាការយោធភូមិភាគទី៧ បានចាប់ផ្តើមចេញពីខេត្តសុងប៊ែតាមផ្លូវជាតិលេខ១៣របស់វៀតណាម សហការជាមួយកងកម្លាំងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាមួយកងវរសេនាតូចបានវាយចូលតាមស្នួល ឆ្ពោះមកផ្លូវជាតិលេខ៧ ចូលកាន់កាប់ ស្រុកសំបូរ និងខេត្តក្រចេះនៅថ្ងៃទី២៩ ខែធ្នូឆ្នាំ១៩៧៨។ កងកម្លាំងយោធភូមិទី៧ បានបន្តឆ្លងទៅត្រើយខាងលិចទន្លេមេគង្គឆ្ពោះទៅខេត្តកំពង់ចាម កំពង់ធំ សៀមរាប និងបាត់ដំបង។

**មុខព្រួញទី៣៖** នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៨ អង្គភាពទ័ពលេខ៣រួមមានកងពលលេខ១០ កងពល៣១ កងពល៣២០ និងអង្គភាពកងទ័ពផ្សេងទៀត ដឹកនាំដោយ ឧត្តមសេនីយ៍ ង្វៀន គីមទន់ (Ngyuen Kim Toan) មេបញ្ជាការអង្គភាពទ័ពលេខ៣បានដឹកនាំកងកម្លាំងចេញដំណើរពីខេត្តតៃនីញ វាយចូលខេត្តកំពង់ចាមត្រើយខាងកើតទន្លេមេគង្គ (បច្ចុប្បន្នខេត្តត្បូងឃ្មុំ)។ បន្ទាប់មក កងម្លាំងអង្គភាពទ័ពទី៣ បានបែងចែកកម្លាំងជាពីរផ្នែក ដោយមួយផ្នែកវាយកាន់កាប់ខេត្តព្រៃវែង និងមួយផ្នែកទៀតបានបន្តមកទន្លេបិត ឆ្លងមកត្រើយខាងលិចទន្លេមេគង្គនៅថ្ងៃទី៣

*ខែមករា ឆ្នាំ១៩៧៩ ដើម្បីវាយចូលមកទីក្រុងភ្នំពេញ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។*

**មុខព្រួញទី៤៖** *នៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៩ អង្គភាពទ័ពលេខ៤ រួមមានកងពលលេខ៧ កងពលលេខ៩ កងពលលេខ៣៤១ និងអង្គភាពផ្សេងទៀត ដឹកនាំដោយឧត្តមសេនីយ៍ ហ័ង កឹម* (Hoang Cam) *មេបញ្ជាការអង្គភាពទ័ពលេខ៤ បានដឹកនាំកងទ័ពចេញដំណើរពីខេត្តតៃនីញ វាយចូលមកកាន់កាប់ខេត្តស្វាយរៀង។ បន្ទាប់មក កងទ័ពមួយផ្នែកទៀតបន្តតាមផ្លូវជាតិលេខ១ ឆ្ពោះទៅអ្នកលឿងនៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៩ និងឆ្លងទន្លេមេគង្គមកត្រើយខាងលិចបានវាយសម្រុកចូលមកកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។*

**មុខព្រួញទី៥៖** *នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៨ កងកម្លាំងយោធភូមិភាគទី៩ រួមមានកងពលលេខ៤ កងពលលេខ៣៣០ កងពល៣៣៩ និងអង្គភាពទ័ពផ្សេងទៀត ដឹកនាំដោយឧត្តមសេនីយ៍ ង្វៀន ចាញ់* (Nguyen Chanh) *មេបញ្ជាការយោធភូមិភាគទី៩ សហការជាមួយអង្គភាពទ័ពលេខ២ ( កងពល៣០៤ កងពល៣២៥ និងអង្គភាពកងទ័ពផ្សេងទៀត ) ដឹកនាំដោយឧត្តមសេនីយ៍ ង្វៀន ហ៊ីវ អាន* (Nguyen Huu An) *និងឧត្តមសេនីយ៍ ឡេ លីញ* (Le Linh) *ថ្នាក់ដឹកនាំអង្គភាពទ័ពលេខ២ បានដឹកនាំកងទ័ពចេញដំណើរពីខេត្តអានយ៉ាង វាយចូលមកកាន់កាប់ខេត្តតាកែវតាមផ្លូវជាតិលេខ២។ បន្ទាប់មក បានបន្តវាយតាមផ្លូវលេខ២ ចូលមកទីក្រុងភ្នំពេញ។ កងកម្លាំងយោធភូមិភាគទី៩ និងអង្គភាពទ័ពលេខ២ ក៏ជាកងកម្លាំងបម្រុងត្រៀមជួយអង្គភាពទ័ពលេខវាយចូលទីក្រុងភ្នំពេញ ក្នុងករណីជួបប្រទះនឹងឧបសគ្គខ្លាំង។ កងកម្លាំងយោធភូមិភាគទី៩ ក៏បានវាយចូលកាន់កាប់ខេត្តកំពត បន្តមកខេត្តកំពង់ស្ពឺ ខេត្តកោះកុង ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ និងផ្នែកខ្លះនៃខេត្តបាត់ដំបង។*

**មុខព្រួញទី៦៖** *កងទ័ពជើងទឹកនៃកងទ័ពប្រជាជនវៀតណាមរួមមានកងពលតូចលេខ១២៦ និងកងពលតូចលេខ១០១ បានចេញដំណើរតាមនាវាចម្បាំងជាច្រើនគ្រឿងពីស្រុកហាទៀង ខេត្តទៀងយ៉ាង វាយចូលមកកំពង់ផែរាម និងកំពង់ផែកំពង់សោម។*

*ក្នុងនោះក៏មានការជួយអន្តរាគមន៍កងទ័ពជើងអាកាសនៃកងទ័ពប្រជាជនវៀតណាមបានមកទម្លាក់គ្រាប់បែកនៅតាមសមរភូមិ តាមផ្លូវលេខ១ មកអ្នកលឿង និងការទម្លាក់គ្រាប់បែកនៅកំពង់ផែរាម និងកំពង់សោមជាដើម។ បើយោងតាមឯកសារសារព័ត៌មានវៀតណាមការប្រយុទ្ធគ្នាចន្លោះពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៧៨ ដល់ថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៩ មានកងទ័ពប្រជាជនវៀតណាមចំនួនប្រមាណ៣២០០នាក់ បានស្លាប់ និងរបួស ( ស្លាប់ប្រហែល១០០០នាក់ )។ ចំណែកកងទ័ពវៀតណាមរាប់រយនាក់ត្រូវបានកងទ័ពខ្មែរក្រហមចាប់បាន។*



*កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពស្ម័គ្រចិត្តវៀតណាម ចូលមកដល់ក្រុងភ្នំពេញ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។*
*( បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា )*

# ការស្លាប់របស់ ប៉ុល ពត និងការបែកបាក់របស់មេដឹកនាំខ្មែរក្រហម

សោម ប៊ុនថន



ប៉ុល ពត។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



សុន សេន។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ប៉ុល ពត កើតនៅខែមករា ឆ្នាំ១៩២៥ ត្រូវនឹងឆ្នាំឆ្លូវ នៅស្រុកស្ទោង ខេត្តកំពង់ធំ។ ប៉ុល ពត មានបងប្រុសឈ្មោះ សា ឡុត សេង, បងស្រីឈ្មោះ សា ឡុត រឿង និងប្អូនប្រុសឈ្មោះ សា ឡុត ញឹប។ នៅពេលដែល ប៉ុល ពត មានអាយុ៦ឆ្នាំ គាត់បានទៅរស់នៅជាមួយបងប្រុសដែលធ្វើការនៅក្នុងព្រះបរមរាជវាំង។ នៅទីក្រុងភ្នំពេញ ប៉ុល ពត បានសិក្សារៀនសូត្រនៅតាមសាលាបារាំងជាច្រើន ហើយបានបួសជាលោកនេន។

នៅឆ្នាំ១៩៤៩ ប៉ុល ពត បានទទួលអាហារូបករណ៍ទៅសិក្សានៅប្រទេសបារាំង ប៉ុន្តែមិនបានទទួលសញ្ញាបត្រអ្វីទេ។ ក្នុងអំឡុងពេលរៀនសូត្រនៅទីក្រុងប៉ារីស ប៉ុល ពត បានចូលជាសមាជិកបក្សកុម្មុយនិស្តបារាំង ហើយបានចំណាយពេលយ៉ាងច្រើនទៅលើសកម្មភាពនយោបាយ។

នៅឆ្នាំ១៩៥៣ ប៉ុល ពត បានត្រឡប់មកប្រទេស

កម្ពុជាវិញ និងធ្វើជាគ្រូបង្រៀនប្រវត្តិវិទ្យា និងភូមិវិទ្យា នៅសាលាឯកជនព្រមទាំងបានចូលរួមជាមួយចលនាកុម្មុយនីស្តខុសច្បាប់មួយ។ ប៉ុល ពត បានរៀបការជាមួយ ខៀវ ប៉ុណ្ណារី នៅឆ្នាំ១៩៥៦។ នៅឆ្នាំ១៩៦០ ប៉ុល ពត មានឋានៈទីបីនៅក្នុងបក្សពលករកម្ពុជា ហើយត្រូវបានតែងតាំងជាអនុលេខាបក្សទីពីរក្នុងឆ្នាំ១៩៦១។ ពីឆ្នាំក្រោយមក គឺនៅឆ្នាំ១៩៦៣ ប៉ុល ពតត្រូវបានតែងតាំងជាលេខាបក្សកុម្មុយនីស្តកម្ពុជា។ ប៉ុល ពត បានដឹកនាំកងទ័ពខ្មែរក្រហមធ្វើសង្គ្រាមប្រឆាំងជាមួយនឹងរបបសាធារណរដ្ឋខ្មែរដែលដឹកនាំដោយសេនាប្រមុខ លន់ នល់។

នៅឆ្នាំ១៩៧៦ ប៉ុល ពត គឺជានាយករដ្ឋមន្ត្រីនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយបានលាលែងពីតំណែងនៅឆ្នាំ១៩៧៩។ ទោះបីយ៉ាងដូច្នេះក៏ដោយ ប៉ុល ពត នៅតែជាមេដឹកនាំដ៏មានឥទ្ធិពលរបស់ខ្មែរក្រហមដដែល។ ប៉ុល ពតបាននិរទេសខ្លួន ហើយភាគច្រើនរស់នៅក្នុងទឹកដីប្រទេសថៃ។

ជម្លោះរវាង ប៉ុល ពត និង តាម៉ុក ចាប់ផ្តើមនៅពេលមានការផ្តាច់ខ្លួនរបស់កម្លាំងខុទ្ទាមខ្មែរក្រហមនៅប៉ៃលិន និង ម៉ាឡៃ។ ប៉ុល ពត ជឿជាក់ថា អៀង សារី, អ៊ី ឈាន និង សុខ ភាព អាចនឹងវិលត្រឡប់មកចូលរួមជាមួយចលនារបស់ខ្លួនវិញ។ នៅដើមខែតុលា ឆ្នាំ១៩៩៦ ប៉ុល ពត បានបញ្ជូឱ្យ តាម៉ុក និង នួន ជា ទៅដោះស្រាយបញ្ហាផ្តាច់ខ្លួននៅប៉ៃលិន និង ម៉ាឡៃ។

ទទួលបានបញ្ជាពី ប៉ុល ពត, តាម៉ុក និង នួន ជា បានធ្វើដំណើរទៅប៉ៃលិន ដោយពុំមានកងទ័ពទៅជាមួយឡើយ គឺមានតែអង្គរក្សពីរបីនាក់ប៉ុណ្ណោះដែលបានអមដំណើរ តាម៉ុក និង នួន ជា។ ប៉ុល ពត បានដឹងថា មេបញ្ជាការកងទ័ពរបស់ អៀង សារី បានកាន់កាប់សិទ្ធិកងទ័ពទាំងស្រុងនៅប៉ៃលិន។ ដូច្នេះ ប្រសិនបើជម្លោះកើតឡើង តាម៉ុក និង នួន ជា នឹងពិបាកក្នុងការវិលត្រឡប់មកវិញ។

តាម៉ុក និង នួន ជា មិនសម្រេចបានលទ្ធផលនៅក្នុងបេសកម្មនេះទេដែលបានធ្វើឱ្យប៉ុល ពត ខឹងសម្បារទៅវិញ។ តាម៉ុក និង នួន ជា មិនត្រឹមតែមិនអាចបញ្ចុះបញ្ចូលកម្លាំងខ្មែរក្រហមនៅប៉ៃលិន និង ម៉ាឡៃ ឱ្យវិលត្រឡប់មកវិញបាននោះទេ ថែមទាំងត្រូវបានបណ្តេញចេញពីតំបន់នោះថែមទៀតផង។ អ្នកទាំងពីរបានរត់មកសំឡូត ហើយបានជួបជាមួយ សុន សេន។ មេដឹកនាំទាំង៣រូប បានធ្វើដំណើរត្រឡប់មកអន្លង់វែងជាមួយគ្នាតាមប្រទេសថៃ។ កាលនោះ សម្តេចតេជោ ហ៊ុន សែន និងសម្តេចព្រះ នរោត្តម រណឫទ្ធិ បានស្នើសុំទៅអាជ្ញាធរថៃឱ្យចាប់ខ្លួនតាម៉ុក នួន ជា និង សុន សេន។ ប៉ុន្តែអាជ្ញាធរថៃមិនបានធ្វើតាមសំណើរនេះ ហើយ តាម៉ុក នួន ជា និង សុន សេន បានធ្វើដំណើរត្រឡប់មកអន្លង់វែងវិញដោយគ្មានឧបសគ្គអ្វីទាំងអស់។

ប៉ុល ពត បានធ្វើដំណើរមកជួបជាមួយ តាម៉ុក នៅពេលដែល តាម៉ុក មកដល់ផ្ទះរបស់គាត់នៅពើយតារូន លើខ្នងភ្នំដងរែក។ មេដឹកនាំទាំងពីរបានជួបគ្នាអស់រយៈពេលយ៉ាងយូរ និងបានឈ្លោះប្រកែកគ្នាខ្លាំងៗ។ ប៉ុល ពត បានចាប់ខ្លួន និងឃុំឃាំង តាម៉ុក, នួន ជា និង សុន សេន អស់រយៈពេល៦ខែ ចាប់ពីខែតុលា ឆ្នាំ១៩៩៦ ដល់ខែកុម្ភៈ ឆ្នាំ១៩៩៧។ ប៉ុល ពត ឃុំឃាំងមេដឹកនាំខ្មែរក្រហមទាំងបីរូបនៅក្នុងបន្ទប់ងងឹត និងមិនត្រូវបានអនុញ្ញាតឱ្យដើរទៅណាឡើយ។

ទោះបីជា ប៉ុល ពត ឃុំឃាំងមេដឹកនាំជាន់ខ្ពស់ទាំងបីយ៉ាងស្ងៀមស្ងាត់ ប៉ុន្តែ ប៉ុល ពត មិនបានសម្លាប់មេដឹកនាំទាំងនោះទេ ព្រោះអាចនឹងបង្កឱ្យមានជម្លោះ។ ផ្ទុយទៅវិញ ប៉ុល ពតបានជ្រើសរើសការដកហូតការគាំទ្រ ជាពិសេសពី តាម៉ុក ដោយបានស្នើឱ្យមានការផ្លាស់ប្តូរថ្នាក់ដឹកនាំនៅអន្លង់វែង។ ប៉ុល ពត បានស្នើថា គ្រប់មេដឹកនាំខ្មែរក្រហមដែលមានវ័យចំណាស់ទាំងអស់ ដែលរួមទាំង តាម៉ុក និង ខ្លួនគាត់ផងត្រូវចូលនិវត្តន៍ និងទុកឱកាសឱ្យអ្នកដឹកនាំជំនាន់ក្រោយបន្តការតស៊ូ។ មេដឹកនាំចាស់ទាំងអស់នឹងធ្វើជាទីប្រឹក្សារបស់ចលនានេះ។

នៅខែកុម្ភៈ ឆ្នាំ១៩៩៧ ប៉ុល ពត បានរៀបចំ

មហាសន្និបាតមួយ ដែលមានអ្នកចូលរួមប្រមាណ ៤០០នាក់ ដែលភាគច្រើនគឺជាមេបញ្ជាការកងទ័ព។ គោលបំណងនៃមហាសន្និបាតនេះ គឺការពិភាក្សាអំពីការផ្ទេរអំណាចពីមេដឹកនាំចាស់ៗទៅអ្នកជំនាន់ថ្មីៗ ការផ្ទេរអំណាចនឹងធ្វើឡើងតាមរយៈការបោះឆ្នោត។ បេក្ខជន១០រូបត្រូវបានជ្រើសរើសឱ្យឈរឈ្មោះសម្រាប់ការបោះឆ្នោតផ្ទេរអំណាចនេះ ហើយអ្នកដែលចូលរួមមានឈ្មោះ សូ សារឿន, មៀច សាន, ទឹម ឆុន, ញាន, ហឿន និង ខន។ មៀច សាន ដែលជាមេបញ្ជាការស្និទ្ធនឹង ប៉ុល ពត ទទួលសំឡេងគាំទ្រច្រើនជាងគេ។ ទោះជាយ៉ាងនេះក្តី មៀច សាន បានសម្រេចចិត្តមិនប្រកួតប្រជែងជាមួយ សូ សារឿន ដែលជាអតីតមេបញ្ជាការរបស់គាត់ និងដែលបានចូលបម្រើបដិវត្តន៍មុនគាត់។ មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមបានពិភាក្សាគ្នា និងបានសម្រេចថា សូ សារឿន គឺជាមេដឹកនាំជំនាន់ថ្មីរបស់ចលនាខ្មែរក្រហម។ ប៉ុន្តែ តាម៉ុក ចង់ឱ្យ ទឹម ឆុន ដែលជាមេបញ្ជាការស្និទ្ធនឹងគាត់ធ្វើជាមេដឹកនាំវិញ។



តា ម៉ុក។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បន្ទាប់ពីការបោះឆ្នោតនៅក្នុងមហាសន្និបាតរួចមក ប៉ុល ពត បានបង្កើតគណៈកម្មាធិការមួយដែលមានសមាជិក១០នាក់។ គណៈកម្មាធិការនោះមានឈ្មោះថា«គណៈកម្មាធិការ១៩»ដែលដឹកនាំដោយ សូ សារឿន ដែលបានក្លាយទៅជាអគ្គមេបញ្ជាការកងទ័ពនៅតំបន់អន្លង់វែង។ ទីបញ្ជាការរបស់ សូ សារឿន មានទីតាំងនៅឃុំព្រះប្រឡាយ ស្រុកត្រពាំងប្រាសាទ។ ចំណែកមេទ័ពខ្លាំងៗដែលស្និទ្ធនឹង តាម៉ុក ត្រូវបានដកហូតសិទ្ធិ និងកងទ័ព ហើយត្រូវបានតែងតាំងឱ្យកាន់ការងាររដ្ឋបាលជំនួសវិញ។ តាម៉ុក បានប្រឆាំងគំនិតផ្តួចផ្តើមនេះ។ តាម៉ុក យល់ឃើញថាកិច្ចការទាំងអស់នេះគឺជាយុទ្ធសាស្ត្ររបស់ ប៉ុល ពត ក្នុងការប្រមូលផ្តុំអំណាចនៅអន្លង់វែង។

នៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ១៩៩៧ សុន សេន ដែលជាជនបដិវត្តន៍ដ៏យូរឆ្នាំមួយរូបរបស់ ប៉ុល ពត ត្រូវបានសម្លាប់យ៉ាងព្រៃផ្សៃ។ ជាងនេះទៅទៀត សមាជិកគ្រួសារចំនួន១០នាក់ទៀត ដែលរួមមាន យ៉ុន យ៉ាត ប្រពន្ធរបស់ សុន សេន និងជារដ្ឋមន្ត្រីក្រសួងវប្បធម៌ អប់រំ និងសិក្សាជាតិ ព្រមទាំងកូនស្រីពីរនាក់ ចៅប្រុសអាយុ៥ឆ្នាំម្នាក់ អ្នកបើករថយន្តម្នាក់ និងនីសារម្នាក់ត្រូវបានសម្លាប់ចោលទាំងអស់។ នៅយប់នៃការសម្លាប់ សុន សេន គឺ ប៉ុល ពត បានសុំឱ្យមានការប្រជុំជាមួយ សុន សេន។ ប៉ុន្តែ សុន សេន និង យ៉ុន យ៉ាត បានបដិសេធការប្រជុំនោះ ដោយបានប្រាប់ទៅនីសារថា យប់ជ្រៅពេក ហើយសុំពន្យារពេលប្រជុំទៅព្រឹកនៃថ្ងៃបន្ទាប់។ ប៉ុល ពត បានបញ្ជាឱ្យមេទ័ពរបស់គាត់ សូ សារឿន សម្លាប់ សុន សេន និងប្រពន្ធដែលកំពុងស្នាក់នៅក្នុងផ្ទះដែល តាម៉ុក សង់ឱ្យនៅក្បែរពើយតារូន។ ប៉ុន្តែ សូ សារឿន បានអនុវត្តលើសពីបញ្ជារបស់ ប៉ុល ពត ដោយសម្លាប់សាច់ញាតិរបស់ សុន សេន ចោលទាំងអស់។

បន្ទាប់ពីទទួលដំណឹងអំពីការស្លាប់របស់ សុន សេន តាម៉ុក បានធ្វើការសន្និដ្ឋានថា ប៉ុល ពត មានបំណងចង់សម្លាប់គាត់នៅក្នុងការធ្វើបន្សុទ្ធកម្មរួម។

តាម៉ុក ខឹងនឹង ប៉ុល ពត និង សូ សារឿន យ៉ាងខ្លាំង និងបានកោះប្រជុំបន្ទាន់មួយជាមួយមេបញ្ជាការកងទ័ពនៅផ្ទះរបស់គាត់ក្បែរមាត់ទឹក។ តាម៉ុក បានប្រាប់ទៅមេទ័ពទាំងអស់ថា ប៉ុល ពត និង សូ សារឿន មានបំណងចង់សម្លាប់គាត់ និងចង់ធ្វើជាស្តេចនៅអន្លង់វែង។ តាម៉ុក ប្រាប់មេទ័ពរបស់គាត់ឱ្យត្រៀមខ្លួនធ្វើសង្គ្រាមជាមួយ ប៉ុល ពត។

នៅយប់ថ្ងៃទី៩ ខែមិថុនា ឆ្នាំ១៩៩៧ តាម៉ុក បានបញ្ជាឱ្យប្រមូលផ្តុំកម្លាំងទាំងអស់ដើម្បីវាយដណ្តើមយកសាកសពរបស់ សុន សេន និងក្រុមគ្រួសារដែលក្រោយមករូបថតរបស់សាកសពទាំងនោះត្រូវបានប្រើប្រាស់សម្រាប់ធ្វើការឃោសនា។ នៅវេលាម៉ោង៧ព្រឹក ថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៧ តាម៉ុក និងកងកម្លាំងរបស់គាត់បានផ្សព្វផ្សាយការសម្លាប់របស់ សុន សេន ជាសាធារណៈដើម្បីប្រមូលការគាំទ្រពីកងទ័ព និងប្រជាជន។ ជាមួយនឹងរូបថតសាកសពរបស់ សុន សេន ជាភស្តុតាង តាម៉ុក បានអំពាវនាវដល់ប្រជាជនឱ្យចូលរួមជាមួយគាត់ ដើម្បីធ្វើការតស៊ូប្រឆាំងនឹង ប៉ុល ពត។

តាម៉ុក បានបញ្ជាឱ្យកងពល៩៨០ និងកងពល៩១២ ចាប់ខ្លួន ប៉ុល ពត និងបក្ខពួក។ ឡុង ទេម, សាន់ គង់, ឃឹម ដាន់ណា, ឃឹម ពឹម និង ម៉ុន ត្រូវបានចាត់តាំងឱ្យទទួលខុសត្រូវក្នុងការដឹកនាំកម្លាំងរបស់ តាម៉ុក ប្រយុទ្ធជាមួយនឹងកម្លាំងរបស់ ប៉ុល ពត ដែលរួមមានកងពល ៨០១ របស់ សូ សារឿន និងកងពល៩២០ របស់ មៀច សាន។

ឆ្លើយតបទៅនឹងការឃោសនារបស់ តាម៉ុក ប៉ុល ពត បានវាយប្រហារ តាម៉ុក តាមវិទ្យុ។ ប៉ុល ពត បានចោទប្រកាន់កងកម្លាំងរបស់ តាម៉ុក ថាក្បត់ជាតិ។ ខៀវ សំផន ក៏បានចូលរួមនៅក្នុងជម្លោះនោះដែរ។ នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៩៧ ខៀវ សំផន បានអានសេចក្តីប្រកាសរបស់ ប៉ុល ពត តាមវិទ្យុដោយចោទ សុន សេន ថាជាភ្នាក់ងារស៊ើបការណ៍សម្ងាត់របស់ «រដ្ឋាភិបាលអាយ៉ងយួន» នៅទីក្រុងភ្នំពេញ។

បន្ទាប់ពីមានការប្រយុទ្ធគ្នាអស់រយៈពេល៥ថ្ងៃ ប៉ុល ពត បានបញ្ជាឱ្យ សូ សារឿន, មៀច សាន និងមេបញ្ជាការដែលស្មោះត្រង់នឹងខ្លួនទម្លាក់អាវុធ ហើយចរចាជាមួយ តាម៉ុក។ ប៉ុល ពត មានបំណងបញ្ចុះបញ្ចូល តាម៉ុក ឱ្យបញ្ចប់ការប្រយុទ្ធគ្នា ដោយសារតែ ប៉ុល ពត យល់ឃើញថា បើនៅបន្តប្រយុទ្ធតទៅទៀត «សត្រូវនឹងទទួលបានផលប្រយោជន៍កាន់តែច្រើន»។ ម្យ៉ាងទៀត ទោះបី ប៉ុល ពត ទទួលបានភក្តីភាពពីមេទ័ពក៏ដោយ ក៏ ប៉ុល ពត ពុំមានធនធានសេដ្ឋកិច្ចគ្រប់គ្រាន់ក្នុងការបន្តប្រយុទ្ធបានដែរ។

តាម៉ុក បានចាប់ខ្លួន សូ សារឿន និងប្រពន្ធ, មៀច សាន និងកូនប្រុស មៀច សាវ៉ារុធ ព្រមទាំងមេបញ្ជាការកងទ័ពមួយចំនួនទៀតដូចជា ឃន, ង៉ួន, សែន និង ខេមរា ដែលសុទ្ធតែជាអ្នកស្មោះត្រង់នឹង ប៉ុល ពត។ ពីខែក្រោយមក សូ សារឿន និងប្រពន្ធ និង មៀច សាន ត្រូវបានកាត់ទោសប្រហារជីវិត។

ដោយឡែក ប៉ុល ពត, ខៀវ សំផន, នួន ជា, ដួន ជឿន, ចាន់ យូរ៉ាន់, ទេព ឃុនណាល់ ព្រមទាំងទីប្រឹក្សា និងអ្នកនៅក្រោមបង្គាប់មួយចំនួនបានរត់គេចពីកងទ័ពរបស់ តាម៉ុក ទៅលាក់ខ្លួននៅក្នុងរូងភ្នំនៅឃុំអូរស្វាយ ស្រុកត្រពាំងប្រាសាទ។

នៅទីបញ្ចប់ ប៉ុល ពត ត្រូវបានកងទ័ពរបស់ តាម៉ុក ចាប់ខ្លួននៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ១៩៩៧។ កងទ័ព បានយកអង្រឹងសែង ប៉ុល ពត ចំណែកមេដឹកនាំដទៃទៀតបានដើរត្រឡប់មកវិញ។ កងទ័ពរបស់ តាម៉ុក បានឃុំឃាំងមេដឹកនាំខ្មែរក្រហមនៅឃ្លាំងកណ្តាល ក្រោយមកបានបញ្ជូនទៅឃុំឃាំងនៅក្បែរច្រកព្រំដែនជាំសាង៉ាំ។

នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៧ ប៉ុល ពត ត្រូវបាននាំមកកាត់ទោសនៅចំពោះមុខ «តុលាការប្រជាជន» ដែលមានប្រជាជននៅអន្លង់វែងប្រមាណ ៤០០ទៅ៥០០នាក់បានចូលរួម។ មេបញ្ជាការកងទ័ពជាន់ខ្ពស់ និងមេដឹកនាំស៊ីវិលចំនួនបួននាក់ ដែលស្មោះត្រង់នឹង តាម៉ុក ត្រូវបានជ្រើសរើសឱ្យធ្វើជាអង្គជំនុំជម្រះដែលរួមមាន ខៀវ នៅ តំណាងឱ្យ

ប្រជាជន, ខៀវ សំផន តំណាងឱ្យកងកម្លាំងប្រដាប់អាវុធ, ម៉ក់ ប៉េន និង ទេព ឃុនណាល់ តំណាងឱ្យបញ្ញវន្តៗ នៅទីបញ្ចប់ ខៀវ នៅ បានប្រកាសសាលក្រមដោយបានដាក់ទោស ប៉ុល ពត ឱ្យជាប់ពន្ធនាគារអស់មួយជីវិតពីបទឧក្រិដ្ឋ «សម្លាប់ សុន សេន ការប៉ុនប៉ងសម្លាប់ តាម៉ុក និងការបំផ្លិចបំផ្លាញកិច្ចខិតខំប្រឹងប្រែងផ្សះផ្សាជាតិៗ

ប៉ុល ពត ត្រូវបានឃុំឃាំងរហូតដល់ថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៩៨ ទើបស្លាប់ដោយសារជំងឺបេះដូង នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យៗ សាកសពរបស់ ប៉ុល ពត ត្រូវបានបូជា នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៩៨ៗ

មានហេតុផលជាច្រើនសម្រាប់ការបែកបាក់និងជម្លោះជាយថាហេតុដែលកើតឡើងនៅក្នុងថ្ងៃចុងក្រោយនៃចលនាខ្មែរក្រហមៗ ការសម្រេចចិត្តថាតើត្រូវចូលរួមក្នុងការបោះឆ្នោតឆ្នាំ១៩៩៣ បានបង្កើតភាពតានតឹងក្នុងចំណោមមេដឹកនាំខ្មែរក្រហមៗ ប៉ុល ពត ប្រកាន់ខ្ជាប់នូវជំនឿថា កងកម្លាំង និងចារកម្មវៀតណាមបានចូលកាន់កាប់ក្នុងជួរនៃការគ្រប់គ្រងរដ្ឋកម្ពុជាៗ លើសពីនេះ ប៉ុល ពត បានបន្តមានជំនឿថា ខ្មែរក្រហមអាចយកឈ្នះប្រទេសកម្ពុជាម្តងទៀតៗ ទស្សនះរបស់ ប៉ុល ពត មិនអាចលើសពីការពិតបានទេៗ ស្ទើរតែភ្លាមៗនៅពេលដែលវៀតណាមបានបញ្ចប់ការដកទ័ពចុងក្រោយពីកម្ពុជា ក្នុងឆ្នាំ១៩៨៩នោះ ទីតាំងយុទ្ធសាស្ត្រនៅសមរភូមិ (ឬចំណុចកណ្តាលនៃការស្រូបទាញ) លើអនាគតរបស់កម្ពុជាបានផ្លាស់ប្តូរពីកងទ័ពទៅកាន់ឆាកនយោបាយ ដែលសម្តេចតេជោ ហ៊ុន សែន បានយល់យ៉ាងច្បាស់អំពីសភាពការណ៍នេះៗ



មេដឹកនាំខ្មែរក្រហមរង់ចាំទទួលគណៈប្រតិភូបរទេសនៅព្រលានយន្តហោះពោធិ៍ចិនតុងៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលឯកសារកម្ពុជា ដំឡើងស្លាកសញ្ញាបង្ហាញផ្លូវ និងស្លាកឈ្មោះ «ព្រះរាជបណ្ណាល័យហ្លួងម៉ែ»

*មីន សាណាស់*




ក្រុមជាងកំពុងដំឡើងស្លាកសញ្ញាបង្ហាញផ្លូវ និងស្លាកឈ្មោះ «ព្រះរាជបណ្ណាល័យ ហ្លួងម៉ែ»។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្រសួងមហាផ្ទៃ និងសាលារាជធានីភ្នំពេញ នៅថ្ងៃទី៦ ខែមករា ឆ្នាំ២០២៥ បានអនុញ្ញាតឱ្យមជ្ឈមណ្ឌលឯកសារកម្ពុជា រៀបចំលើកស្លាកសញ្ញាបង្ហាញផ្លូវ និងស្លាកឈ្មោះ **«ព្រះរាជបណ្ណាល័យហ្លួងម៉ែ»** នៅតាមបណ្តោយមហាវិថីព្រះសីហនុ, មហាវិថីព្រះនរោត្តម, មហាវិថីប៉ាស្ទ័រ, មហាវិថីកែន្ទូ, មហាវិថីសម្តេចសុធារស, មហាវិថីសុរាម្រិត, មហាវិថីព្រះអង្គយុគន្ធរ និងមហាវិថីខកញ៉ាឈុន ដើម្បីបង្កលក្ខណៈងាយស្រួលដល់ភ្ញៀវជាតិ និង អន្តរជាតិក្នុងការស្វែងរកទីតាំង **«ព្រះរាជបណ្ណាល័យហ្លួងម៉ែ»**។

**«ព្រះរាជបណ្ណាល័យហ្លួងម៉ែ»** ត្រូវបានបង្កើតឡើងជាផ្លូវការដោយមជ្ឈមណ្ឌលឯកសារកម្ពុជា

នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០ ដើម្បីជាព្រះរាជកិត្តិយសជាទីគោរពសក្ការៈដ៏ខ្ពស់ខ្ពង់បំផុតថ្វាយ សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និង សុភមង្គល ដែលទ្រង់បានខិតខំយកអស់ព្រះកាយពលដើម្បី សម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ អតីតព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ ប្រទេសជាតិកម្ពុជា និង ប្រជាជនកម្ពុជា។

«**ព្រះរាជបណ្ណាល័យហ្លួងម៉ែ**» ដើរតួយ៉ាងសំខាន់សម្រាប់ដាក់តាំងពិព័រណ៍ព្រះឆាយាលក្ខណ៍ និង ស្នាព្រះហស្តរបស់ សម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ អតីតព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ ឯកសារស្រាវជ្រាវ ផ្សព្វផ្សាយ និង ឯកសារផ្សេងៗជាច្រើនទៀត ដែលអនុញ្ញាតឱ្យភ្ញៀវជាតិ និង អន្តរជាតិអាចចូលអាន និងសិក្សាស្រាវជ្រាវអំពីប្រវត្តិសាស្ត្រប្រទេសកម្ពុជា។







ក្រុមជាងកំពុងដំឡើងស្លាកសញ្ញាបង្ហាញផ្លូវ និងស្លាកឈ្មោះ «ព្រះរាជបណ្ណាល័យ ហ្លួងម៉ែ»។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ព្រះរាជទាន

## សៀវភៅឯកសារ២៩មុខ ជូន អគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ)

*មីន សាណាស់*



អ្នកស្រី សូ ហ្វារីណា នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា និងលោក រស់ សំពៅ ប្រធាន «ព្រះរាជបណ្ណាល័យ ហ្វូង់ម៉ែ» ទទួលព្រះរាជអំណោយឯកសារ២៩មុខ ពីសម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ យកទៅតម្កល់ទុកនៅអគារមរតកសង្គមរាស្ត្រនិយមសម្តេចឪ សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) សម្រាប់សាធារណជនអាន និងសិក្សាស្រាវជ្រាវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នាព្រឹកថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៤ សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ បានសព្វព្រះរាជហឫទ័យព្រះរាជទាននូវសៀវភៅឯកសារដែលជាស្នាព្រះហស្ត ជាប្រវត្តិសាស្ត្រព្រះរាជជីវប្រវត្តិ ព្រះរាជសកម្មភាពនយោបាយ ការកសាងសមិទ្ធផលផ្សេងៗតាំងពីសម័យ សង្គមរាស្ត្រនិយម និងបច្ចុប្បន្នរបស់ ព្រះករុណាព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ ព្រះបរមរតនកោដ្ឋ នៃប្រជាជាតិខ្មែរ និង សម្តេចព្រះមហាក្សត្រីព្រះវររាជមាតាជាតិខ្មែរ ជូនដល់«អគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ)» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា និង ព្រះរាជបណ្ណាល័យ

ហ្លួងម៉ែ។ គោលបំណងនៃព្រះរាជទាន គឺដើម្បីសិក្សាយល់ដឹង ធ្វើការស្រាវជ្រាវ និងជាឯកសារដ៏មានសារសំខាន់ប្រកបដោយឧត្តមប្រយោជន៍ជាតិខ្មែរ។

គួររំឭកថា នៅក្នុងឆ្នាំ២០១៩ ដោយសារព្រះទ័យសប្បុរស និងគាំទ្ររបស់ ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ភូមិអូរស្វាយបានលេចត្រដែតឡើងវិញ ដោយមានការសាងសង់សាលារៀន មន្ទីរពេទ្យ និងបន្ទប់ទឹកសាធារណៈ។ ឆ្នាំនេះគឺឆ្នាំ២០២៤ ភូមិដ៏តូចនេះនឹងរំឭកឡើងវិញកាលពី៦០ឆ្នាំមុន នៃការយាងមកដល់របស់ ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ «**ព្រះបរមរតនកោដ្ឋ**» មកកាន់ភូមិអូរស្វាយ (បច្ចុប្បន្នមានឈ្មោះថា ស្រុកបុរីអូរស្វាយ-សែនជ័យ) ហើយដែលមជ្ឈមណ្ឌលឯកសារកម្ពុជា មានមោទកភាពបានចូលរួមចំណែកក្នុងការស្តារមកវិញនូវមរតករបស់ ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ «**ព្រះបរមរតនកោដ្ឋ**» ដោយបានសាងសង់ព្រះរាជដំណាក់តូច ជាបណ្ណាល័យ, សាងសង់កំពង់ផែជាច្រើន, ការរៀបចំឡើងវិញនូវដងទន្លេមេគង្គ និងការសាងសង់ទូកថ្មីជាច្រើនគ្រឿងដែលទាំងអស់នេះគឺសម្រាប់ប្រើប្រាស់ជាសាធារណៈ។ គ្រឿងបរិក្ខារ និងមធ្យោបាយធ្វើដំណើរតាមទូកថ្មីមានសារសំខាន់ណាស់ក្នុងការពង្រឹងសហគមន៍ឡើងវិញដែលលាតសន្ធឹងក្នុងចំណោមកោះទាំង៦។ ប្រវត្តិសាស្ត្របរិស្ថាន និងបេតិកភណ្ឌវប្បធម៌ក្នុងតំបន់បុរីអូរស្វាយ-សែនជ័យ គឺជាធនធានដែលមិនអាចកាត់ថ្លៃបានដែលត្រូវតែថែរក្សា និងការពារសម្រាប់មនុស្សជំនាន់ក្រោយ។

**អគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ)** ដែលជាសាខាមួយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានចាប់ផ្តើមសាងសង់នៅពាក់កណ្តាលឆ្នាំ២០២៤ និងទទួលសាធារណជនអ្នកស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៤។ មជ្ឈមណ្ឌលឯកសារកម្ពុជា និងចាប់ដំណើរការដំណាក់កាលបន្ទាប់នៃកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួននៅឆ្នាំ២០២៥ ដែលនឹងរួមបញ្ចូលក្នុងចំណោមសកម្មភាពជាច្រើនផ្សេងទៀតរួមមានការស្រាវជ្រាវប្រវត្តិសាស្ត្ររបស់សហគមន៍ សិល្បៈចម្លាក់ និងការកែលម្អបន្ថែមទៀតដល់ការិយាល័យ និងសហគមន៍ជុំវិញ។



«ព្រះរាជបណ្ណាល័យ ហ្លួងម៉ែ» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

**ព្រះរាជខុទ្ទកាល័យ**
**សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតា**
**នរោត្តម មុនិនាថ សីហនុ**
**នៃព្រះរាជាណាចក្រកម្ពុជា**

ជូន លោក **ឆាំង យុ**
នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា
និងព្រះរាជបណ្ណាល័យ **ហ្លួងម៉ែ**

លោកនាយក ជាទីរាប់អាន

នាងខ្ញុំ មានកិត្តិយសសូមជំរាបជូនជ្រាបថា **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សព្វព្រះរាជហឫទ័យព្រះរាជទាន នូវសៀវភៅឯកសារដែលជាស្នាព្រះហស្ត ជាប្រវត្តិសាស្ត្រព្រះរាជជីវប្រវត្តិ ព្រះរាជសកម្មភាព ព្រះរាជនយោបាយ ការកសាងសមិទ្ធិផលផ្សេងៗតាំងពីសម័យសង្គមរាស្ត្រនិយម និងបច្ចុប្បន្នរបស់ **ព្រះករុណាព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ ព្រះបរមរតនកោដ្ឋ** នៃប្រជាជាតិខ្មែរ និង**សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះរាជទានរក្សាទុកនៅក្នុង "**អគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ-បុរីអូរស្វាយ សែនជ័យ ស្ទឹងត្រែង**" ដើម្បីសិក្សាយល់ដឹង ធ្វើការស្រាវជ្រាវ និងជាឯកសារដ៏មានសារៈសំខាន់ប្រកបដោយឧត្តមប្រយោជន៍ជាតិខ្មែរ ។

នាងខ្ញុំ សូមភ្ជាប់ជាមួយនូវបញ្ជីឈ្មោះសៀវភៅមានចំនួន ២៩ឯកសារ ។

សូម លោកនាយក បានប្រកបតែនឹងព្រះពុទ្ធពរគ្រប់ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងទទួលនូវសេចក្តីរាប់អាន អំពីខ្ញុំ ។

នាយព្រះរាជខុទ្ទកាល័យ
តាន់ ម៉េងហួយ
Menghuoy

ភ្នំពេញ ថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០២៤

# យុវតីមកពីសហគមន៍ចាម នៅភូមិចុងខ្នង ខេត្តពោធិ៍សាត់ ជាប់អាហារូបករណ៍ខាងផ្នែកតែងនិពន្ធ

*សូ ហ្វារីណា*



កញ្ញា សារ៉ៃ ហ៊ីគីន (រូបទី៤ រាប់ពីស្តាំ) នៅក្នុងពិធីទទួលបានអាហារូបករណ៍ផ្នែកតែងនិពន្ធពីលោកជំទាវ ខៀវ ម៉ាលី (រូបទី៧ រាប់ពីស្តាំ) ដែលជាស្ថាបនិកសមាគម សុខ ខៀវសមិទ្ធិ ដើម្បីសិល្បៈ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

កាលពីព្រឹកថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៥ សារ៉ៃ ហ៊ីគីន ដែលជាអ្នកស្ម័គ្រចិត្តកម្ពុជា នៃមជ្ឈមណ្ឌលឯកសារកម្ពុជា និងព្រះរាជបណ្ណាល័យហ្វូងម៉ែ បានទទួលអាហារូបករណ៍សិក្សាផ្នែកតែងនិពន្ធ នៅសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ក្នុងចំណោមនិស្សិត៧ នាក់ផ្សេងទៀត។ អាហារូបករណ៍នេះឧបត្ថម្ភដោយ លោកជំទាវ ខៀវ ម៉ាលី ដែលជាស្ថាបនិកសមាគម សុខ ខៀវសមិទ្ធិ ដើម្បីសិល្បៈ សម្រាប់បង់ថ្លៃសិក្សារយៈពេល៤ឆ្នាំ។ តាមរយៈរូបថតចំនួនពីរសន្លឹកនេះបង្ហាញថា រ៉ៃហ៊ីគីន មានសេចក្តីរំភើបរីករាយ ដែលទទួលបានអាហារូបករណ៍នេះ។

បច្ចុប្បន្ន សារ៉ៃ ហ៊ីគីន មានអាយុ២២ឆ្នាំ ជាកូនទី៦ក្នុងចំណោមបងប្អូន៧ នាក់។ រ៉ៃហ៊ីគីន មានស្រុកកំណើតនៅភូមិចុងខ្នង ឃុំអូរសណ្តាន់ ស្រុកក្រគរ ខេត្តពោធិ៍សាត់។ ភូមិចុងខ្នងមានចម្ងាយប្រមាណ ១៧៤គីឡូម៉ែត្រពីទីក្រុងភ្នំពេញ ហើយភូមិនេះ គឺជាភូមិចំណាស់មួយដែលមានប្រជាជនជាអ្នកគោរពប្រណិប័តន៍សាសនាអ៊ិស្លាមចំនួន៣៨៤គ្រួសារ។ រ៉ៃហ៊ីគីន ធ្លាប់ទទួលបានបរិញ្ញាបត្រវផ្នែកអគ្គិសនី

និងបានចូលបម្រើការងារខាងផ្នែកអគ្គិសនី ខណៈពេលកំពុងសិក្សា ដើម្បីទទួលបានប្រាក់ចំណូលខ្លះសម្រាប់ផ្គត់ផ្គង់ការសិក្សា និងក្រុមគ្រួសារនៅឯភូមិកំណើត។ ក្នុងពេលបំពេញការងារ រ៉ហ៊ីគីន បានទទួលដំណឹងអំពីការងារស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលផ្តល់ឱកាសដល់យុវជនសិក្សាស្វែងយល់បន្ថែមអំពីរបបខ្មែរក្រហម និងបញ្ហាសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

រ៉ហ៊ីគីន ក៏បានសម្រេចចិត្តចូលបម្រើការជាអ្នកស្ម័គ្រចិត្ត ហើយបានចុះធ្វើការសម្ភាសន៍អ្នកភូមិរបស់ខ្លួនរយៈពេល៣ខែ ក្នុងឆ្នាំ២០២២។ បន្ទាប់ពីកិច្ចការស្ម័គ្រចិត្ត រ៉ហ៊ីគីន ត្រូវបានជ្រើសរើសឱ្យចូលរួមកម្មវិធី Cross Talk របស់កាសែត Khmer Times ជាមួយយុវជនយុវនារីចំនួន៣នាក់ទៀត មកពីខេត្តមណ្ឌលគិរី ខេត្តត្បូងឃ្មុំ និងខេត្តបាត់ដំបង កាលពីថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៣ ។ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣ រ៉ហ៊ីគីន បានចូលជួបជាមួយឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក លោក ដាទ្រិក មើហ៊ី និង លោកស្រី ឃែរី កែលសមែន នាយកបេសកកម្មរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ និងបានឡើងថ្លែងចំណាប់អារម្មណ៍អំពីការងារស្ម័គ្រចិត្តដែលបានស្តាប់ និងរៀនសូត្រអំពីបទពិសោធន៍របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងភាពជាអ្នកដឹកនាំរបស់ខ្លួន។ ដោយសារការប្តេជ្ញាចិត្តលើការងារស្ម័គ្រចិត្តនេះ រ៉ហ៊ីគីន ត្រូវបានជ្រើសរើសចេញពីយុវជនជាច្រើននាក់ទៀត ដើម្បីចូលធ្វើការពាក់កណ្តាលម៉ោងនៅឯទីស្នាក់ការកណ្តាលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ទីក្រុងភ្នំពេញ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជំរុញនិងគាំទ្រយុវជនដែលជាបុគ្គលិកនិងអ្នកស្ម័គ្រចិត្ត ធ្វើការសិក្សាបន្តនិងស្វែងរកឱកាសទទួលបានការអប់រំជាន់ខ្ពស់ដើម្បីការលូតលាស់ទៅមុខ។ ចាប់តាំងពីឆ្នាំ១៩៩៥ មកដល់បច្ចុប្បន្ននេះ បុគ្គលិក និងអ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាចំនួន១០០នាក់ បានទទួលសញ្ញាបត្របណ្ឌិត សញ្ញាបត្រអនុបណ្ឌិត បរិញ្ញាបត្រ និងវគ្គបណ្តុះបណ្តាលជាន់ខ្ពស់មកពីបរទេស។ ដោយមានការគាំទ្រ និងជំរុញបែបនេះ រ៉ហ៊ីគីន សម្រេចចិត្តបន្តការសិក្សាផ្នែកតែងនិពន្ធ ដែលជាមុខវិជ្ជាដែលខ្លួនស្រឡាញ់តាំងពីក្មេង ប៉ុន្តែមិនទាន់មានឱកាសចាប់យក។ រ៉ហ៊ីគីន គឺជាក្មេងស្រីក្លាហាន ខំស្វាហាប់ព្យាយាម និងចូលចិត្តសាកល្បងធ្វើការងារដែលមានលក្ខណៈប្រកួតប្រជែង។ រ៉ហ៊ីគីន បានស្ម័គ្រចិត្តធ្វើជាប្រធានថ្នាក់នៅឯសកលវិទ្យាល័យដែលខ្លួនកំពុងសិក្សា។ បន្ទាប់ពីទទួលដំណឹងអំពីឱកាសអាហារូបករណ៍ដែលខាងសកលវិទ្យាល័យបានផ្សព្វផ្សាយ រ៉ហ៊ីគីន បានព្យាយាមស្វះស្វែងដាក់ពាក្យស្នើសុំ និងចូលរួមប្រឡងប្រជែងដណ្តើមអាហារូបករណ៍ជាមួយបេក្ខជនជាច្រើននាក់ផ្សេងទៀត។ ជាលទ្ធផល រ៉ហ៊ីគីន ក៏ទទួលបានជោគជ័យ ដោយទទួលបានអាហារូបករណ៍រយៈពេល៤ឆ្នាំ។ រ៉ហ៊ីគីន បានបញ្ជាក់ថា ខ្លួនចង់ក្លាយជាអ្នកនិពន្ធមួយរូបដែលនាំយកទស្សនៈ និងការយល់ឃើញជំនាន់ថ្មី ដើម្បីធ្វើឱ្យការតែងនិពន្ធកាន់តែប្លែកនិងទាក់ទាញ។





កញ្ញា សា រ៉ហ៊ីគីន គឺជាអ្នកស្ម័គ្រចិត្តកម្ពុជាក្នុងគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» របស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ឃិន សាវ៉ន៖ កម្មករនៅការដ្ឋានក្រសួងកសិកម្ម

**អេង សុខម៉េង**

ឃិន សាវ៉ិន ភេទស្រី អាយុ៤៨ឆ្នាំ (២០០៥) មានស្រុកកំណើត និងទីកន្លែងរស់នៅបច្ចុប្បន្ន ភូមិព្រែកត្នោត ឃុំសំបួរ ស្រុករមាសហែក ខេត្តស្វាយរៀង។ មានឪពុកឈ្មោះ កុយ បូរ (ស្លាប់) និងម្តាយឈ្មោះ កែវ យ៉ន (ស្លាប់)។ សាវ៉ិនជាកូនទី២ ក្នុងគ្រួសារ ដែលមានបងប្អូនចំនួន៨នាក់ ក្នុងនោះមានស្រី៦នាក់ឈ្មោះ (ឃិនយឿន, ឃិនសំអាត, ឃិនយ៉ាន, ឃិនភាគ, ឃិនភឿន, ឃិនសាវិន) និង ប្រុស ២នាក់ឈ្មោះ (ឃិនជា និង ឃិនចាន់)។ សាវ៉ិនបានរៀបការប្តីឈ្មោះ ធូ ឆាន នៅឆ្នាំ១៩៨៧ និង មានកូនចំនួន៣នាក់។

នៅក្នុងឆ្នាំ១៩៧០ សាវ៉ិន បានឈប់រៀនត្រឹមថ្នាក់ទី១២ (សង្គមចាស់)។ បន្ទាប់ពីឈប់រៀន ក៏ទៅជួយធ្វើស្រែចម្ការឪពុកម្តាយ និងឃ្វាលគោក្របី ខណៈពេលនោះក្នុងភូមិឃើញមានការទម្លាក់គ្រាប់បែកជាញឹកញាប់ និងមានសង្រ្គាម។ ចំណែកប្រជាជនត្រូវរត់ចេញពីផ្ទះសម្បែងទៅពួននៅក្នុងរណ្តៅត្រង់សេ និង គេចខ្លួនទៅរស់នៅក្នុងព្រៃ។ អំឡុងពេលនោះទ្រព្យសម្បត្តិប្រជាជនត្រូវបានបំផ្លិចបំផ្លាញ បន្តឱ្យប្រជាជនរងរបួស ស្លាប់ និង ព្រមទាំងគ្មានពេលវេលារកស៊ីចិញ្ចឹមជីវិត។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមឡើងកាន់អំណាចបានទាំងស្រុង អង្គការចាប់ផ្តើមបង្ខំប្រជាជនឱ្យធ្វើការងាររួម រស់នៅរួម និងហូបអាហាររួមគ្នានៅក្នុងរោងបាយសហករណ៍ព្រែកត្នោត។ សាវ៉ិន ត្រូវបានចាត់តាំងឱ្យទៅធ្វើការក្នុងកងចល័តនារីឃុំសំបួរ។ គាត់ត្រូវជីក និង រែកដី ហើយ



កសិករចិញ្ចឹមជ្រូកដើម្បីឧបត្ថម្ភដល់សហករណ៍ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ត្រូវរស់នៅបែកគ្នាពីឪពុកម្តាយ និងបងប្អូន។ នៅថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៧៥ សាវ៉ិន ត្រូវបានណែនាំឱ្យចូលធ្វើបដិវត្តន៍ខ្មែរក្រហមតាមរយៈ ឈ្មោះ តូច រិន ប្រធានវប្បធម៌មន្ទីរឃុំសំបួរ ដោយសារមូលហេតុគាត់ចង់ចូលរួមចំណែករំដោះប្រទេសជាតិឱ្យរួចផុតពីសង្រ្គាមជិះជាន់វណ្ណៈ។

នៅចុងឆ្នាំ១៩៧៥ សាវ៉ិន និងយុវជន៣នាក់ទៀត ក្នុងកងចល័តឃុំសំបួរត្រូវបានកងឈ្លបឃុំឈ្មោះផាន់ចុះមកជ្រើសរើសឱ្យទៅធ្វើការនៅក្រសួង

មន្ទីរ និងរោងចក្រនៅទីក្រុងភ្នំពេញ។ សារ៉ែន បានធ្វើដំណើរចេញពីស្រុកកំណើតតាមរថយន្តមករស់នៅ និងហ្វឹកហាត់នៅមន្ទីរទ័ព ដែលស្ថិតនៅជិតវត្តមេបុណ្យ ខេត្តព្រៃវែង។ នៅមន្ទីរទ័ព សារ៉ែន ត្រូវងើបម៉ោង៤ទៀបភ្លឺដើម្បីហាត់ពីវិធីក្បួនទ័ពដូចជា៖ លូន, ក្រាប, រត់, វិធីដោះមីន, និងរៀនពីរបៀបរស់ក្នុងព្រៃ។ នៅទីនោះមានយុវជន យុវនារីប្រហែល ១០០នាក់ដែលមករៀន និងគ្រប់គ្រងដោយឈ្មោះ លឿ។ ក្រៅពីការហ្វឹកហាត់ទ័ព សារ៉ែន និងអ្នកហាត់ទ័ពដទៃទៀត ក៏មានភារកិច្ចជួយធ្វើស្រែប្រជាជន។ សារ៉ែន និងអ្នកហាត់ទ័ពទាំងអស់ត្រូវចម្អិនម្ហូបអាហារដោយខ្លួនឯង និងទទួលរបបអង្ករម្នាក់១កំប៉ុង សម្រាប់១ថ្ងៃ។

នៅក្នុងឆ្នាំ១៩៧៦ សារ៉ែន និងយុវជន យុវនារីទាំងអស់ត្រូវឈ្មោះ លឿ ដឹកនាំឱ្យទៅធ្វើការ នៅភ្នំពេញ។ សារ៉ែន និងយុវជន យុវនារីបានធ្វើដំណើរតាមកប៉ាល់ពីតំបន់អ្នកលឿង ខេត្តព្រៃវែង ឆ្ពោះមកទីក្រុងភ្នំពេញដោយឈប់សម្រាកនៅមុខព្រះបរមរាជវាំង។ ពេលធ្វើដំណើរឆ្លងកាត់ភ្នំពេញ សារ៉ែន បានឃើញស្ថានភាពនៅទីក្រុងមានសភាពស្ងាត់ជ្រងំ។ សារ៉ែននិយាយថា "ទីក្រុងភ្នំពេញនៅពេលនោះ ហាក់ដូចជាទីក្រុងខ្មោចដែលត្រូវបោះបង់ចោលអញ្ចឹង"។ "អំឡុងពេលខ្មែរក្រហមឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា អង្គការបានបង្ខំអ្នករស់នៅទីក្រុងភ្នំពេញប្រហែលពីរលាននាក់ ដែលក្នុងនោះរួមទាំងអ្នកភៀសខ្លួនចូលទីក្រុងក្នុងអំឡុងពេលសង្គ្រាមចំនួនជាងមួយលាននាក់ ដង់ឱ្យចាកចេញដើម្បីធ្វើដំណើរទៅកាន់ទីជនបទ ដើម្បីធ្វើស្រែចម្ការ"។

សារ៉ែន ពេលមកដល់ភ្នំពេញបានឃើញ យុវជន យុវនារី ជាច្រើនមកពីបណ្តាលខេត្តនានាដើម្បីត្រៀមខ្លួនចូលធ្វើការឱ្យខ្មែរក្រហមតាមកន្លែងផ្សេងៗ។ គាត់ត្រូវបានជ្រើសរើសក្នុងចំណោមយុវជន យុវនារី ប្រហែល១០០នាក់ "ក្រុមគ១២" ឱ្យទៅធ្វើការនៅការដ្ឋានទី២ ដែលជាការដ្ឋានស្ថិតក្រោមក្រសួងកសិកម្ម នៅក្នុងវត្តអង្គជ័យ ស្រុកលើកដែក ខេត្តកណ្តាល។ ក្រុមគ១២ គ្រប់គ្រងដោយឈ្មោះ ហៀង និងឈ្មោះជ័យ។ ក្រុមនេះត្រូវរុករានដីព្រៃទំហំប្រមាណជាង១០០ហិចតា ដើម្បីឱ្យប្រជាជនធ្វើស្រែចម្ការ។ សារ៉ែន និយាយថា "ការងារនៅទីនោះជាការងារធ្ងន់ព្រោះប្រើកម្លាំងមនុស្សសុទ្ធសាធដើម្បីកាប់កាស់គល់ឈើតូចធំ។ កម្មករត្រូវសម្រាកនៅក្នុងព្រៃដោយគ្មានកន្លែងត្រឹមត្រូវ"។ សារ៉ែន បន្តថា "កម្មករធ្វើការងារនៅទីនេះធ្វើគ្មានពេលសម្រាក ទោះបីឈឺក៏ប្រធានឈ្មោះជ័យ និងឈ្មោះហៀងមិនឱ្យសម្រាកដែរ"។ ចំណែករបបអាហារវិញទទួលបានមិនគ្រប់គ្រាន់។ នៅទីនោះសម្បូរផ្លែដូង សារ៉ែន និងក្រុមគ១២ តែងតែលួចផ្លែដូងរបស់អង្គការហូប។

បន្ទាប់ពីក្រុមគ១២ រុករានដីព្រៃបានរួចរាល់ នៅចុងឆ្នាំ១៩៧៧ សារ៉ែន ត្រូវបានផ្លាស់ប្តូរកន្លែងធ្វើការពីការដ្ឋានវត្តអង្គជ័យ ទៅការដ្ឋានបឹងបាយ៉ាប ស្ថិតនៅជាយក្រុងភ្នំពេញ ដោយមានការគ្រប់គ្រងពីក្រសួងកសិកម្ម។ នៅបឹងបាយ៉ាប សារ៉ែន និងកម្មករដទៃទៀតត្រូវបានអង្គការខ្មែរក្រហមប្រើឱ្យសាងសង់រោងចក្រ។ នៅការដ្ឋានមានប្រធានគ្រប់គ្រងឈ្មោះ លី និងឈ្មោះ អាត។ ការងាររបស់ សារ៉ែនមានដូចជា លាយស៊ីម៉ង់ ចងដែក និងជញ្ជូនឥដ្ឋដើម្បីរៀបធ្វើជារោងចក្រ។ នៅការដ្ឋាននេះ សារ៉ែន ឃើញជនជាតិកូរ៉េខាងជើង៣នាក់បានមកដំឡើងម៉ាស៊ីន និងគ្រឿងចក្រធំៗសម្រាប់ប្រើប្រាស់ក្នុងរោងចក្រ។ បន្ទាប់ពីដំឡើងម៉ាស៊ីនរួចជនជាតិកូរ៉េខាងជើងនោះបានត្រឡប់ទៅប្រទេសខ្លួនវិញ។

នៅក្នុងឆ្នាំ១៩៧៨ ការដ្ឋានបឹងបាយ៉ាប ជារឿយៗ សារ៉ែន បានឃើញការបាត់ខ្លួន និងចាប់ខ្លួនកម្មករមកពីខេត្តកំពង់ចាម ខេត្តព្រៃវែង និងស្វាយរៀង។ សារ៉ែន និយាយថា "ការចាប់ និងបាត់ខ្លួនកម្មករនេះគឺពាក់ព័ន្ធនឹងកម្មាភិបាលខ្មែរក្រហមនៅភូមិភាគបូព៌ាដែលត្រូវបានអង្គការចោទប្រកាន់ថាបានក្បត់ និងចង់ផ្តួលរំលំរបបខ្មែរក្រហម"។ ឃើញដូច្នេះគាត់បានរត់គេចពីការដ្ឋានបឹងបាយ៉ាប ដើម្បីធ្វើដំណើរជាមួយបងធម៌ទៅស្រុកគងពិសី ខេត្តកំពង់ស្ពឺ។ សារ៉ែន និង បងធម៌ត្រូវបានខ្មែរក្រហមចាប់បាន និង

ឃុំខ្លួនក្នុងទូររថភ្លើងរយៈពេល ១យប់ ១ថ្ងៃ ប្រធានឈ្មោះលី និងឈ្មោះ អាត លត់ដំឱ្យធ្វើការងារធ្ងន់ និងបានដាក់ទណ្ឌកម្មដោយបង្អត់អាហារ ព្រមទាំងឱ្យធ្វើកិច្ចសន្យាឈប់រត់គេចពីការដ្ឋានបន្តទៀតៗ

នៅពាក់កណ្ដាលឆ្នាំ ១៩៧៨ សារ៉ាន ត្រូវបានផ្លាស់ប្ដូរកន្លែងធ្វើការពីការដ្ឋានបឹងបាយ៉ាប ទៅការដ្ឋានអូរដឹម ស្ថិតនៅជិតផ្លូវជាតិលេខ៤ នៅជិតពោធិ៍ចិនតុង។ នៅការដ្ឋាននេះ សារ៉ាន ត្រូវបានប្រធានឈ្មោះ ភឿន ប្រើឱ្យក្រឡឹងដែកដើម្បីយកទៅជួសជុលគ្រឿងចក្រកសិកម្ម។ ការងារនៅការដ្ឋានអូរដឹមមិនសូវលំបាកទេ ចំណែកការហូបចុកវិញក៏ទទួលបានគ្រប់គ្រាន់ និងមានបន្ថែមហូបមួយសប្ដាហ៍ម្ដងទៀតផង។ ប៉ុន្តែសារ៉ាន និងកម្មករទាំងអស់ត្រូវបង្ខំឱ្យផ្ដល់ឈាមក្នុងមួយខែចំនួនពីរដង ទៅឱ្យមន្ទីរពេទ្យ ១៧ មេសា "បច្ចុប្បន្នមន្ទីរពេទ្យមិត្តភាពខ្មែរ- សូវៀត" ដើម្បីយកឈាមទៅសង្គ្រោះអាយុជីវិតយោធាដែលរងរបួសនៅសមរភូមិ។ សារ៉ាន បាននិយាយថា "ការផ្ដល់ឈាមនៅពេលនោះមិនមែនជាការស្ម័គ្រចិត្តដូចបច្ចុប្បន្នទេ កម្មករត្រូវបានគំរាមសម្លាប់ចោល ប្រសិនបើមិនព្រមផ្ដល់ឈាម។ ឈាមដែលត្រូវផ្ដល់គឺប្រភេទ O និងប្រភេទAB ចំណែកឈាមប្រភេទA និងប្រភេទ B មិនត្រូវការទេ" ។

អំឡុងពេលធ្វើការនៅការដ្ឋានអូរដឹម សារ៉ាន ធ្លាប់ត្រូវបានប្រធានឈ្មោះ ភឿន បញ្ជូនឱ្យទៅរៀនសូត្រចំនួន៣ដង នៅតំបន់បុរីកីឡា ស្ដីពី "ការងារកសិកម្ម និងមាគ៌ាបក្ស"។ នៅបុរីកីឡាគាត់ឃើញ នួន ជា និង ខៀវ សំផន បានមកធ្វើបទឧទ្ទេសនាមពីវគ្គអប់រំនយោបាយ ដោយប្រាប់ដល់អ្នកចូលរួមប្រហែល២០០នាក់ត្រូវខិតខំធ្វើការដើម្បីជំរុញកំណើនសេដ្ឋកិច្ចជាតិ។ ខៀវ សំផនបាននិយាយប្រាប់អ្នកចូលរួមថា "អ្នកដែលសម្លាប់ឪពុកម្ដាយយើងនៅតាមមូលដ្ឋាន និងឱ្យយើងហូបមិនគ្រប់គ្រាន់ហ្នឹង គឺជាជនក្បត់ ជាយួន អ្នកសម្លាប់ខ្មែរគឺមានតែយួនទេ"។ រីឯ នួន ជា វិញបានឆ្លើយតបនឹងសំណួរដែលសួរអំពីការបាត់ខ្លួនរបស់កម្មករភូមិភាគបូព៌ានៅការដ្ឋានអូរដឹមថា "កម្មករទាំងនោះត្រូវបានអង្គការនាំយកទៅរៀនសូត្រ"។

សារ៉ាន ធ្វើការផ្នែកក្រឡឹងដែកនៅការដ្ឋានរោងចក្រអូរដឹម រយៈពេលប្រហែល៦ខែ របបខ្មែរក្រហមក៏បានដួលរលំ។ នៅក្នុងឆ្នាំ១៩៧៩ ពេលកងទ័ពវៀតណាមវាយចូលមកដល់ទីក្រុងភ្នំពេញ កម្មករ និងសារ៉ានបានរត់ភៀសខ្លួនទៅខេត្តភាគខាងលិចប្រទេសកម្ពុជា។ សារ៉ាន បានទៅរស់នៅខេត្តឧត្ដរមានជ័យ ព្រំដែនប្រទេសថៃបានមួយរយៈក៏ត្រឡប់មករស់នៅស្រុកកំណើតវិញ។

ការរស់នៅឆ្លងកាត់របបខ្មែរក្រហម សារ៉ាន យល់ថា ប្រជាជន និងកម្មាភិបាលថ្នាក់មូលដ្ឋានទាំងអស់គ្មានសិទ្ធិសេរីភាពក្នុងការសម្រេចចិត្តទេ រាល់ផែនការទាំងអស់ដែលថ្នាក់ដឹកនាំកំណត់ត្រូវតែអនុវត្តតាមមិនអាចប្រកែកបាន។ សារ៉ានមិនពេញចិត្តចំពោះការដឹកនាំក្នុងរបបខ្មែរក្រហមទេ បើទោះបីជាគាត់បានចូលរួមជាជនបដិវត្តន៍ម្នាក់កាលពីអតីតកាលក៏ដោយ ព្រោះរបបនេះស្ទើរតែសម្លាប់គាត់ដោយគ្រាន់តែសង្ស័យថាគាត់ជាប់ពាក់ព័ន្ធនឹងកម្មាភិបាលរស់នៅភូមិភាគបូព៌ា។ សារ៉ាន ធ្លាប់ប្រាប់រឿងរ៉ាវដែលគាត់បានរស់នៅឆ្លងកាត់ក្នុងរបបខ្មែរក្រហមដល់កូនចៅ និងក្មេងជំនាន់ក្រោយក្នុងគោលបំណងចូលរួមទប់ស្កាត់កុំឱ្យរបបខ្មែរក្រហមត្រឡប់មកលើទឹកដីកម្ពុជាសារជាថ្មី។



កងចល័តកំពុងជីកប្រឡាយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ជឿលើសន្យារបស់អង្គការ

## សុភ័ក្ត្រ ភាណា

“ដឹកស្មៅ ត្រូវដឹកទាំងឫស” ជាសុភាសិតដែលតែងតែប្រើប្រាស់ជាសកលក្នុងរបបដឹកនាំបែបផ្តាច់ការ។ នៅក្នុងសង្គមខ្មែរ សុភាសិតនេះ ពេញនិយមប្រើប្រាស់នៅក្នុងរបបកម្ពុជាប្រជាធិតេយ្យ (១៩៧៥-១៩៧៩) ឬ របបខ្មែរក្រហម។ ខ្មែរក្រហម អនុវត្តគោលការណ៍ “ដឹកស្មៅ ត្រូវដឹកទាំងឫស” ទៅលើក្រុមគោលដៅ ឬក្រុមសង្ស័យដែលប្រឆាំងជាមួយខ្លួន។ នៅអំឡុងឆ្នាំ១៩៧៦ និង ១៩៧៧ ខ្មែរក្រហម បានអនុវត្តការធ្វើបន្សុទ្ធកម្មលើសមាជិករបស់ខ្លួន ដោយសារ ប៉ុល ពត និងសហការី ជឿថាការបះបោរប្រឆាំងនឹងថ្នាក់ដឹកនាំបក្ស កាន់តែកើតមានច្រើនឡើងៗ។ “មន្ទីរសន្តិសុខ” ឬហៅសាមញ្ញថា “គុក” រួមមានជិត២០០កន្លែងត្រូវបានបង្កើតឡើងដោយខ្មែរក្រហម គ្របដណ្តប់ស្ទើរគ្រប់ទិសទីលើផ្ទៃប្រទេស។ នៅក្នុងអំឡុងនៃការធ្វើបន្សុទ្ធកម្ម អ្នកដែលខ្មែរក្រហមចោទថាជាជនក្បត់ជាតិ និងអ្នកដែលពាក់ព័ន្ធត្រូវបានបញ្ជូនទៅសួរចម្លើយ ដែលនៅចុងបញ្ចប់គឺត្រូវឃុំខ្លួន ឬកម្ទេច។ ថោង ហ៊ិន គណៈអប់រំស្រុកមេមត់ នៃតំបន់២១ ត្រូវបានចាប់បញ្ជូនទៅមន្ទីរ ស-២១។ ផ្តោតលើគោលការណ៍ “ដឹកស្មៅដឹកទាំងឫស” ខ្មែរក្រហម ក៏បានស្រាវជ្រាវនិងចាប់បញ្ជូនអ្នកដែលពាក់ព័ន្ធនឹង ថោង ហ៊ិន ទាំងអស់ទៅសួរចម្លើយនិងឃុំខ្លួនដែរ។ ជាក់ស្តែង ឈុំ រីម ដែលជាប្រពន្ធរបស់ ថោង ហ៊ិន ត្រូវបានឃាត់ខ្លួននិងបញ្ជូនទៅសួរចម្លើយនៅមន្ទីរ ស-២១ នៅខែមិថុនា ឆ្នាំ១៩៧៧។



ឯកសារ K០០៦៩៦ ដែលមានចំណារលេខដើម TSL៤១២៤ តម្កល់ទុកនៅក្នុងបណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា

ឈុំ រីម កើតនៅក្នុងគ្រួសារកសិករមួយ នៅក្នុងភូមិកំផ្លាក់ ឃុំបារាយណ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ កាលពីកុមារភាព ឈុំ រីម បានសិក្សារៀនសូត្រដល់ត្រឹមថ្នាក់ទី១០ចាស់ ដែលស្មើនឹងថ្នាក់ទី៦នាពេលបច្ចុប្បន្ន។ ដោយសារតែនៅភូមិកំណើតមានសភាពការណ៍ចលាចល រីម បានឈប់រៀន និងស្ម័គ្រចិត្តចូលបម្រើទ័ពនារីភូមិនៅ

ក្នុងឆ្នាំ១៩៧៣ ជាមួយនឹងអ្នកភូមិចំនួន១២នាក់ផ្សេងទៀត។ នៅមុនពេលត្រូវបញ្ជូនទៅសមរភូមិ រីម និងគ្នីគ្នា ត្រូវបញ្ជូនទៅកាន់ភូមិផ្ទះវាល ឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ដែលជាទីតាំងសម្រាប់បណ្តុះបណ្តាលកងកម្លាំងទើបចូលរួមថ្មីៗ នៅទីនេះ រីម ត្រូវរៀនវគ្គនយោបាយ និងការបំពាក់បំប៉នស្មារតីដើម្បីកុំឱ្យភ័យខ្លាច កុំឱ្យញញើត និងរាថយនៅក្នុងសមរភូមិ មុនពេលត្រូវបញ្ជូនទៅសមរភូមិជាក់ស្តែង។ ក្រោយបិទវគ្គ រីម និងទ័ពនារីសរុប៣០នាក់ ត្រូវបានចាត់បញ្ជូនឱ្យទៅឈរជើងនៅសមរភូមិបាក់ខែង។ នៅក្នុងសមរភូមិដំបូងនេះ រីម ទទួលបន្ទុកជញ្ជូនសម្ភារនិងសព្វាវុធសម្រាប់យុទ្ធជនដែលវាយតតាំងក្នុងសមរភូមិ។ រីម ថែមទាំងត្រូវសែងយុទ្ធជនរបួសទៅពេទ្យ និងសាកសពទាហានទៅកប់ថែមទៀតផង។ រីម រំឭកថា នៅក្នុងសមរភូមិ គាត់ត្រូវធ្វើការតាមមុខព្រួញ តាំងពីម៉ោង៣ទៀបភ្លឺដល់ម៉ោង៦ល្ងាចទើបបានសម្រាក។ ក្រោយយកឈ្នះលើសមរភូមិនៅបាក់ខែង កងកម្លាំងខ្មែរក្រហម បានបន្តរុញកម្លាំងទៅមុខ គឺទៅកាន់ម្តុំឃ្លាំងមឿង, ព្រែកក្របៅ, ព្រែកថោង និងតំបន់នានាតាមបណ្តោយផ្លូវជាតិលេខ៦ រហូតទៅឈរជើងចាំវាយយកទីក្រុងភ្នំពេញនៅតំបន់ជ្រោយចង្វារមួយថ្ងៃមុនជ័យជម្នះរបស់ខ្មែរក្រហម។

“ឈរជើងនៅទីនេះ គេវាយពីក្បាលព្រលប់វាយឱ្យទល់តែព្រឹកឡើងក្រសោបអស់ល្ហម” រីម បានរំឭកអំពីហេតុការណ៍មុនខ្មែរក្រហមវាយយកបានទីក្រុងភ្នំពេញមួយថ្ងៃ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នៅពេលដែលខ្មែរក្រហមក្តោបក្តាប់បានទីក្រុងភ្នំពេញ រីម បានរៀបរាប់ថា នៅក្នុងក្រុងមានសភាពជ្រួលច្របល់។ ប្រជាជនចេញពីផ្ទះសម្បែងទាំងក្រុមៗ ឯកងកម្លាំងខ្មែរក្រហមនៅយាមល្បាត និងចាំឃាត់ខ្លួនទាហាន លន់ នល់។ ជាក់ស្តែង កងរបស់ រីម បានចាប់ខ្លួនទាហាន លន់ នល់ ចំនួន២០០នាក់ រួចបញ្ជូនឡើងរថយន្តចេញពីភ្នំពេញ។ ក្រោយពីជម្លៀសប្រជាជនចេញអស់ ខ្មែរក្រហម បានប្រាប់កងកម្លាំងរបស់ខ្លួនថា គេនឹងរៀបចំក្រុងឡើងវិញ និងបង្កើតជារោងចក្រផ្សេងៗ។ នៅពេលរួចរាល់ យុទ្ធជនខ្មែរក្រហមអាចចូលបម្រើនៅតាមកន្លែងណាដែលខ្លួនពេញចិត្ត។ ដោយជឿតាមការសន្យានេះ រីម នៅរង់ចាំនៅទីក្រុងភ្នំពេញមួយរយៈ រួចក៏ត្រូវចាត់តាំងឱ្យទៅម្តុំគៀនឃ្លាំង ផ្នែកជ្រោយចង្វារ។ នៅទីនេះ រីម ត្រូវអង្គការចាត់តាំងឱ្យដាំបន្លែមួយរយៈ ទម្រាំមានការចាត់តាំងបន្ថែម។

នៅពេលនោះ អង្គការ បានរៀបចំគូស្រករឱ្យ រីម ដោយលើកឡើងថា រីម គួររៀបការជាមួយកម្មាភិបាលឱ្យហើយ បើមិនដូច្នោះទេ រីម អាចត្រឹមរៀបការជាមួយនឹងយុទ្ធជនពិការប៉ុណ្ណោះ។ រីម បានយល់ព្រម ទោះបីជាគាត់ពុំធ្លាប់ជួបជាមួយនឹងគូស្រករដែលអង្គការរៀបចំឱ្យពីមុនមកក៏ដោយ។ អង្គការបានផ្សំផ្គុំ រីម ជាមួយនឹងសមមិត្ត ថោង ហ៊ុន ដែលមកពីស្រុកមេមត់។ យោងតាម រីម, ថោង ហ៊ុនបានចូលរួមតស៊ូជាមួយខ្មែរក្រហមតាំងពីឆ្នាំ១៩៧០មកម្ល៉េះ។ ក្រោយពីទទួលជ័យជម្នះ ខ្មែរក្រហម បានតែងតាំង ហ៊ុន ជាគណៈអប់រំនៅស្រុកមេមត់។ ក្រោយរៀបការបានមួយរយៈ រីមបានទៅលេងស្រុកកំណើតរបស់ហ៊ុន រួចវិលត្រឡប់មកកាន់គៀនឃ្លាំងវិញ ឯ ហ៊ុន នៅឈរជើងនៅមេមត់ ក្នុងភូមិភាគបូព៌ា។ រីម រៀបរាប់ថា គាត់តែងតែអាចទៅលេងក្រុមគ្រួសារបាន។ ក្រោយរៀបការបានមួយរយៈ រីម បង្កើតបានកូនស្រីម្នាក់ ដែលកូននោះនៅស្នាក់ជាមួយខ្លួននៅឯគៀនឃ្លាំង។

មិនយូរប៉ុន្មាន រីម បានលេចព្ត័ត៌មានអំពីការចាប់ខ្លួនមេដឹកនាំខ្មែរក្រហមនៅភូមិភាគបូព៌ា។ ក្នុងថ្ងៃមួយ នៅម៉ោងប្រមាណ១០យប់ មាននីរសារខ្មែរក្រហម បានមករក រីម ដោយប្រាប់ឱ្យរីមរៀបចំរបស់របរដើម្បីទៅទស្សនកិច្ចកំពង់សោម។ នៅពេលនោះ រីម បានស្នើនីរសារឱ្យគាត់បានបំបៅដោះកូនមុនពេលចេញទៅ តែនីរសារនោះបានបដិសេធ និងតបថា៖ “មិនបាច់ឱ្យទឹកដោះអីទេ កូននឹងមុនក្រោយគង់មិននៅ”។ រីម លើកឡើងថា ដោយសារតែកូនរបស់ខ្លួន

ឃ្លាននិងពុំបានទឹកដោះ កូននោះយំរហូតគាំងស្លាប់។ រីម នៅចងចាំទិដ្ឋភាពនៃការស្លាប់របស់កូនខ្លួនមិនភ្លេច។ ក្រោយពីកូនផុតដង្ហើមទៅ រីម ពុំបានរៀបចំសពរបស់កូនឱ្យបានស្រួលបួលឡើយ ពីព្រោះថានីរសារនោះ បានបង្ខំឱ្យរីមឡើងរថយន្តចាកចេញទៅ។

នៅពេលចុះលើរថយន្តរីម សង្កេតឃើញថា ខ្លួនបានមកដល់អគារដូចសាលារៀនមួយកន្លែង ដែលបំភ្លឺដោយអំពូលម៉ែត្រភ្លឺចែស។ រីម ត្រូវបាននាំទៅកាន់បន្ទប់បិទជិតនៅជាន់ផ្ទាល់ដី ដើម្បីសួរនាំ។ "អង្គការចាក់វ៉ាត់យូ (វិទ្យុ) ឮៗ ចឹងមិនបានឮសូរសំឡេងអី ពីខាងក្រៅទេ" រីម លើកឡើង។ "អ្នកសួរមុខខុសគ្នា ខ្ញុំត្រូវអង្គការសួរពីរដង។ អង្គការសួរតែពេលយប់ទេ ហើយពេលព្រឹកអង្គការដាក់ឃុំនៅជាន់ទីពីរ។ ក្រោយសួរហើយលើកដំបូង អង្គការនាំខ្ញុំទៅថតរូប។ អង្គការសួរប្រវត្តិចូលទ័ព ប្រវត្តិយុវកក "អង្គការថាខ្ញុំហ្នឹងប្រពន្ធពួកក្បត់ ខ្ញុំជាប់និន្នាការនយោបាយពួកក្បត់។ អ្នកដឹកនាំក៏ក្បត់ ប្ដីក៏ក្បត់ អីចឹងទៅអង្គការចាប់ខ្ញុំយកទៅគុកទួលស្លែង។ អង្គការសួរចម្លើយខ្ញុំ ២យប់២ថ្ងៃ។" ដោយសារតែ ឈុំ រីម ពុំបានផ្ដល់ចម្លើយបង្ហាញអំពីចេតនាក្បត់ ខ្មែរក្រហម បានបញ្ឈប់ការសួរចម្លើយដែលប្រព្រឹត្តទៅអស់រយៈពេល២យប់២ថ្ងៃនេះ រួចបញ្ជូន រីម ឱ្យទៅធ្វើការនៅគុកព្រៃសអស់រយៈកាលជិត១ឆ្នាំ។

ឈុំ រីម បានរៀបរាប់អំពីជីវភាពរស់នៅជាង១ឆ្នាំនៅព្រៃស៖ "អើយ! វេទនាណាស់ មហាវេទនា ម៉ោង៣ក្រោកឡើយតម្រង់ជួរ ម៉ោង៨យប់បានចូលដល់កន្លែងៗ! បន្ថែមម៉ោងគេទៀតដល់ ម៉ោង១១ ឬ១២ បានៗឱ្យដេក។ ដេកបានមួយភ្លែត ផ្លុំកញ្ចែប្រែក ផែនការក្ដៅម៉ោង ១ តម្រង់ជួរចេញធ្វើការបន្តទៀត"។ ក្រៅពីស្ថានភាពការងារដ៏លំបាកលំបិននេះ ឈុំ រីម និងអ្នកជាប់ឃុំក្នុងមន្ទីរនេះ ត្រូវរស់នៅក្នុងភាពភិតភ័យ ពីព្រោះ មានការនាំខ្លួនមនុស្សចេញចូលជារៀងរាល់យប់។ ឈុំ រីម បន្តថា៖ "អង្គការប្រាប់ថា យកទៅកសាងនៅសហករណ៍ផ្សេង ការពិត យកទៅវាយនៅរណ្ដៅ៤ជ្រុងៗ មួយយប់ចូល៣ឡាន ចេញ៣ឡាន អាកាម៉ាសធំៗ"។

ក្រៅពីសណ្ឋានការងារធ្ងន់ធ្ងរ រីម ក៏ពុំបានទទួលរបបអាហារគ្រប់គ្រាន់ដែរ។ រីម រំឭកថា ដោយសារតែអត់ឃ្លានយូរថ្ងៃ គាត់និងមិត្តរួមក្រុម នាំគ្នាចាប់ក្ដាមនិងត្រីហូបទាំងរស់។ រីម ធ្លាប់ត្រូវអង្គការចាប់បានអំពីការលួចហូបនេះ នឹងទទួលបានការគំរាមកម្ទេចពីអង្គការថែមទៀតផង។ រីម លើកឡើងថា ទោះបីជាត្រូវចាប់បាននិងគំរាមយ៉ាងណាក្ដី គាត់នៅតែបន្តលួចចាប់សត្វហូប ពីព្រោះបើមិនដូច្នោះទេ គាត់ត្រូវដាច់ពោះស្លាប់ មុនពេលអង្គការកម្ទេចទៅទៀត។ ជាសំណាងល្អ គាត់ពុំត្រូវអង្គការចាប់បានអំពីការលួចហូបទៀតទេ។ រីម ធ្លាប់បានចូលរួមនៅក្នុងការប្រារព្ធខួបបក្សម្ដង ដោយរីមចាំបានថានៅក្នុងការប្រារព្ធ គាត់ធ្លាប់ឃើញមានក្រុមជនជាតិចិនមកចូលរួមដែរ។ ក្រោយប្រារព្ធខួបបក្ស ជនជាតិចិនទាំងនោះបានដើរសួរសុខទុក្ខយុទ្ធជនយុទ្ធនារី ដោយមានអ្នកបកប្រែមកជាមួយ។ នៅមុនពេលចូលរួម ប្រធានបានហាមឃាត់សមាជិកក្នុងក្រុមមិនឱ្យនិយាយរិះគន់អង្គការឡើយ។ នោះគឺជាឱកាសតែម្ដងគត់នៅក្នុងរបបខ្មែរក្រហម ដែលរីមត្រូវបានអនុញ្ញាតឱ្យចេញពីព្រៃសទៅចូលរួម និងទទួលបានសម្លៀកបំពាក់ស្អាតបាត។

មិនយូរប៉ុន្មាន សភាពការណ៍នៅកន្លែងបំពេញការងាររបស់រីមចាប់ផ្ដើមជ្រួលច្របល់។ សមមិត្តរួមក្រុមបានបែកខ្ញែកពីគ្នា ដោយមានការប្រកាសថា វៀតណាមវាយបានទីក្រុងភ្នំពេញ។ រីម និងមិត្តរួមក្រុមមួយចំនួន បានមម៉ីម៉ាចាកចេញពីទីក្រុងភ្នំពេញនៅពេលជ្រួលច្របល់នេះ។ ក្រោយធ្វើដំណើរអស់ជាង៣០ថ្ងៃ រីមបានមកដល់កោះកុង។ ក្រោយពីនៅទីនេះបានមួយរយៈ វៀតណាមក៏បានមកដល់កោះកុងដែរ។ កម្លាំងខ្មែរក្រហមមួយចំនួនបានបន្តភៀសខ្លួន ចំណែកឯរីមបន្តនៅកោះកុង និងទទួលបានការផ្គត់ផ្គង់អាហារពីទ័ពវៀតណាម។ នៅឆ្នាំ១៩៨០ រីមបានសម្រេចចិត្តវិលត្រឡប់មកស្រុកកំណើតនៅខេត្ត

កំពង់ចាមវិញ ហើយបន្តរស់នៅទីនេះ កសាងគ្រួសារថ្មី និងមានកូនស្រី៣នាក់ កូនប្រុស២នាក់។

រំឭកដល់អតីតកាលជូរចត់ និងបទពិសោធន៍គួរឱ្យភិតភ័យរបស់ខ្លួនក្នុងអំឡុងរបបខ្មែរក្រហម រីម បានខទានថា៖ “ស្តាយខ្លួនថា ខំធ្វើការតស៊ូមក លទ្ធផលវាទៅជាស្គាល់ពីការវេទនា វាមិនបានផលអីទេ! បំណាច់ថាហត់នឿយពិបាកត្រឡប់ត្រឡិន ឆ្លងកាត់គ្រាប់ផ្លោង ដើម្បីឱ្យលទ្ធផលមកខ្លួនបានសុខស្រួលទៅ វាអត់មានលទ្ធផលអី បានត្រឹមតែចូលគុកដោយខ្លួនមិនបានធ្វើអី! មិនបានដឹងខ្លួនហ្នឹង! ស្មោះត្រង់ចំពោះប្រជាជនមាតុភូមិខ្លួនឯង ម៉េចហើយលទ្ធផលចុងក្រោយមិនឱ្យផល ទៅជាឱ្យទោសមកវិញ! ឱ្យយកទៅដាក់គុកវិញហ្នឹង!”។ រីម នៅតែមានវិប្បដិសារី ក្រោយបម្រើខ្មែរក្រហម។ ហេតុនេះ នៅពេលទំនេរ ឬអផ្សុក រីមតែងតែនិទានពីប្រវត្តិតស៊ូរបស់ខ្លួនប្រាប់កូនចៅជំនាន់ក្រោយ ដើម្បីកុំឱ្យជ្រុលខ្លួនដូចគាត់ និងកុំឱ្យក្មេងៗភ្លេចពីរបបយោរយៅនេះ។






ជនរងគ្រោះនៅមន្ទីរសន្តិសុខស-២១។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ញ៉ាញ់ មៀវ៖ បណ្តាំម្តាយ «នាំប្អូនរត់ចុះ ម្តាយមិនរស់ទេ»
## អំឡុងពេលកងទ័ពវៀតណាមវាយប្រហារលើកងកម្លាំងខ្មែរក្រហម

**ទី ស៊ីថា**

នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ១៩៧៨ វិទ្យុក្រុងហាណូយបានផ្សព្វផ្សាយពីការបង្កើតឡើងនូវរណសិរ្ស សាមគ្គីសង្គ្រោះជាតិកម្ពុជា។ មេបញ្ជាការទ័ពវៀតណាម វ៉ាន់ ទៀងយុង បានធ្វើការវាយប្រហារ យ៉ាងខ្លាំងក្លាមកលើរបបកម្ពុជាប្រជាធិបតេយ្យនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៧៨។ ទ័ពរបស់ វ៉ាន់ ទៀងយុង បានវាយកាន់កាប់ខេត្តក្រចេះ។ ប្រជាជនរស់នៅក្នុងភូមិជើងឃ្លូបានរត់ចេញពីភូមិទាំងអស់ នៅសល់តែ មៀវ ជាមួយម្តាយ និង ប្អូនប្រុស។ ម្តាយ មៀវ បានប្រាប់ថា «នាំប្អូនរត់ជាមួយអ្នកភូមិទៅកូន ទុកម៉ែនៅទីនេះហើយ ម៉ែដឹងតែមិនរស់ទេ»។ ពេលនោះមៀវ ក៏បានពប្អូនប្រុសរត់ទៅតាមប្រជាជនក្នុងភូមិ។



ញ៉ាញ់ មៀវ ជនជាតិស្អៀង រស់នៅភូមិល្ហាលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

***ខាងក្រោមនេះជាការរៀបរាប់រឿងរ៉ាវរបស់ញ៉ាញ់ មៀវ៖***

នាងខ្ញុំឈ្មោះ ញ៉ាញ់ មៀវ ភេទស្រី ជាជនជាតិដើមភាគតិចស្អៀង កើតនៅថ្ងៃទី៧ ខែមីនា ឆ្នាំ១៩៦១។ ខ្ញុំកើតនៅភូមិល្ហាលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តកំពង់ចាម។ បច្ចុប្បន្ន ខ្ញុំរស់នៅភូមិល្ហាលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ឪពុកខ្ញុំឈ្មោះ ញ៉ាញ់ និង ម្តាយឈ្មោះ ប៉ម។ ឪពុកម្តាយខ្ញុំស្លាប់អស់ហើយនៅក្នុងរបប ប៉ុល ពត។ ខ្ញុំមានបងប្អូនចំនួន៤នាក់ ក្នុងនោះមានប្រុស៣នាក់ និងស្រីម្នាក់។ សព្វថ្ងៃបងប្អូនខ្ញុំនៅរស់តែ២នាក់ គឺប្រុស១នាក់ និង ស្រី១នាក់។ ពីដំណាន់ដើម អ្នកភូមិល្ហាលើប្រកបរបរធ្វើចម្ការ និងដាំស្រូវ។ ប្រជាជនក្នុងភូមិភាគច្រើនជាជនជាតិដើមភាគតិចស្អៀង (ស្អៀងខាន)។ ការប្រាស្រ័យទាក់ទងគ្នាក៏និយាយជាភាសាស្អៀង ប៉ុន្តែភាសាស្អៀងនិយាយមិនដូចគ្នាទេ (និយាយទៅតាមតំបន់)។

កាលពីកុមារភាពខ្ញុំមិនបានរៀនសូត្រទេ ព្រោះកាលនោះរៀននៅវត្តកន្ទួត។ ក្មេងប្រុសបានរៀនសូត្រច្រើនជាងក្មេងស្រីដោយសារតែក្មេងស្រីឪពុកម្តាយប្រើឱ្យមើលប្អូន និងធ្វើកិច្ចការផ្ទះ។ ប្រសិនបើជាដើរពីភូមិល្ហាទៅវត្តកន្ទួតប្រហែលជាដើរមួយម៉ោងកន្លះបានដល់ ហើយភាគច្រើនប្រុសៗទៅរៀនធ្វើជាកូនសិស្សលោកតែម្តង។ ខ្ញុំនៅផ្ទះជួយឃ្វាល

គោ និងមើលប្អូនៗ ក្រៅពីនេះ ខ្ញុំជួយជម្រះស្មៅចម្ការនៅភូមិល្វា។ ចម្ការម្ដាយខ្ញុំដាំតែដំណាំស្រូវគ្មានដាំដំណាំអ្វីផ្សេងទេ។

សម័យសាធារណរដ្ឋខ្មែរ ឬ លន់ នល់ ខ្ញុំធំដឹងក្ដីហើយ ពេលនោះខ្ញុំក៏ឃើញមានកងទ័ពធីវគី និងកងទ័ពយួនវៀតកុង បានចូលមកដល់ក្នុងភូមិល្វាលើ។ បន្ទាប់មក ទើបមានទាហានអាមេរិកាំងចូលមកតាមក្រោយៗ រួចមានយន្តហោះទម្លាក់គ្រាប់បែកពេញភូមិ។ នៅភូមិបេងកោង គ្រាប់បែកបានបន្តឱ្យឪពុករបស់បង យ៉ម បានស្លាប់។ ទាហានអាមេរិកមាឌធំៗ ដែលស្លៀកពាក់ចម្រុះពណ៌ ខ្លះសម្បុរខ្មៅ ស និងជិះរថក្រោះពេញភូមិ គួរឱ្យខ្លាចៗ ចំណែកយួនវៀតកុង ស្លៀកពាក់ខៀវ ឬ ពណ៌ស្វាបសេករស់នៅពួនតាមព្រៃ។ កាលណោះឪពុកម្ដាយខ្ញុំមានកូនធម៌ម្នាក់ឈ្មោះលឿង ជាពេទ្យរបស់វៀតកុង។ លឿងស្រលាញ់រាប់អានជាមួយគ្រួសារខ្ញុំណាស់ ដូចបងប្អូនបង្កើតឱ្យតែពេលមានបុណ្យទានដឹងតែយកអន្សមមកជូន។

ឆ្នាំ១៩៧៤ ក្នុងភូមិខ្ញុំរស់នៅអង្គការចាប់ផ្ដើមរៀបចំឱ្យប្រជាជនធ្វើស្រែបែបប្រវាស់ដៃគ្នា។ ប្រជាជនក្នុងភូមិអាចប្រមូលផលទុកដាក់ក្នុងជង្រុករៀងខ្លួនបាននៅឡើយ។ ចំណែក ការហូបចុកវិញគឺគ្រប់គ្រាន់ ព្រោះហូបបាយតាមផ្ទះរៀងៗខ្លួន។ ចូលមកឆ្នាំ១៩៧៥ ពេលដែលខ្មែរក្រហមចាប់ផ្ដើមប្រមូលទ្រព្យសម្បត្តិដាក់ជារួមៗ ប្រជាជននៅក្នុងភូមិទាំងអស់ចាប់ផ្ដើមធ្វើការងារជារួម មានរោងបាយមួយរួមៗ ប្រជាជនទាំងអស់ត្រូវបំពេញការងារ តាមអង្គការចាត់តាំង។

ខ្ញុំត្រូវបានអង្គការជម្លៀសទៅនៅភូមិចង្កឹកណ្ដាល ដោយសារតែភូមិល្វាលើនេះតូចពេក។ ផ្ទះខ្ញុំត្រូវបានអង្គការរើធ្វើជាជង្រុកស្រូវសម្រាប់ភូមិចង្កឹកណ្ដាល។ ខ្ញុំត្រូវអង្គការផ្ដល់តួនាទីឱ្យដើររកបន្លែជាមួយចាស់ៗ រួចប្រគល់ឱ្យខាងចុងភៅសហករណ៍។ ខ្ញុំដើររកបន្លែដីកទំពាំង បេះស្លឹកសាវម៉ាវ និងរកបន្លែព្រោងៗ រួចពីដើររកបន្លែខ្ញុំត្រូវទៅស្ទូងដកតាមបទបញ្ជាអង្គការ។ ស្ថិតនៅភូមិចង្កឹកណ្ដាល ខ្ញុំទទួលបានរបបអាហារហូបគ្រប់គ្រាន់ ពេលខ្លះបានហូបបាយដល់ទៅបីពេល។ ប្រជាជនណាដែលមានកូនតូចៗ ឬក៏កូនខ្ចីអង្គការទុកបាយឱ្យកូនក្មេង សម្រាប់ហូបពេលយប់បន្ថែមទៀត។ ខ្ញុំនៅភូមិចង្កឹកណ្ដាលបាន២ឆ្នាំ រួចខ្ញុំចេញទៅនៅស្រែតាពេជ្របានកន្លះឆ្នាំ។ នៅស្រែតាពេជ្រ ខ្ញុំមានតួនាទីគាស់ស្រែ។ ក្រោយមកទៀត អង្គការជម្លៀសខ្ញុំចេញពីស្រែតាពេជ្រទៅស្វាយជ្រះ។ នៅស្វាយជ្រះ ពេលដែលខ្ញុំទៅដល់ដំបូងគឺឃើញសុទ្ធតែព្រៃ។ ខ្ញុំមានតួនាទីជាកងចល័ត ហើយការហូបចុកពិបាកណាស់។ រាល់ពេលព្រឹកឡើងមុនចុះទៅធ្វើការ គឺអង្គការត្រូវហៅមកប្រជុំ និងមានឈ្លបខ្មែរក្រហមចាប់អ្នកភូមិចងស្លាបសេកនៅពេលប្រជុំ និងវាយរួចកប់ទាំងរស់។ ដើម្បីឱ្យសមមិត្តដែលចូលរួមប្រជុំបានឃើញហើយកុំឱ្យយកគំរូតាម។ ខ្ញុំចាំបានថាអង្គការចោទអ្នកទាំងនោះថា "ក្បាលយួនខ្លួនខ្មែរ"។

បន្ទាប់មកក្រុមមជ្ឈិមចូលមកបានចាប់ប្រធានក្រុមប្រធានសហករណ៍ ប្រធាន"ក" ប្រធាន"ខ" យកទៅវាយចោលនៅខាងស្នួល។ បងប្រុសខ្ញុំម្នាក់ត្រូវបានអង្គការបាញ់ទម្លាក់ទឹក នៅជ្រីវ (ព្រំប្រទល់ស្រុកមេមត់ និង ស្រុកស្នួល) ដោយសារតែអង្គការប្រឡំឈ្មោះ។ បុគ្គលដែលពួកមជ្ឈិមតាមរកគាត់ឈ្មោះ ងិ ត្រូវជាបងជីដូនមួយ ដោយសារតែរត់ចេញពីជួរ។ ប៉ុន្តែបែរជាទៅចាប់បងប្រុសខ្ញុំឈ្មោះរិក ធ្វើជាទាហាននៅកូនក្រពើទៅវិញ។ បងប្រុសម្នាក់ទៀតស្លាប់ដោយសារតែការហូបចុកមិនគ្រប់គ្រាន់ និងធ្វើការហួសកម្លាំងស្លាប់នៅស្វាយជ្រះ ចំណែកឪពុកខ្ញុំស្លាប់នៅតំបន់ម្លេចៗ ខ្ញុំចេញពីម្លេចមកនៅភូមិជើងឃ្លូបានជួបម្ដាយខ្ញុំ ដែលកំពុងដេកឈឺនៅលើកន្ទេល និងមានប្អូនប្រុសខ្ញុំម្នាក់ មិនទាន់មានអាយុ៣ខួប។ ដោយភាពចលាចលប្រជាជនភូមិជើងឃ្លូបានរត់អស់ នៅសល់តែខ្ញុំជាមួយម្ដាយ និងប្អូនប្រុស។ ម្ដាយខ្ញុំបានប្រាប់ថា «នាំប្អូនរត់ជាមួយអ្នកភូមិទៅកូន ទុកម៉ែនៅទីនេះហើយ ម៉ែដឹងតែមិនរស់ទេ»។ ខ្ញុំក៏បាននាំប្អូនប្រុសរត់ រួចបានផ្ញើប្អូនប្រុស

ជាមួយពូម៉ុងសិន ហើយខ្ញុំត្រឡប់មកគ្រាម្តាយៗ ខ្ញុំបានគ្រាម្តាយទៅដល់ភូមិស្រែចារ ស្រាប់តែមានទាហានរំដោះបានបុកចូលមកបាញ់គ្នាជាមួយទាហានខ្មែរក្រហមៗ ម្តាយខ្ញុំបានដេញខ្ញុំឱ្យរត់ទៅរកប្អូនៗ អំឡុងពេលនោះ ខ្ញុំពិតជាពិបាកសម្រេចចិត្តណាស់ ព្រោះខ្លួនមានតែមួយមិនដឹងត្រូវធ្វើយ៉ាងណា ម្ខាងជាម្តាយ ហើយម្ខាងទៀតត្រូវជាប្អូនៗ ប៉ុន្តែដោយសារតែម្តាយខ្ញុំបានដេញខ្ញុំម្តងហើយម្តងទៀត ទើបខ្ញុំបង្ខំចិត្តទុកម្តាយនៅភូមិស្រែចារ ដើម្បីធ្វើដំណើរមករកប្អូនៗ ខ្ញុំមករកប្អូនប្រុសហើយក៏សម្រេចចិត្តត្រឡប់ទៅរកម្តាយវិញៗ ក្នុងចិត្តខ្ញុំគិតថាទោះស្លាប់ក៏ត្រូវទៅជួបម៉ែវិញៗ ស្របពេលជាមួយគ្នាដែរ ទាហានរំដោះបានមកដល់ល្មមៗ ខ្ញុំរកប្អូនឃើញរួចបានពប្អូនទៅរកម្តាយវិញៗ

ខ្ញុំបានពប្អូនប្រុសខ្ញុំមករកម្តាយរបស់ខ្ញុំវិញ ហើយមានទាហានយួន៣-៤នាក់ជួយស្វែងរកៗ ខ្ញុំរកឃើញម៉ែ តែម៉ែខ្ញុំបានស្លាប់បាត់ទៅហើយ ហេតុនេះទាហានរំដោះបានជួយខ្ញុំកប់សពម៉ែខ្ញុំនៅភូមិដូនមាៗ







ឧបករណ៍នេសាទ និងប្រើប្រាស់ប្រចាំថ្ងៃរបស់ជនជាតិស្ទៀង នៅឃុំទន្ទូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំៗ
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សា អែស៊ះ ៖ បើមានសំឡេងក្មេងយំ នឹងត្រូវដាក់គ្រាប់បែកកម្ទេចទាំងទូក

**មីន សាណាស់**

ឆ្នាំ១៩៧៣ ជនជាតិចាមចាប់ផ្ដើមឡើងតវ៉ាប្រឆាំងនឹងការគ្រប់គ្រងរបស់កងទ័ពខ្មែររំដោះ (ខ្មែរក្រហម) ដែលបានធ្វើការគាបសង្កត់លើជំនឿសាសនា និងការអនុវត្តប្រពៃណី វប្បធម៌តាមសហគមន៍ ដូចជាការថ្វាយបង្គំក្នុងមួយថ្ងៃប្រាំដង និងការសូត្រគម្ពីរកូអានជាដើម។ ចាប់ពីដើមខែវិច្ឆិកា ឆ្នាំ១៩៧៣ មកដល់ពាក់កណ្ដាលឆ្នាំ១៩៧៤ ជនជាតិចាមយ៉ាងហោចណាស់ ៣០០ នាក់ ក្នុងស្រុកក្រូចឆ្មារ ត្រូវកងទ័ពរំដោះចាប់ខ្លួន។ អ្នកដែលត្រូវចាប់ គឺសុទ្ធតែជនជាតិចាមដែលមានចំណេះដឹងជ្រៅជ្រះ ជាមេដឹកនាំសាសនា ជាពិសេសគឺជាតួន (គ្រូ) បង្រៀនផ្នែកគម្ពីរកូអាន និងអ្នកដែលមានធនធាន អ្នកជំនួញក្នុងសហគមន៍។ ឆ្នាំ១៩៧៥ ការកំណត់មុខសញ្ញាបំផ្លាញជីវិតជនជាតិចាមចាប់ផ្ដើមមានជាប្រព័ន្ធយ៉ាងពិតប្រាកដ។ ហេតុការណ៍ទាំងនេះធ្វើឱ្យប្រជាជនចាម ក្នុងភូមិស្វាយឃ្លាំង មានការភ័យខ្លាច និង សម្រេចចិត្តងើបបះបោរ ទាំងដឹងហើយថាគ្មានអាវុធទំនើបអ៊ីតទល់ជាមួយកងទ័ពខ្មែរក្រហម គឺមានតែកាំបិត និង ពូថៅ។ ក្រោយការបះបោររបស់ជនជាតិចាម ក៏មានការបង្ក្រាបភ្លាមៗពីកងទ័ពខ្មែរក្រហម។ ភូមិស្វាយឃ្លាំងទាំងមូលត្រូវលិចលង់ទៅដោយថ្លុកឈាម។ បន្ទាប់ពីនេះយន្តការរបស់ខ្មែរក្រហមគឺមិនបានបញ្ឈប់ការកម្ទេចលើជនជាតិចាមនោះឡើយ។ ការចាប់ជនជាតិចាមយកទៅសម្លាប់កាន់តែមានភាពព្រៃផ្សៃឡើង និងឈានទៅដល់ការចាប់បំបែកប្រជាជនចេញពីសហគមន៍របស់ខ្លួន កុមារត្រូវបានបំបែកចេញទៅរស់នៅតាម



សា អែស៊ះ និង ចៅប្រុស សព្វថ្ងៃរស់នៅភូមិទី៥ ឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ។ ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

កងផ្សេងៗ ហាមមិនឱ្យប្រើប្រាស់ភាសាចាម បំបាត់ទំនៀមទម្លាប់ និងសាសនាអ៊ិស្លាម។ ស្ថិតក្នុងការកំណត់និយមន័យ អំពើប្រល័យពូជសាសន៍ ក្នុងមាត្រា ទី២ ដែលបានអនុម័ត នាថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៤៨ នៃអនុសញ្ញាអន្តរជាតិស្តីពីការបង្ការ និងផ្ដន្ទាទោសបទឧក្រិដ្ឋប្រល័យពូជសាសន៍។ អត្ថន័យពាក្យការប្រល័យពូជសាសន៍គឺជាអំពើទាំងឡាយណា ដែលមានចេតនាបំផ្លាញទាំងស្រុងឬមួយផ្នែកនៃក្រុមជាតិមួយ ជនជាតិ

មួយ ពូជសាសន៍ណាមួយ ឬក្រុមសាសនាណាមួយ ដូចជា៖ ការសម្លាប់សមាជិកក្នុងក្រុមណាមួយ, បង្កការខូចខាតផ្នែកសរីរាង្គកាយ ឬ ផ្នែកសតិបញ្ញាដល់សមាជិកក្នុងក្រុមណាមួយ, ដាក់បន្ទុំនូវវិធានការនានា ដូចជាឃាត់មិនឱ្យមានការបង្កកំណើតទារកក្នុងក្រុងណាមួយ, ការចាប់ជម្លៀសកុមារដោយបង្ខំពីក្រុមមួយទៅក្រុមមួយទៀត និងចេតនាក្នុងការបំផ្លិចបំផ្លាញរូបរាងកាយក្រុមទាំងមូល ឬក៏មួយផ្នែកណាមួយ។

ជនរងគ្រោះនៃការជម្លៀសដោយបង្ខំ ក្រោយពីព្រឹត្តិការណ៍បង្ក្រាបការបះបោរជនជាតិចាម ក្នុងឃុំស្វាយឃ្លាំង ឈ្មោះ សា អែស៊ិះ ភេទស្រី អាយុ៥៨ឆ្នាំ (២០២១) កើតនៅភូមិស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម។

អែស៊ិះ សព្វថ្ងៃរស់នៅភូមិទី៥ ឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ។ អែស៊ិះ បានរៀបរាប់ពីបទពិសោធន៍ឆ្លងកាត់ក្នុងរបបខ្មែរក្រហម ក្នុងនាមជាក្មេងស្រីជនជាតិចាម ដែលកាលណោះ គាត់ទើបមានអាយុ៨ឆ្នាំ បានរៀបរាប់ថា៖

ខ្ញុំចាំមិនភ្លេច រឿងរ៉ាវក្នុងភូមិមានអ្នកស្លាប់ច្រើន និង សម្បូរដោយឈាម វានៅជាប់ក្នុងអារម្មណ៍ខ្ញុំ។ នៅល្ងាចម៉ោងប្រហែលជា៥ មេឃចាប់ដើមចុះងងឹត តែយើងអាចនៅមើលមុខគ្នាស្គាល់បាន ទោះជាសាកសពដែលបានស្លាប់ និងអ្នករបួសដែលខ្លួនពោរពេញទៅដោយឈាម។ ក្រុមទាហានទាំងនោះបានស្រែកឱ្យគ្រួសារខ្ញុំ ត្រូវដើរជាជួរតម្រង់ទៅផ្លូវខាងមុខ (ផ្លូវតាមដងទន្លេ)។ ប្រជាជនទូទាំងភូមិត្រូវនៅលើផ្លូវតែមួយ និងឈរជាជួរ តែមួយជួរប៉ុណ្ណោះ ថែមមានទាំងអ្នករបួសដែលត្រូវគ្រាប់កាំភ្លើង ឈាមនៅហូរចេញពីខ្លួនមកមិនឈប់ ត្រូវបានសាច់ញាតិសែងយកទៅតាម។ ខ្ញុំមើលទៅឃើញមនុស្សឈរតម្រង់ជួរឡើងវែង ដើម្បីត្រៀមខ្លួនស្តាប់បញ្ជាទាហាន ដែលមានកាំភ្លើងក្នុងដៃ និង គិតតែពីស្រែកស្តីឱ្យយើង។ គ្រួសារខ្ញុំមានគ្នា៦នាក់ រួមទាំងឪពុកម្តាយខ្ញុំ ដែលត្រូវទាហានទាំងអស់នោះយកមកដាក់ឃុំឃាំងនៅទីរួមស្រុកក្រូចឆ្មារ និង បំបែកដោយយកឪពុកខ្ញុំទៅឃុំក្នុងវត្តកញ្ចក់ ម្តាយខ្ញុំ និងបងប្អូនខ្ញុំទាំងបួនត្រូវដាក់ចូលឃុំឃាំងក្នុង ឡចំហុយថ្នាំកាតាប។ ខ្ញុំនៅក្នុងឡថ្នាំរយៈពេលមួយខែ។ រាល់ពេលថ្ងៃត្រង់ទើបមានកងសន្តិសុខយកទឹកបបរដែលមានរស់ជាតិសាបមកឱ្យហូប។ ខ្ញុំ និងប្អូនប្រុសបន្ទាប់មានការស្រេកឃ្លានយ៉ាងខ្លាំង។ ដោយឃ្លានខ្លាំងពេកបងស្រីខ្ញុំតែងតែលួចបេះចេកខ្ចីដែលធ្លាក់ទងចូលមកក្បែរប្រឡោះជញ្ជាំងឡ។ ពេលអស់ផ្លែចេក គឺយើងនាំគ្នាហូបស្លឹកចេក និង ស្លឹកខ្នុរ ឡើងអស់ពីដើមនៅសល់តែធាង។ បន្ទាប់មកមានកងសន្តិសុខមកសួរនាំពីប្រវត្តិរូប ខ្ញុំចាំសំណួរបានថា តើក្រុមគ្រួសារនេះមានគ្នាប៉ុន្មាននាក់? អ្នកឈ្មោះអ្វី? មានឪពុកឈ្មោះអ្វី? ម្តាយឈ្មោះអ្វី? ក្រុមគ្រួសារធ្វើការអ្វី? រួចអង្គការក៏យកចម្លើយទាំងនោះទៅ។

កន្លងទៅមួយខែ នៅវេលាម៉ោង៨យប់ មេឃធ្លាក់ភ្លៀង កងសន្តិសុខបានស្រែកហៅក្រុមគ្រួសារខ្ញុំឱ្យរៀបចំខ្លួន ផ្លាស់ទៅរស់នៅភូមិថ្មី ព្រោះមានទូកនៅរង់ចាំនៅកំពង់ទឹកជាស្រេច។ ចំណែកបងស្រីខ្ញុំឈ្មោះ សា ហាប់សះ ដែលមានវ័យ១២ឆ្នាំ តែគាត់មានរាងខ្ពស់ គឺកងសន្តិសុខមិនអនុញ្ញាតឱ្យទៅជាមួយឪពុកម្តាយទេ ដោយនិយាយថាត្រូវទៅធ្វើការក្នុងកងចល័តស្រួច ហេតុនេះត្រូវជិះទូកដ្យេងពីគ្នា។ ម្តាយខ្ញុំនៅសរសៃខ្ចី ព្រោះទើបសម្រាលកូនបាន៧ខែ ប្រាំងទន្លេក៏បោកភ្លៀងរងា និងរអិល កងសន្តិសុខស្រុក បានស្រែកខ្លាំងៗថា ឡើងទូកឱ្យលឿន ឡើងឱ្យលឿនៗ។ ខ្ញុំភ័យខ្លាចខ្លាំងណាស់ ជើងរបស់ខ្ញុំលែងទប់លំនឹងបាន និងបានរអិលពីប្រាំងមកដល់មាត់ទឹកទន្លេ។ ខ្ញុំឮសំឡេងឪពុករបស់ខ្ញុំហៅខ្ញុំ ស៊ិះៗៗ ព្រោះគាត់ចាំសំឡេងខ្ញុំស្រែកពេលរអិល។ ខ្ញុំឈឺខ្លួនពេលរអិល តែសប្បាយចិត្តឡើងវិញពេលឮសំឡេងពុក ព្រោះមិនបានជួបគាត់រយៈពេលមួយខែ។ ប្អូនប្រុសខ្ញុំដែលមានអាយុទើបតែ៧ខែបានស្រែកយំ ប្រហែលជាត្រូវអាកាសធាតុត្រជាក់ កងសន្តិសុខទាំងនោះក៏ស្រែកមកថែមថា « សូមឱ្យស្ងាត់ ប្រុសៗឡើងចែវទូកមុខក្រោយ ហើយប្រសិនជាទូកណាមានឮសំឡេង

ក្មេងយំ សូម្បីតែម្នាក់ នឹងត្រូវដាក់គ្រាប់បែកកម្ទេចទាំងទូក»។ ពុំដូច្នេះ ម្ដាយខ្ញុំបានចាប់ប្អូនខ្ញុំផ្ទប់នឹងទ្រូងរបស់គាត់ដើម្បីឱ្យកូនជៀររហូត កុំឱ្យមានសំឡេង និងនិយាយតិចៗមកកាន់ខ្ញុំថា ឱ្យជួយមើលប្អូនបន្ទាប់ដែលកំពុងរងា ព្រោះពុកគាត់ត្រូវបែរទូកបញ្ច្រាស់ខ្សែទឹកហូរខ្លាំងនារដូវទឹកឡើងៗ ផែនការរបស់ខ្មែរក្រហម គឺធ្វើយ៉ាងម៉េចឱ្យមេឃភ្លឺ គឺទូកត្រូវចូលទៅដល់ផ្នែកខាងក្រោយព្រែករកាខ្នុរ ដែលចាស់ៗហៅថា ជន្ទាំង។ ចុះពីទូករួច អង្គការបញ្ជាឱ្យជម្លៀសបន្តដោយថ្មើរជើងទៅមុខទៀត ដោយប្រុសៗត្រូវដើរខាងមុខ បន្ទាប់មកស្ត្រីៗ និងកូនក្មេងត្រូវនៅក្រោយគេបង្អស់។ ខ្ញុំដើរទាំងគ្មានស្បែកជើង និងត្រូវពប្អូនម្នាក់ទៀតនៅលើចង្កេះ សត្វសង្អារខាំ ឈឺចុកក៏មិនហ៊ានស្រែកយំ មានតែបន្ទំដាលោតចុះលោតឡើងដើម្បីឱ្យទាន់អ្នកខាងមុខៗ តាមផ្លូវធ្វើដំណើរគ្រួសារណា ដែលមានជីដូនជីតា ឬឪពុកម្ដាយចាស់ៗដើរមិនរួច ឬ សែងមិនរួច អង្គការសុំឱ្យទុកតាមផ្លូវសិន ចាំអង្គការយកទៅជូន តែអង្គការនិយាយមិនពិត គ្មានគ្រួសារណាបានជួបឪពុកម្ដាយរហូត។ ខ្ញុំត្រូវធ្វើដំណើរបែកពីឪពុកម្ដាយរហូតដល់គោលដៅដែលអង្គការកំណត់ដល់ត្រពាំងព្រីង ស្រុកតំបែរ។

តំបន់ត្រពាំងព្រីង អង្គការចាត់តាំងចំនួនបួនគ្រួសារ ឱ្យរស់នៅក្នុងជង្រុកស្រូវតូចមួយ និងគ្មានសម្ភារប្រើប្រាស់ទាំងអស់។ ក្រោយមកប្រធានភូមិមកចុះឈ្មោះ និងចែកអង្ករឱ្យតាមចំនួនសមាជិកនៃគ្រួសារនីមួយៗ។ ខ្ញុំបានហូបបាយជាមួយអំពិលពិតជាមានរសជាតិឆ្ងាញ់ជាប់មាត់ខ្លាំងណាស់ ព្រោះដោយសារគ្មានបាយហូបរយៈពេលមួយខែកន្លងមកហើយ។ គ្រួសារនីមួយៗ នាំគ្នាដាំបាយហូបឡើងច្រើនកំប៉ុងៗ។ រំលងបានមួយខែ ម្ដាយរបស់ខ្ញុំបានស្លាប់ដោយសារជំងឺគ្រុនចាញ់ប្រហែលជាម៉ោង២យប់។ មុនពេលគាត់ស្លាប់ គាត់បានហៅខ្ញុំ«ស៊ិះៗ ម៉ែប្រហែលជាត្រូវស្លាប់បន្តិចទៀតនេះហើយ ព្រោះម៉ែស្រេកទឹកខ្លាំងណាស់ យកទឹកឱ្យម៉ែមួយដំណក់មក ម៉ែស្រេកទឹកណាស់»។ ខ្ញុំក៏ងើបទៅដាស់ឪពុករបស់ខ្ញុំដែលសម្រាកនៅខាងក្រៅឱ្យមកជួយមើលម្ដាយខ្ញុំ និងប្រាប់គាត់ថាប្រហែលជាម៉ែត្រូវស្លាប់ហើយ។ មិនបានប៉ុន្មាននាទីផង ម្ដាយរបស់ខ្ញុំបានផុតដង្ហើម។ ប្អូនប្រុសខ្ញុំដែលទើបចេះវារ មិនដឹងថាម្ដាយស្លាប់ ក៏វារទៅលើម្ដាយហើយខំប្រឹងបៅដោះទាំងយំ។ ចាប់តាំងពីពេលនោះមក ខ្ញុំត្រូវមានតួនាទីមើលថែប្អូនប្រុសទាំងពីរ។ អង្គការមិនបានឱ្យខ្ញុំធ្វើការអ្វីឡើយ ប៉ុន្តែតួនាទីមើលថែប្អូនតូចៗ ទាំងគ្មានរបបអាហារអ្វីសោះសម្រាប់ខ្ញុំ គឺលើសពីលំបាក ក្នុងការទៅជីកប្រឡាយ លើកទំនប់។ ខ្ញុំត្រូវដាំទឹកបបរ គ្មានសូម្បីអំបិលដាក់ឱ្យប្អូនខ្ញុំបៅបានរស់រានមានជីវិតដល់សព្វថ្ងៃ ប៉ុន្តែប្អូនខ្ញុំនៅតែមានរូបរាងស្គមស្បែកដណ្ដប់ឆ្អឹង។

ប្រហែលជាខែសីហា ក្នុងឆ្នាំ១៩៧៨ ឪពុកខ្ញុំចេញទៅធ្វើការបាត់ កងទ័ពវៀតណាមក៏វាយចូលមកដល់ភូមិត្រពាំងព្រីង និងមានការបាញ់ប្រោះគ្នាទៅវិញទៅមក។ អ្នកភូមិត្រពាំងព្រីងនាំគ្នារត់ចូលព្រៃអស់រលីង នៅសល់តែបងប្អូនខ្ញុំបីនាក់ សំងំពួនក្នុងជង្រុកស្រូវ ព្រោះខ្ញុំមិនដឹងយកប្អូនទាំងពីររត់ដោយរបៀបណា។ ដល់ពេលឪពុកខ្ញុំមកវិញ គាត់ក៏នាំបងប្អូនខ្ញុំត្រឡប់មករកយាយតា ដែលត្រូវអង្គការជម្លៀសចេញពីភូមិស្វាយឃ្លាំង ឱ្យទៅរស់នៅឃុំប៉ើស ស្រុកក្រូចឆ្មារ។ នៅឃុំប៉ើស កាន់តែអត់ឃ្លាន ក្នុងមួយថ្ងៃអង្គការផ្ដល់ឱ្យគ្រាប់ពោតចំនួនមួយផ្ដិល សម្រាប់សមាជិកគ្រួសារខ្ញុំដែលរស់នៅជុំគ្នាជិត៣០នាក់។ ប្រហែលជាខែកញ្ញា ឬខែតុលា ឆ្នាំ១៩៧៨ អង្គការមកហៅឪពុកខ្ញុំឱ្យទៅជួយសាងសង់ផ្ទះប៉ែកលើភ្នំ។ ឪពុករបស់ខ្ញុំដូចដឹងស្ថានភាពមិនស្រួល ក៏សម្រេចចិត្តទុកបីនាក់បងប្អូនខ្ញុំ និងយាយតា។ ចំណែកគាត់ក៏ធ្វើដំណើរតាមអង្គការ ឡើងជិះស្រឡាងដែលរង់ចាំដឹកអ្នកភូមិជាច្រើនទៀតដែលភាគច្រើនជាជនជាតិចាម។ តាំងពីពេលនោះ ខ្ញុំក៏លែងបានឃើញឪពុកខ្ញុំរហូតមកដល់បច្ចុប្បន្ន។

# តួនាទីនីរសារ ក្នុងរបបខ្មែរក្រហម

**ជាវ៉ារដ្ឋ មេត្តា**



កងកុមារបដិវត្តន៍ខ្មែរក្រហម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្នុងរបបខ្មែរក្រហមអង្គភាពនានារបស់មជ្ឈិមបក្ស ភូមិភាគ តំបន់ ស្រុក និង ឃុំ ធ្វើការទំនាក់ទំនងគ្នាតាមរយៈសំបុត្រ។ ទោះបីជាទូរលេខ ពេញនិយមប្រើជាទូទៅសម្រាប់ទំនាក់ទំនងការងារតំបន់ឆ្ងាយៗ ក៏ទូរលេខនិងរបាយការណ៍ដែលមានច្រើនទំព័រ ត្រូវបានផ្ញើតាមរយៈសំបុត្រ ដែលមាននីរសារជាអ្នកចែកចាយ។ សម្រាប់ភូមិភាគ តំបន់ និង ស្រុក សុទ្ធតែមានបណ្តាញនីរសាររបស់អង្គភាពនីមួយៗផ្ទាល់។

មី យ៉ា ភេទស្រី អាយុ៦៥ឆ្នាំ កើតនៅស្រុកព្រៃកប្បាស ខេត្តតាកែវ។ នៅឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ មី យ៉ា ធ្វើជានីរសារនាំសំបុត្រទ័ពទាក់ទងមកខាងមន្ទីរស្រុក ដូចជាឱ្យឃុំជ្រើសរើសទ័ពតាមភូមិ តាមឃុំៗ មី យ៉ា លើកឡើងថា **«ពីមុនជ្រើសរើសពីភូមិឡើងមកឃុំ ដល់ហើយរើសពីឃុំមកភូមិវិញ។ ឃុំណាមួយ រើសយុវជនឡើងមកស្រុក ខ្ញុំគឺជាអ្នកនាំកាន់ក្រដាស (សំបុត្រ) ពីមូលដ្ឋានមក សំបុត្របញ្ជីឈ្មោះយុវជនធ្វើទ័ព ប្រគល់ឱ្យបងណាត ហើយខ្ញុំត្រឡប់មកវិញ។ ជួនកាលស្រុកត្រូវការឱ្យនីរសារពីស្រុកយកលិខិតទៅឱ្យឃុំវិញ មានការអ៊ីមួយខ្ញុំជានីរសារ អ្នកទាក់ទងគ្នាធ្វើរបាយការណ៍ឱ្យខ្ញុំយកមកវិញ»។**

ឌុច ចាន់ថា អាយុ៦២ឆ្នាំ កើតនៅស្រុកបាកាន ខេត្តពោធិ៍សាត់។ នៅឆ្នាំ១៩៧២ ឌុច ចាន់ថា ត្រូវបានជ្រើសរើសចូលបដិវត្តន៍។ ក្រោយមក ឌុច ចាន់ថា ធ្វើពេទ្យ និងបានព្យាបាល លឹម ខាន់ មានតួនាទីជាគណៈតំបន់២។ លឹម ខាន់ បានយក ឌុច ចាន់ថា ឱ្យនៅជាមួយដើម្បីទុកព្យាបាលខ្លួន។ លឹម ខាន់ មាននីរសារចំនួន៣នាក់គឺ១) ឌុច ចាន់ថា មានភារកិច្ចជាអ្នកបើកឡាន និងព្យាបាលជំងឺ។ អ្នកទី២) ភារកិច្ចការពារ និងអ្នកទី៣) ទទួលខាងសេដ្ឋកិច្ច គឺដាំបាយឬភ្លក់ម្ហូបពេលក្រុមរបស់ លឹម ខាន់ មិនដាំខ្លួនឯង។ លឹម ខាន់ បានប្រាប់នីរសារទាំង៣នាក់ថា «ពេលអញទៅដល់ណា អ្នកការពារត្រូវទៅមើលសភាពការណ៍ជុំវិញ ហ្នឹងខ្លាចមានប្រតិកម្មអ្វីមួយ ត្រូវឱ្យអញដឹង។ សេដ្ឋកិច្ចអ្នកដាំបាយ ទឹក បើឯងដាំបាយខ្លួនឯងមិនអីទេ បើមានគេជួយដាំឯងត្រូវភ្លក់មុន ជៀសវាងក្រែងមានគ្រោះថ្នាក់ដល់អញ និងភ្ញៀវឯទៀត»។ ចំណែក ឌុច ចាន់ថា មានតួនាទីបើកឡាន ពេលឈប់សម្រាកត្រូវពិនិត្យមើលឡានមើលប្រេងមើលសាំងមើលកង់ឱ្យបានហ្មត់ចត់ហើយបើ លឹម ខាន់ ឈឺត្រូវព្យាបាលនិងចាក់ថ្នាំឱ្យ។

ឆាយ ស៊ិន អាយុ៦១ឆ្នាំ កើតនៅស្រុកសៀមរាប ខេត្តសៀមរាប។ ឆាយ ស៊ិន ត្រូវបានជ្រើសរើសជានីរសាររបស់ ឆឹង គឺជាគណៈស្រុកចុងកាល់។ ឆាយ ស៊ិនបានរៀបរាប់អំពីតួនាទីរបស់ខ្លួនជានីរសារថា «ខ្ញុំយកសំបុត្រពីស្រុកទៅចែកតាមភូមិមួយចំនួនដូចជាភូមិជើងទៀន ភូមិឆ្លក ភូមិត្រាំកង់ និងភូមិពង្រដោយជិះកង់ផលិតនៅប្រទេសចិន ហើយជួនកាលជិះសេះប្រសិនបើផ្លូវឆ្ងាយហើយមានខ្សាច់ច្រើន។ សំបុត្រនោះគឺត្រូវបិតភ្ជិតដោយមានសរសេរឈ្មោះតំបន់ដែលត្រូវយកទៅប្រគល់នៅពីលើសំបុត្រនោះ»។ ក្រោយពីនីរសារ ឆាយ ស៊ិន ត្រូវបានចាត់តាំងឱ្យធ្វើជាអ្នកយាមគុកនៅវត្តចុងកាល់និងត្រូវចាត់តាំងបន្តទៀតជាអ្នកដាំបាយឱ្យអ្នកទោសហូប។

ទូច ឈាង អាយុ៥៩ឆ្នាំ កើតនៅស្រុកពួក ខេត្តសៀមរាប។ ទូច ឈាង ធ្វើនីរសារ របស់តាប៉េង ដែលជាប្រធានវរសេនាធំ៨១២ ដែលមានបន្ទាយនៅក្បែរវត្តល្អក់ ខេត្តសៀមរាប។ អ្នកនាំសារនៅពេលនោះមានមធ្យោបាយក្នុងការធ្វើដំណើរមានពីរ គឺជិះកង់ និងជិះសេះ។

ញឹក ជិន អាយុ៧២ឆ្នាំ មានស្រុកកំណើត នៅខេត្តព្រៃវែង។ ញឹក ជិនបានរំឭកថា «នៅឆ្នាំ១៩៧៥ ខ្មែរក្រហមចាត់តាំងខ្ញុំឱ្យធ្វើជានីរសារ។ ខ្ញុំត្រូវខ្មែរក្រហមប្រើឱ្យរត់សំបុត្រពីភូមិតាហ៊ីរ ទៅស្រុកទាំងយប់អធ្រាត្រ ពេលនោះខ្ញុំភ័យខ្លាចទាហាន លន់ នល់ បាញ់សម្លាប់ខ្លាំងណាស់ប៉ុន្តែខ្ញុំមិនហ៊ានប្រកែកឡើយ»។

ម៉ិល ឈួន អាយុ៦១ឆ្នាំ កើតនៅស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។ នៅឆ្នាំ១៩៧៥ នៅពេលខ្មែរក្រហមវាយដាច់ទីក្រុងភ្នំពេញខ្មែរក្រហមបានចាត់តាំង ម៉ិល ឈួន ធ្វើជានីរសាររបស់តាប្រាន។ តាប្រាន មានតួនាទីធ្វើជាគណៈស្រុកមកពីភូមិភាគនិរតី។ ការងាររបស់ ម៉ិល ឈួន នៅពេលនោះគឺធ្វើជាអ្នករត់សំបុត្រដោយជិះសេះ និងមានកាំភ្លើងមួយដើមសម្រាប់ការពារខ្លួន។ ម៉ិល ឈួនមិនដែលដឹងអំពីខ្លឹមសារនៅខាងក្នុងសំបុត្រទេ ដោយសារមានការវេចខ្ចប់ស្រោមសំបុត្រយ៉ាងជិតល្អ។ ពេលទំនេរពីការរត់សំបុត្រ ម៉ិល ឈួនធ្វើជាអ្នកដឹកស្បៀងអង្ករពីឃ្លាំងនៅក្នុងស្រុកដាក់តាមសហករណ៍។

មិត្តច្រឹក នីរសារ របស់ សៅ គា ដែលចាត់តាំងសម្រាប់ឱ្យយកព័ត៌មានដែលទទួលបានទាក់ទងទៅកន្លែងនារីយ៉ាននៅតាខ្មៅ និង នារីខុននៅរោងចក្រថ្មពិលចាក់អង្រែ ទៅកន្លែងពេទ្យតំបន់២៥និងសង្កាត់ព្រែកថ្មី ពីកន្លែងនោះផ្ទាល់ដោយក្តាប់សភាពការណ៍ព្រម ទាំងឃ្លាំងសម្ភារដើម្បីលួចបញ្ចេញចែកទៅក្រៅ។

ម៉ែង ហាក់ គឺជាយុទ្ធជននៅក្នុងវរសេនាតូចពិសេស៧០៨ គាត់ត្រូវបានចាត់តាំងឱ្យចាប់ កុយ ធួន លេខាភូមិភាគឧត្តរ ដែលស្នាក់នៅខាងជើងវត្តភ្នំ។ ម៉ែង ហាក់ លើកឡើងថា «ទម្រាំចាប់កុយ ធួន បានត្រូវចំណាយពេលពីរថ្ងៃមួយយប់ពីព្រោះ កុយ ធួន មាននីរសារការពារច្រើនណាស់»។

ភាគច្រើននៃអ្នកសួរចម្លើយ និងអ្នកធ្វើឯកសារធ្លាប់បានចូលរួមធ្វើសង្គ្រាមក្នុងអំឡុងឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ ដោយបម្រើជានីរសារដែលជាការងារប្រកបដោយគ្រោះថ្នាក់និងគួរឱ្យគោរព។

អ្នកភូមិមួយចំនួនថែមទាំងធ្វើជានីរសារឱ្យខ្មែរក្រហមទៀតផង។ មាន អេន ដែលជាអ្នកភូមិម្នាក់នៅស្រុកអន្លង់វែងបានរំឭកថា៖ អ្នកភូមិបានជួយរៀបចំដំណើររបស់ខ្ញុំទៅកាន់ភ្នំដងរែក។ ខ្មែរក្រហមមានចារកិច្ចរបស់ខ្លួននៅក្នុងភូមិ។ ប្រសិនបើកងទ័ពវៀតណាមចុះមកពិនិត្យ នៅក្នុងភូមិនៅម៉ោង១១រសៀល អ្នកភូមិនឹងឱ្យការណ៍ទៅខ្មែរក្រហមដែលនឹងចាកចេញពីភូមិនៅម៉ោង១២ ថ្ងៃត្រង់ដើម្បីចៀសវាងពីការប្រឈមមុខដាក់គ្នាជាមួយកងទ័ពវៀតណាម។

តាមរយៈបទសម្ភាសន៍ និងប្រភពឯកសារផ្សេងៗ បានឱ្យដឹងថាតួនាទីនីរសារគឺធ្វើតាមការចាត់តាំងរបស់អង្គភាពជាក់ស្តែង និងផ្សេងៗគ្នាដូចជាធ្វើជាអ្នករត់សំបុត្រ យកការណ៍ បើកឡាន អ្នកព្យាបាលជំងឺ (ប្រសិនជាចេះ) អ្នកការពារ អ្នកដាំបាយបុគ្គលិកបាយម្ហូប ជាអ្នកយាមគុក និងដឹកស្បៀងអង្ករពីឃ្លាំងនៅស្រុកដាក់តាមសហករណ៍ ដែលការងារមួយចំនួនប្រកបដោយគ្រោះថ្នាក់ដល់អាយុជីវិតព្រមទាំងខ្មែរក្រហមគិតថាជាការងារគួរឱ្យគោរព។



កងកុមារនិងយុវជនបដិវត្តន៍ខ្មែរក្រហម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សេង អួន ពេទ្យកងទ័ពតំបន់២២ ក្នុងរបបខ្មែរក្រហម

**ស៊ាង ចិន្តា**

ខ្ញុំឈ្មោះ សេង អូន អាយុ៧៥ឆ្នាំ រស់នៅក្នុងភូមិទី៧ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ខ្ញុំរៀបការប្តីឈ្មោះ ស៊ាន ដៃ ដែលធ្វើការជានីរសារកងទ័ពតំបន់២២ នៅឆ្នាំ១៩៧៨។ ខ្ញុំមានកូនប្រុសស្រីសរុបចំនួន៤នាក់។ ឪពុកខ្ញុំឈ្មោះ សេង និងម្តាយឈ្មោះ ស្រ៊ី។ ខ្ញុំមានបងប្អូនចំនួន៦នាក់។ នៅវ័យកុមារ ខ្ញុំចូលរៀននៅសាលាបឋមសិក្សាវត្តកណ្តាលកោះ និងរៀនបានត្រឹមថ្នាក់ទី៧ចាស់។ នៅពេលនោះ ខ្ញុំត្រៀមប្រឡងចូលរៀនថ្នាក់វិទ្យាល័យប៉ុន្តែមិនដាប់នោះឡើយ។ ខ្ញុំឈប់រៀននៅអាយុ១៣ឆ្នាំ។ ប្រមាណជាបីខែបន្ទាប់ពីមានរដ្ឋប្រហារ លន់ នល់ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ បាតុកម្មចូលរួមដោយអ្នកភូមិបានកើតឡើង ដើម្បីទាមទារឱ្យសម្តេចឪមកគ្រប់គ្រងអំណាចឡើងវិញ។ នៅពេលនោះ ខ្ញុំនៅជួយការងារឪពុកម្តាយនៅផ្ទះនៅឡើយ។



សេង អូន អាយុ៧៥ឆ្នាំ អតីតពេទ្យកងទ័ពខ្មែរក្រហម រស់នៅក្នុងភូមិទី៧ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅឆ្នាំ១៩៧១ ការផ្ទុះអាវុធ និងការផ្លោងគ្រាប់រវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហមបានចាប់ផ្តើម។ នៅចុងឆ្នាំ១៩៧១ ភូមិរបស់ខ្ញុំត្រូវបានរំដោះដោយកងទ័ពរំដោះខ្មែរក្រហម។ បន្ទាប់មកខ្ញុំបានស្ម័គ្រចិត្តចូលបដិវត្តន៍ និងស្នើសុំធ្វើជាពេទ្យកងទ័ពដែលជាអាជីពខ្លួនស្រលាញ់។ នៅពេលនោះមានយុវជន និងយុវនារីក្នុងភូមិជាច្រើនបានចូលរួមជាមួយបដិវត្តន៍។

ខ្ញុំ និងសមមិត្តប្រមាណ២០នាក់ផ្សេងទៀតត្រូវបានបញ្ជូនទៅរៀនវគ្គបណ្តុះបណ្តាលរយៈពេល៤ខែគឺ ចាប់ផ្តើមពីការដើរតាមកងទ័ពរំដោះខ្មែរក្រហម ការរៀនមេរៀនទ្រឹស្តី និងចុះអនុវត្តតាមមូលដ្ឋាននៅក្នុងព្រៃជិតព្រំដែនវៀតណាម។ បន្ទាប់ពីបញ្ចប់វគ្គបណ្តុះបណ្តាលមក ពេទ្យកងទ័ពរបស់ខ្ញុំត្រូវបានបញ្ជូន ទៅតាមសមរភូមិនានាដែលកងទ័ពរំដោះខ្មែរក្រហមឈរជើងត្រៀមវាយយកទីតាំងបន្ទាយទាហាន លន់ នល់។ សមរភូមិដែលខ្ញុំចាំមិនភ្លេចនោះគឺ សមរភូមិព្រែកតាមាក់ និងសមរភូមិអរិយក្សត្រ។ បន្ទាប់ពីវាយបែកបន្ទាយទាហាន

លន់នល់ ខ្ញុំ និងសមមិត្តពេទ្យផ្សេងទៀតទទួលបានសម្ភារយោធាមួយចំនួន។ ខ្ញុំ ទទួលបានកាបូបស្ពាយយោធាអាមេរិកមានសញ្ញា “USA” ដើម្បីដាក់សម្ភារពេទ្យរបស់ខ្ញុំ។ ខ្ញុំបានបន្តប្រើប្រាស់កាបូបស្ពាយយោធាអាមេរិករហូតដល់ឆ្នាំ១៩៧៩។

បន្ទាប់ពីកងទ័ពរំដោះខ្មែរក្រហមវាយបែកទីក្រុងភ្នំពេញនៅឆ្នាំ១៩៧៥ ពេទ្យកងទ័ពរបស់ខ្ញុំត្រូវបានបញ្ជូនមកតាមការដ្ឋាន។ ខ្ញុំធ្វើជាពេទ្យកងទ័ពតំបន់២២។ ខ្ញុំត្រូវធ្វើការដូចកងចល័តផ្សេងទៀតដែររួមមានដកស្ទូង រែកដី និងជីកប្រឡាយជាដើម។ អាហារហូបចុកគឺគ្រប់គ្រាន់ ពីព្រោះកងទ័ព តំបន់២២ គឺមានដីដាំដំណាំ និងកន្ទែងចិញ្ចឹមមាន់ ទា ត្រី និងជ្រូកដើម្បីផ្គត់ផ្គង់អង្គភាពរបស់ខ្លួន។ នៅពេលខ្លះ ចុងភៅកាប់ជ្រូកធ្វើម្ហូបសម្រាប់ហូបក្នុងអង្គភាព។

នៅឆ្នាំ១៩៧៦ អង្គភាពកងទ័ពតំបន់២២ ត្រូវបានផ្លាស់ទៅធ្វើពាងទឹកនៅពារាំង។ ខ្ញុំក៏ទៅជាមួយអង្គភាពដែរ។ នៅឆ្នាំ១៩៧៧ និង ឆ្នាំ១៩៧៨ ប្រធានអង្គភាព និងប្រធានក្រុមនៅភូមិភាគបូព៌ាត្រូវបានកងទ័ពខ្មែរក្រហមមកពីភូមិភាគនិរតីចាប់ខ្លួនយកទៅសម្លាប់ជាច្រើន។ ខ្ញុំមានអារម្មណ៍តក់ស្លុតយ៉ាងខ្លាំង។

នៅចុងឆ្នាំ១៩៧៨ ខ្ញុំត្រូវអង្គការរៀបចំឱ្យមានប្តី ដែលមានតួនាទីជានីសារកងទ័ពតំបន់។ នៅដើមឆ្នាំ១៩៧៩ ខ្ញុំនិងប្តីបានបេវទូកវិលត្រឡប់មកភូមិវិញ និងរួចផុតពីការសម្លាប់របស់កងទ័ពខ្មែរក្រហមមកពីភូមិភាគនិរតី បន្ទាប់មកកងទ័ពវៀតណាមបានចូលមកដល់រំដោះប្រទេសបានទាំងស្រុង។



នារីពេទ្យបដិវត្តន៍ខ្មែរក្រហមចុះជួបប្រជាជននៅតាមផ្ទះ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ឡេង ឈៀង ៖ អតីតយោធាខ្មែរក្រហម យាមព្រំដែនខេត្តស្វាយរៀង

**ចាន់ ណារិទ្ធ**



ឡេង ឈៀង អាយុ៦៧ឆ្នាំ សព្វថ្ងៃរស់នៅភូមិដីក្រហម ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បន្ទោះឆ្នាំ១៩៧៦ ដល់ឆ្នាំ ១៩៧៩ ឈៀង និងកងទ័ពជាច្រើនត្រូវបានខ្មែរក្រហមបញ្ជូនឱ្យមកការពារព្រំដែនខេត្តស្វាយរៀង និងធ្លាប់បានវាយបណ្ដេញកងទ័ពវៀតណាម ឱ្យរត់ធ្លាក់រហូតដល់ខេត្តហាទៀង និងតៃនីញ ប្រទេសវៀតណាម។

***ឈៀងបាននិយាយរៀបរាប់ពីការតស៊ូរបស់ខ្លួនដូចខាងក្រោម៖***

ឡេង ឈៀង ភេទប្រុស អាយុ៦៧ឆ្នាំ សព្វថ្ងៃមានមុខរបរធ្វើចម្ការ។ ឈៀង កើតនៅភូមិអូរក្រសារ ឃុំកែប ស្រុកកំពត ខេត្តកំពត។ បច្ចុប្បន្នរស់នៅភូមិដីក្រហម ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ឈៀង មានឪពុកឈ្មោះ នាក់ គេន (ស្លាប់ក្នុងឆ្នាំ១៩៧០ ដោយសារជំងឺបុសដូងបាត) និងម្ដាយឈ្មោះ ប៉ូ ញែត (ស្លាប់ដោយសារជំងឺចាស់ជរា)។ ឈៀង មានបងប្អូនចំនួន៧ នាក់ ( ប្រុស ៦នាក់ និងស្រី១នាក់ ) បងប្អូន ឈៀង បានបាត់បង់ជីវិតចំនួន៣នាក់ ( បងទី១ទី២ ស្លាប់ពេលដែលវាយជាមួយទាហាន លន់ នល់ ក្នុងឆ្នាំ១៩៧៥ និងប្អូនស្រីម្នាក់ស្លាប់ដោយសារពុលពងត្រីកំពត)។ ឈៀង ជាកូនទី៦នៅក្នុងគ្រួសារ។ ឈៀង មានប្រពន្ធឈ្មោះ អោម រឿន អាយុ៦៨ឆ្នាំ សព្វថ្ងៃមានមុខរបរធ្វើចម្ការ។ ឈៀង មានកូនចំនួន៥នាក់ ( ប្រុស២នាក់ និង ស្រី៣នាក់) ។

កាលពីក្មេង ឈៀង ចូលរៀននៅសាលាក្នុងវត្តចរិយាវង្ស បានត្រឹមថ្នាក់ទី២សង្គមចាស់ និងមានគ្រូបង្រៀនឈ្មោះ គ្រូថុល។ ឈៀង ចូលរៀនដំបូងនៅអាយុ១២ឆ្នាំ។ ឈៀង ឈប់រៀនដោយសារតែប្រទេសជាតិធ្លាក់ចូលក្នុងសង្គ្រាមស៊ីវិល បន្ទាប់ពីលោកសេនាប្រមុខលន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់សម្ដេចព្រះនរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ហើយគ្រូៗមួយចំនួនឈប់បង្រៀនដើម្បីចូលបម្រើកងទ័ព។

ឆ្នាំ១៩៧៣ យន្តហោះជាច្រើនគ្រឿងហោះមកទម្លាក់គ្រាប់បែកបេ៥២ និងគ្រាប់បែកចង្កោមយ៉ាងសន្ធឹកសន្ធាប់មកលើភូមិអូរក្រសារ។ ប្រជាជននៅក្នុងភូមិជាច្រើនត្រូវបានស្លាប់ និងផ្ទះសម្បែងត្រូវបានឆាបឆេះគ្មានសល់។ ការទម្លាក់គ្រាប់បែកបេះតែ

បន្តខ្លាំងឡើងៗ ជារៀងរាល់ថ្ងៃ។ ម្តាយ ឈៀង បានសម្រេចចិត្តចាកចេញពីភូមិអូរក្រសារ ទៅរស់នៅចម្ការលើជាបណ្តោះអាសន្ន ព្រោះនៅចម្ការលើ ម្តាយ ឈៀង មានផ្ទះដែលបានសាងសង់ទុកមួយៗ នៅពាក់កណ្តាលឆ្នាំ១៩៧៣ ការទម្លាក់គ្រាប់បែក នៅតែទម្លាក់ឥតឈប់ឈរ ម្តាយ ឈៀង បានបញ្ជូន ឈៀង និងបងៗចេញពីចម្ការលើឱ្យទៅរស់នៅភូមិក្រាំងលាវ ស្រុកឈូក ខេត្តកំពតវិញ ព្រោះនៅទីនោះមិនសូវមានការទម្លាក់គ្រាប់បែក។

ឆ្នាំ១៩៧៤ ដោយសភាពការណ៍ស្ងប់ស្ងាត់ ឈៀង និងគ្រួសារបានផ្លាស់ចេញពីភូមិក្រាំងលាវ ស្រុកឈូក មករស់នៅភូមិកំណើតវិញ។ ឈៀង ចូលមករស់នៅក្នុងភូមិបានរយៈពេលមួយខែចាប់ផ្តើមមានកងទ័ពខ្មែរក្រហមរាប់រយនាក់ចូលមកឃោសនាក្នុងភូមិ។ ថ្នាក់ដឹកនាំដែលចូលមកឃោសនាដំបូងឈ្មោះ តា វ៉ែន ។ តា វ៉ែន បានអំពាវនាវឱ្យប្រជាជនចូលរួមជាមួយកងទ័ពរណសិរ្ស ដើម្បីវាយផ្តួលរបបលោកសេនាប្រមុខលន់ នល់។ បន្ទាប់ពីឃោសនាមិនបានប៉ុន្មានថ្ងៃ ឈៀង បានសម្រេចចិត្តចាកចេញពីក្រុមគ្រួសារ ដើម្បីចូលរួមជាមួយកងទ័ពរណសិរ្ស។ នៅពេលចូលបម្រើកងទ័ពដំបូង តា វ៉ែន បានចាត់តាំងឱ្យ ឈៀង ធ្វើឈ្លបយាមការនៅក្នុងភូមិបានរយៈពេលមួយសប្តាហ៍ ទើបផ្លាស់ទៅទ័ពស្រុកវិញ។ នៅពាក់កណ្តាលឆ្នាំ១៩៧៤ តា វ៉ែន ចាប់ផ្តើមជ្រើសរើសកងទ័ពថ្មីម្តងទៀត។ ឈៀង ត្រូវបានតា វ៉ែន ជ្រើសរើសឱ្យចូលបម្រើកងទ័ពនៅក្នុងកងពលលេខ២ប្រចាំភូមិភាគនិរតី។ បន្ទាប់ពីចូលបានមួយរយៈ តា វ៉ែន បានបញ្ជូនឱ្យកងពលលេខ២ រៀបចំកម្លាំងដើម្បីទៅវាយជាមួយទាហាន លន់ នល់ ដែលមានទីតាំងក្នុងខេត្តកំពត ស្រុកកំពង់សិលា និងខេត្តកោះកុង។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានវាយរំដោះទីក្រុងភ្នំពេញ ហើយបានទទួលបានជ័យជម្នះលើរបបសាធារណរដ្ឋខ្មែរ និងបានគ្រប់គ្រងទូទាំងប្រទេសកម្ពុជា។ បន្ទាប់ពីទទួលបានជ័យជម្នះកងពលលេខ២ បានផ្លាស់ចេញពីកំពតមកកាន់ខេត្តតាកែវ។ មកដល់ខេត្តតាកែវ តា វ៉ែន បានបំបែក ឈៀង និងកងទ័ពមួយចំនួនដែលមានគ្នាប្រហែល១០០នាក់ ចេញពីកងពលលេខ២ ឱ្យទៅកាន់កងពលតូច ដែលដឹកនាំដោយ អៀង ផាន ដើម្បីឱ្យនៅយាមការតាមព្រំដែនខេត្តតាកែវ។ ពេលដែលយាមការនៅតាមព្រំដែនខេត្តតាកែវ សម្រាប់អាហារហូបចុករបស់ ឈៀង គឺហូបបានគ្រប់គ្រាន់ មិនមានការខ្វះខាតអ្វីទេ ពេលឈឺថ្កាត់ម្តងៗគឺមានពេទ្យចាំព្យាបាល។ ឈៀង រស់នៅតាកែវបានរយៈពេល១ឆ្នាំ បានអង្គការដកទៅវាយជាមួយកងទ័ពវៀតណាមនៅតាមព្រំដែនខេត្តស្វាយរៀង។ កងទ័ព ឈៀង បានវាយបណ្តេញកងទ័ពវៀតណាមរត់ធ្លាក់រហូតមកដល់ខេត្តហាទៀង និងតៃនីញ ប្រទេសវៀតណាម ទើបត្រឡប់មកការពារព្រំដែនស្វាយរៀងវិញ។ ឈៀង រស់នៅស្វាយរៀងរហូតដល់ឆ្នាំ១៩៧៩។

នៅថ្ងៃទី៤ ខែមករា ឆ្នាំ១៩៧៩ កងទ័ពវៀតណាមបានប្រមូលកម្លាំងវាយចូលមកស្វាយរៀងម្តងទៀត ដោយកងទ័ពវៀតណាមមានកម្លាំងច្រើនទប់ទល់លែងឈ្នះ កងពលតូចដែលដឹកនាំដោយ អៀង ផាន បានដកថយមកតាមរមាសហែក សំរោងតាមត្រឡោកបែក ថយរហូតមកដល់ផ្លូវជាតិលេខ៥ ហើយបានបន្តដំណើរមកដល់ខដុង្គ ខេត្តកំពង់ស្ពឺ។

ចុងឆ្នាំ១៩៧៩ កងទ័ពវៀតណាមបានវាយចូលជាបន្តបន្ទាប់ ដោយទប់ទល់មិនជាប់ កងពលតូចបានរត់មកតាមភ្នំខ្មោចរហូតមកដល់ព្រំដែនថ្មដា ខេត្តពោធិ៍សាត់។ នៅពេលមកដល់ព្រំដែនថ្មដា កងទ័ពខ្មែរក្រហមទាំងអស់ ចាប់ផ្តើមប្រមូលកម្លាំងសារឡើងវិញ ដោយបូកបញ្ចូលជាមួយកងពល ស៊ូម៉ែត មកពីសំឡូត កងពលតា សេង មកពីកោះកុង និងកងពលតា វ៉ែន សរុបបានប្រហែល៧០០នាក់ បានបំបែកជាអង្គភាពតូចៗ ក្នុងមួយអង្គភាពមានគ្នា១២នាក់ សម្រាប់ការពារនៅតាមព្រំដែនៗ ចំណែកអង្គភាព ឈៀង មានតួនាទីការពារព្រំដែនថ្មដា។

មិនយូរប៉ុន្មាន កងទ័ពវៀតណាមបានធ្វើដំណើរតាមផ្លូវលេខ៥៦ រហូតមកដល់ស្ពានមេទឹក និងបានបោះទីតាំងនៅទីនោះ។ នៅពេលបានទទួលដំណឹងអង្គភាពតូចៗដែលបានបំបែកបានរៀបចំកម្លាំងសារឡើងវិញ ដើម្បីចុះមកវាយជាមួយកងទ័ពវៀតណាមដែលបោះទីតាំងនៅស្ពានមេទឹក ហើយបានវាយបណ្តេញកងទ័ពវៀតណាមថយរហូតដល់ទីរួមខេត្តពោធិ៍សាត់ រួចបានត្រឡប់មកព្រំដែនថ្មដាវិញ។

ក្នុងឆ្នាំ១៩៨២ កងទ័ពវៀតណាមបានវាយចូលមកដល់ស្រុកសំឡូត ខេត្តបាត់ដំបង ដោយខ្វះកម្លាំងទប់ទល់ជាមួយកងទ័ពវៀតណាម ស៊ូ ម៉េត បានស្នើសុំឱ្យអង្គភាពតូចៗដែលការពារនៅតាមព្រំដែនថ្មដាទៅជួយ។ អង្គភាព ឈៀង បានទៅជួយវាយជាមួយកងទ័ពវៀតណាមនៅសំឡូតបានប្រហែលកន្លះខែ។ ក្រោយមក កងទ័ពវៀតណាមបានដកចេញពីសំឡូតត្រឡប់មកព្រំដែនថ្មដាវិញ។ នៅពាក់កណ្តាលឆ្នាំ១៩៨២ កងទ័ពវៀតណាមបានធ្វើដំណើរមកស្ពានមេទឹកម្តងទៀត ពេលនោះអង្គភាពតូចៗបានរៀបចំកម្លាំងដើម្បីចុះមកទប់ទល់ជាមួយកងទ័ពវៀតណាមម្តងទៀត។ ពេលដែលកំពុងធ្វើដំណើរចុះបានពាក់កណ្តាល ឈៀង បានដើរជាន់មីនដែលកងទ័ពវៀតណាមបានបង្កប់ពីមុន។ បន្ទាប់ពីរងរបួស ឈៀង មានការឈឺចាប់និងតក់ស្លុតជាខ្លាំង។ ឈៀង ត្រូវបានអ្នកដែលនៅក្នុងអង្គភាពជាមួយបានបញ្ជូនមកព្យាបាលនៅអង្គភាពពេទ្យដែលឈរជើងនៅព្រំដែនថ្មដា ដោយមើលទៅជើងមានសភាពធ្ងន់ធ្ងរពេក ពេទ្យបានសម្រេចចិត្តកាត់ជើងម្ខាង។ ឈៀង សម្រាកព្យាបាលបានរយៈពេល៣ខែ ទើបជាសះស្បើយ។ បន្ទាប់មកពីជាសះស្បើយ កងទ័ពវៀតណាមបានវាយចូលដល់ព្រំដែនថ្មដា អង្គភាពតូចៗ បាននាំគ្នារត់ទៅរស់នៅជំរំសាយខេ ក្នុងទឹកដីថៃ។ ឈៀង រស់នៅជំរំសាយខេបានរយៈពេល៤ឆ្នាំ ទើបរៀបចំមានគ្រួសារនៅទីនោះ។

ក្នុងឆ្នាំ១៩៨៦ ឈៀង និងគ្រួសារបានធ្វើដំណើរចេញពីជំរំសាយខេមករស់នៅក្នុងដីខ្មែរវិញ ដោយធ្វើដំណើរចុះមកតាមផ្លូវអូរននោង រហូតមកដល់សំឡូត ហើយបាននាំប្រពន្ធកាប់ឆ្ការព្រៃយកដីដាំបន្លែនិងធ្វើចម្ការដើម្បីចិញ្ចឹមជីវិត។ ឈៀង រស់នៅសំឡូតបានរយៈពេល៧ឆ្នាំ ដោយសារតែជីវភាពខ្វះខាត ឈៀងនិងប្រពន្ធបានសម្រេចចិត្តផ្លាស់ទីលំនៅពីសំឡូតមករស់នៅភូមិដីក្រហម ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់ ហើយបានរានដីបន្តិចបន្តួចដើម្បីធ្វើចម្ការរហូតមកដល់សព្វថ្ងៃ។ ជាចុងក្រោយរឿងរ៉ាវដែល ឡេង ឈៀង ចង់ចាំមិនអាចបំភ្លេចបានគឺនៅពេលដែលចុះមកទប់ទល់ជាមួយកងទ័ពវៀតណាម ហើយបានដើរជាន់មីនបណ្តាលឱ្យដាច់ជើងម្ខាង។



ទេសភាពស្រុកវាលវែង ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# គ្រូបង្រៀន និងសិស្សានុសិស្សចំនួន៧៥នាក់ មកពីសាលាពន្លឺវិជ្ជាអន្តរជាតិ

## ធ្វើទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលឯកសារកោះថ្ម និងតំបន់ប្រវត្តិសាស្ត្រយោធាតេជោ កោះថ្ម-អ៊ិច-១៦

ឈុំ រ៉ា








គ្រូបង្រៀន និងសិស្សមកពីសាលាពន្លឺវិជ្ជាអន្តរជាតិ ទស្សនកិច្ចសិក្សា មជ្ឈមណ្ឌលឯកសារកោះថ្ម, ផ្ទះសហគមន៍ជនជាតិភាគតិចស្ទៀង និងតំបន់ប្រវត្តិសាស្ត្រយោធាតេជោ កោះថ្ម អ៊ិច-១៦។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅព្រឹកថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៥ លោកគ្រូ អ្នកគ្រូ និង សិស្សានុសិស្សចំនួន៧៥នាក់ មកពីសាលាពន្លឺវិជ្ជាអន្តរជាតិ សាខាក្រុងកំពង់ចាម ធ្វើទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលឯកសារកោះថ្ម ក្នុងគោលបំណងឈ្វេងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម និងប្រវត្តិតស៊ូរបស់សម្តេចតេជោ ហ៊ុន សែន ដែលជាចំណុចចាប់ផ្តើមនៃការរំដោះជាតិ និងប្រជាជនកម្ពុជាចេញពីរបបប្រល័យពូជសាសន៍ កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧។

ជាកិច្ចចាប់ផ្តើមលោក ឡុង ដានី នាយកមជ្ឈ-មណ្ឌលឯកសារកោះថ្ម បានណែនាំខ្លួន និងបង្ហាញអំពីគោលបំណងនៃការបង្កើតមជ្ឈមណ្ឌលឯកសារកោះថ្មនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០ ត្រូវនឹងពិធីរំឭកខួបលើកទី៤៣ នៃដំណើរឆ្ពោះទៅរកការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត (២០/០៦/១៩៧៧ - ២០/០៦/២០២០)។ ការបង្កើតមជ្ឈមណ្ឌលឯកសារកោះថ្ម ស្ថិតក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធរវាងក្រសួងអប់រំយុវជន និង

កីឡា, ក្រសួងការពារជាតិ និងមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយមានគោលបំណងដូចខាងក្រោម ៖

១) បង្ហាញព្រឹត្តិការណ៍ប្រវត្តិសាស្ត្រប្រទេសកម្ពុជាដែលបានចាប់ផ្តើមនៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ដល់ឆ្នាំ១៩៩០។

២) ពង្រឹងការកសាងសន្តិភាព និងការការពារជម្លោះ តាមរយៈកម្មវិធីអប់រំ ដែលជាឱកាសមួយសម្រាប់យុវជននៅតាមតំបន់ជនបទ និងតំបន់ដាច់ស្រយាលក្នុងការចូលរួមរៀនសូត្រ។

៣) លើកទឹកចិត្តអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមឱ្យចែករំលែក និងបង្រៀនក្មេងៗជំនាន់ក្រោយពីបទពិសោធន៍របស់ខ្លួនក្នុងរបបខ្មែរក្រហម។

៤) ប្រមែប្រមូលរឿងរ៉ាវបទពិសោធន៍ពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងទីតាំងឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងរបបនោះ។

បន្ទាប់មកលោក ឡុង ដានី បានដឹកនាំសិស្សានុសិស្សដើរទស្សនាពិព័រណ៍នៃបណ្តុំរូបថតចំនួន ១៣៣រូប និងផែនទីនៅក្នុងមជ្ឈមណ្ឌលឯកសារកោះថ្ម ដោយចាប់ផ្តើមពីបណ្តុំរូបថតនៃសង្គ្រាមនៅទសវត្សរ៍ឆ្នាំ១៩៦០នៅតំបន់កោះថ្ម, បណ្តុំរូបថតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩), បណ្តុំរូបថតនៃជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាបន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩, បណ្តុំរូបថតភស្តុតាងអំពីឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយរបបខ្មែរក្រហម (១៩៧៥-១៩៧៩), បណ្តុំរូបគំនូរដែលសមមិត្ត ហ៊ុន សែន (បច្ចុប្បន្នសម្តេចតេជោ ហ៊ុន សែន) និងយុទ្ធមិត្ត៤រូបចាកចេញទៅប្រទេសវៀតណាមដើម្បីរៀបចំកម្លាំងវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ប៉ុល ពត នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ និងផែនទីបង្ហាញផ្លូវដែលសមមិត្ត ហ៊ុន សែន និងយុទ្ធមិត្ត៤រូប បានចាកចេញពីបន្ទាយយោធានៅភូមិកោះថ្ម ទៅកាន់តំបន់ព្រំដែនអាងដាច់ដើមត្រយឹង (X-16) និងទីតាំងមួយចំនួននៅក្នុងស្រុកឡុកនិញ ខេត្តសុងប៊ែ ប្រទេសវៀតណាម និងការបង្កើតអង្គភាព១២៥ ដែលជាកងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជាដំបូងបង្អស់ដើម្បីវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៨។ បន្ទាប់ពីសិស្សានុសិស្សទស្សនាពិព័រណ៍រូបភាព គំនូរ ផែនទី បណ្តុំរូបថតភស្តុតាងអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយរបបខ្មែរក្រហម (១៩៧៥-១៩៧៩) និងស្តាប់លោក ឡុង ដានី ធ្វើបទបង្ហាញរួច ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម ដឹកនាំលោកគ្រូអ្នកគ្រូនិងសិស្សានុសិស្សបន្តដំណើរទៅទស្សនានៅផ្ទះសហគមន៍ភូមិគ្គុលលើ ឬមជ្ឈមណ្ឌលឯកសារកោះថ្ម-សាលាគរុកណ្ឌស្ទៀង។

លោក ឈុំ រ៉ា គឺជាបុគ្គលិកផ្ទះសហគមន៍ជនជាតិស្ទៀងភូមិគ្គុលលើបានរៀបរាប់ថា ផ្ទះសហគមន៍ជនជាតិស្ទៀងនៅភូមិគ្គុលលើនេះ ចាប់ផ្តើមជួសជុលនៅខែមីនា ឆ្នាំ២០២៤ និងបានបញ្ចប់ទាំងស្រុងនៅដើមខែកញ្ញា ឆ្នាំ២០២៤។ ទីតាំងនេះ គឺជាអំណោយរបស់យាយ ម៉ែន ប្រាញ់ ដល់មជ្ឈមណ្ឌលឯកសារកោះថ្មធ្វើការជួលជុល និងរៀបចំដើម្បីបម្រើដល់ផលប្រយោជន៍រួមរបស់ប្រជាជននៅក្នុងសហគមន៍ទាំងមូល។ ផ្ទះសហគមន៍ជនជាតិស្ទៀងភូមិគ្គុលលើនៃមជ្ឈមណ្ឌលឯកសារកោះថ្មត្រូវបានរចនាឡើងដោយនិស្សិតស្ថាបត្យកម្មឆ្នាំទី៥ នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈចំនួន២រូប គឺលោក វនវ័ត្នវិសាល និង កញ្ញា លីម វណ្ណសូលីហ្សា ដោយយកតាមលំនាំផ្ទះរបស់ជនជាតិដើមភាគតិចស្ទៀងសម័យបុរាណ។

ចុងក្រោយក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម បានដឹកនាំលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សទៅទស្សនានៅតំបន់ប្រវត្តិយោធាតេជោកោះថ្ម អ៊ិច-១៦ ស្ថិតនៅឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ដែលជាទីតាំង សម្តេចតេជោ ហ៊ុន សែន និងយុទ្ធមិត្ត៤រូបចាកចេញទៅប្រទេសវៀតណាម ដើម្បីរៀបចំកម្លាំងវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ប៉ុល ពត នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ ដោយផ្ទាល់ ដើម្បីសិក្សាឈ្វេងយល់អំពីប្រវត្តិសាស្ត្រឱ្យកាន់តែច្បាស់លាស់បន្ថែមទៀត។

***ខាងក្រោមនេះគឺជាចំណាប់អារម្មណ៍របស់លោកគ្រូអ្នកគ្រូ និង សិស្សានុសិស្ស បន្ទាប់ពីបានចូលរួមដំណើរទស្សនកិច្ច៖***

ខ្ញុំឈ្មោះ **ខឹង ចាន់និត** ជាគ្រូបង្រៀនប្រវត្តិវិទ្យា និងភូមិវិទ្យា នៃសាលាពន្លឺវិជ្ជាអន្តរជាតិ (PIS) សាខាក្រុងកំពង់ចាម។ សម្រាប់ខ្ញុំនេះជាលើកទីមួយដែលបានមកទស្សនកិច្ចសិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហម នៅមជ្ឈមណ្ឌលឯកសារកោះថ្ម។ ពេលត្រឡប់ទៅវិញខ្ញុំនឹងបង្រៀនដល់សិស្សានុសិស្សនៅសាលារបស់ខ្ញុំបន្ថែមទៀត និងផ្សព្វផ្សាយដល់សិស្សឯទៀតឱ្យមកទស្សនកិច្ចសិក្សាកាន់តែច្រើនជាងនេះ ពីកន្លែងប្រវត្តិសាស្ត្រតស៊ូ សម្តេចតេជោ ហ៊ុន សែន ដឹកនាំកងកម្លាំងរំដោះប្រទេសចេញពីរបបខ្មែរក្រហម (១៩៧៥-១៩៧៩)។ ខ្ញុំអរគុណដល់ក្រុមការងារនៃមជ្ឈមណ្ឌលឯកសារកោះថ្ម និង បុគ្គលិកផ្ទះសហគមន៍ជនជាតិស្មៀងភូមិក្តុលលើ ដែលបានផ្តល់ព័ត៌មានជាច្រើនមកកាន់លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្ស។ ខ្ញុំសង្ឃឹមថាលើកក្រោយខ្ញុំនឹងមកទស្សនកិច្ចសិក្សានៅទីនេះម្តងទៀត ជាមួយសិស្សានុសិស្ស និង ក្រុមគ្រួសារខ្ញុំ។ ជាចុងក្រោយសូមសំណូមពរដល់មជ្ឈមណ្ឌលឯកសារកោះថ្មជួយផ្សព្វផ្សាយទីតាំងខាងលើឱ្យបានកាន់តែល្អប្រសើរ ពេលសិស្សានុសិស្សចង់ទៅកន្លែងជាក់ស្តែង រកឯកសារដែលកូនសិស្សត្រូវការ សូមឱ្យក្រុមការងារជួយទៅតាមលទ្ធភាពដែលអាចធ្វើបាន។

ខ្ញុំឈ្មោះ **រហឿន ម៉ានី** ជាសិស្សថ្នាក់ទី៨ នៃសាលាពន្លឺវិជ្ជាអន្តរជាតិ សាខាខេត្តកំពង់ចាម។ សម្រាប់ខ្ញុំនេះជាលើកទីមួយ ដែលចុះធ្វើដំណើរទស្សនកិច្ចសិក្សាផ្លូវឆ្ងាយ ដល់ទីតាំងមជ្ឈមណ្ឌលឯកសារកោះថ្ម ។ ទោះបីឆ្ងាយ តែមិនបានបង្កភាពពិបាកសម្រាប់ខ្ញុំទេ ប៉ុន្តែមានភាពសប្បាយដែលបានទទួលចំណេះដឹងថ្មីៗ តាមគ្រូខ្ទេសបង្ហាញណែនាំពីប្រវត្តិសាស្ត្រខ្មែរក្រហម។ ចំណេះដឹងពីរបបខ្មែរក្រហម វាពិតជាធំធេងណាស់ ព្រោះខ្ញុំមិនដឹងថាប្រទេសកម្ពុជាអាចរំដោះខ្លួនចេញពីរបប ប៉ុល ពត បានតាមរបៀបណា? ដល់ថ្ងៃនេះ បានខ្ញុំយល់ដឹងកាន់តែច្បាស់។ ចំណេះដឹងដែលខ្ញុំទទួលបានថ្ងៃនេះ ខ្ញុំយកទៅសិក្សា និងស្រាវជ្រាវបន្ថែម និង ប្រាប់ទៅមិត្តភក្តិដែលមិនបានមកទស្សនកិច្ចសិក្សាដូចខ្ញុំ។

ខ្ញុំឈ្មោះ **គង់ សុបញ្ញាវត្តី** ជាសិស្សថ្នាក់ទី៩ក នៃសាលាពន្លឺវិជ្ជាអន្តរជាតិ។ ខ្ញុំពិតជាសប្បាយចិត្តដែលបានមកទស្សនកិច្ចសិក្សានៅមជ្ឈមណ្ឌលឯកសារកោះថ្ម ពីប្រវត្តិសាស្ត្រខ្មែរក្រហម ព្រមទាំងទទួលបានចំណេះដឹងជាច្រើន។ កន្លងមកខ្ញុំធ្លាប់បានសិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហមតាមសៀវភៅបានបន្តិចបន្តួច។ ជាចុងក្រោយ សូមអរគុណដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម ដែលបានយកចិត្តទុកដាក់លើក្រុមខ្ញុំ និងប្រាប់ពីព័ត៌មាន ទាក់ទងជាមួយប្រវត្តិសាស្ត្រខ្មែរក្នុងរបបប្រល័យពូជសាសន៍ខ្មែរក្រហម (១៩៧៥-១៩៧៩) ដើម្បីជាមូលដ្ឋានដល់រូបខ្ញុំសិក្សាបន្ថែមទៀត។





គ្រូបង្រៀន និងសិស្សមកពីសាលាពន្លឺវិជ្ជាអន្តរជាតិ ទស្សនកិច្ចសិក្សាមជ្ឈមណ្ឌលឯកសារកោះថ្ម ផ្ទះសហគមន៍ជនជាតិភាគតិចស្មៀង និងតំបន់ប្រវត្តិសាស្ត្រយោធាតេជោ កោះថ្ម អ៊ិច-១៦។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលផ្សះផ្សាវាលវែងរៀបចំវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដល់សិស្សមកពីវិទ្យាល័យប្រម៉ោយ

**ឡុង ដានី**



សិស្សមកពីវិទ្យាល័យប្រម៉ោយ ចូលរួមវេទិកាថ្នាក់រៀនស្តីពី «សារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» នៅការិយាល័យមជ្ឈមណ្ឌលផ្សះផ្សាវាលវែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៥ មជ្ឈមណ្ឌលផ្សះផ្សាវាលវែងរៀបចំវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដល់សិស្សានុសិស្សចំនួន១៥នាក់ ក្នុងនោះមានស្រី១២នាក់ មកពីវិទ្យាល័យ ហ៊ុន សែន ប្រម៉ោយ ស្ថិតនៅការិយាល័យរបស់ខ្លួនក្នុងស្រុកវាលវែង ខេត្តពោធិ៍សាត់។ វេទិកាថ្នាក់រៀនក្នុងថ្ងៃនេះគឺផ្តោតលើប្រធានបទ៖ ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងការជម្លៀសដោយបង្ខំដំណាក់កាលទី២ និងទី៣, និយមន័យអំពីអំពើប្រល័យពូជសាសន៍ និងវិធីសាស្ត្រក្នុងការទប់ស្កាត់អំពើប្រល័យពូជសាសន៍កុំឱ្យកើតមានឡើងសារជាថ្មី។ គោលបំណងដែលមជ្ឈមណ្ឌលផ្សះផ្សាវាលវែង រៀបចំវេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) គឺចង់ឱ្យសិស្សានុសិស្សឈ្វេងយល់ពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាក្នុងរបបខ្មែរក្រហម និងកត្តាអ្វីខ្លះដែលនាំឱ្យកើតមានផលប៉ះពាល់នាពេលអនាគត ប្រសិនបើយើងមិនបានរៀនសូត្រពីរបបខ្មែរក្រហម។ សិស្សានុសិស្សត្រូវមានគំនិតផ្លាស់ប្តូរ

ការគិតពីការប្រព្រឹត្តអំពើហិង្សា មកជាការជំរុញឱ្យមានការពិភាក្សាអំពីកេរដំណែលប្រវត្តិសាស្ត្រ នៅក្នុងសង្គម គ្រួសារ សហគមន៍ និងប្រទេសជាតិ។

មុនវេទិកាថ្នាក់រៀនចាប់ផ្តើមលោក ឡុង ដានី នាយកមជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានណែនាំខ្លួនទៅកាន់សិស្សានុសិស្ស និងរៀបរាប់ពីវត្ថុបំណងចំនួន៤ នៃការបើកដំណើរការរបស់មជ្ឈមណ្ឌលផ្សះផ្សាវាលវែង តាំងពីថ្ងៃទី ០១ ខែឧសភា ឆ្នាំ ២០២៣ ដូចខាងក្រោម៖

១) ដើម្បីបង្ហាញពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រប្រទេសកម្ពុជាចាប់ពីទសវត្សរ៍ឆ្នាំ១៩៧០ រហូតដល់ទសវត្សរ៍ឆ្នាំ១៩៩០។

២) ដើម្បីពង្រឹងដល់ដំណើរការសន្តិភាព និងការទប់ស្កាត់ជម្លោះនានាតាមរយៈកម្មវិធីអប់រំ។ កម្មវិធីអប់រំនេះ និងផ្តល់ឱកាសឱ្យសិស្សានុសិស្សជំនាន់ក្រោយដែលភាគច្រើនរស់នៅតាមទីជនបទបានមកចូលរួមរៀនសូត្រ។

៣) លើកទឹកចិត្តដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ក្នុងការចែករំលែកអំពីរឿងរ៉ាវ និងបទពិសោធន៍ផ្ទាល់ខ្លួនដល់សិស្សានុ-សិស្សជំនាន់ក្រោយ។

៤) ប្រមែប្រមូលរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងទីតាំងបទឧក្រិដ្ឋដែលបានបន្សល់ពីរបបខ្មែរក្រហម។

ជាកិច្ចបន្ទាប់មកលោក ឡុង ដានី បានឱ្យសិស្សានុសិស្សបំពេញតារាងស្ទាបស្ទង់មតិអំពីចំណេះដឹងរបស់ខ្លួនទាក់ទងនឹងប្រវត្តិសាស្ត្រខ្មែរក្រហម និយមន័យអំពើប្រល័យពូជសាសន៍ និងការទប់ស្កាត់អំពើឃោរឃៅធ្ងន់ធ្ងរនៅមុនបទបង្ហាញអំពីប្រវត្តិសាស្ត្រខ្មែរក្រហម (១៩៧៥-១៩៧៩)។

ក្រោយពីប្រមូលតារាងស្ទាបស្ទង់មតិរួច លោក ឡុង ដានី បានលើកយកវិធីសាស្ត្រ K-W-L និង អំណានដំពូកមកបង្រៀនសិស្ស ដោយចាប់ផ្តើមសួរសំណួរទៅសិស្សានុសិស្សទាំងអស់ថា តើប្អូនៗបានដឹងអ្វីខ្លះអំពីរបបខ្មែរក្រហម? សំណួរបន្ទាប់មកទៀត តើប្អូនៗចង់ដឹងអ្វីខ្លះអំពីរបបខ្មែរក្រហម? តមកទៀត យុវជនស៊ឺ គ្រូចិត្ត ឡើងអានអត្ថបទការជម្លៀសដោយបង្ខំក្នុងដំណាក់កាលទី២ និងទី៣ ក្នុងរបបខ្មែរក្រហម។ នៅក្នុងឱកាសនោះ លោក ឡុង ដានី បានធ្វើបទបង្ហាញអំពីការឡើងកាន់អំណាចរបស់ខ្មែរក្រហម គឺ៖ ការជម្លៀសប្រជាជនចេញពីទីក្រុង ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដែលខ្មែរក្រហមបានជម្លៀសប្រជាជនដោយបង្ខំជាបីដំណាក់កាលដូចខាងក្រោម៖

១) នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បន្ទាប់ពីកងទ័ពខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ បានរយៈពេល២ទៅ៣ម៉ោង មេដឹកនាំខ្មែរក្រហមបានបញ្ជាឱ្យកងទ័ពខ្មែរក្រហមចាប់ផ្តើមជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ និងទីប្រជុំជននានា ទៅធ្វើការងារពលកម្មដ៏លំបាកវេទនា នៅតាមវាលស្រែនៃតំបន់ដាច់ស្រយាលនៃប្រទេសកម្ពុជា។ កងទ័ពខ្មែរក្រហមបានយកលេសក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញថា សហរដ្ឋអាមេរិកនឹងមកទម្លាក់គ្រាប់នៅទីក្រុងភ្នំពេញ ប្រជាជនត្រូវជម្លៀសចេញពីទីក្រុងភ្នំពេញតែរយៈពេល៣ថ្ងៃនឹងបានវិលត្រឡប់មកផ្ទះវិញហើយ ដូច្នេះប្រជាជនទាំងអស់មិនចាំបាច់យកទ្រព្យសម្បត្តិច្រើនទៅតាមខ្លួន និងចាក់សោផ្ទះឡើយ។ ប៉ុន្តែការពិតខ្មែរក្រហមមិនបានអនុញ្ញាតឱ្យប្រជាជនត្រឡប់មកផ្ទះវិញពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ប្រជាជនជម្លៀសច្រើនលើសលប់បានស្លាប់ដោយសារការសម្លាប់ ធ្វើការងារហួសកម្លាំង និងអត់អាហារ។

២) ចាប់តាំងពីចុងឆ្នាំ១៩៧៥ ខ្មែរក្រហមបានការផ្លាស់ទីប្រជាជន ជាពិសេសប្រជាជនថ្មី



សិស្សមកពីវិទ្យាល័យប្រម៉ោយ ចូលរួមវេទិកាថ្នាក់រៀន ស្តីពី «សារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» នៅការិយាល័យមជ្ឈមណ្ឌលផ្សះផ្សាវាលវែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ដោយបង្ខំនៅតាមទីជនបទមួយទៅតាមទីជនបទមួយទៀតម្តងហើយម្តងទៀតនៅក្នុងភូមិភាគកណ្តាល ភូមិភាគនិរតី ភូមិភាគបស្ចិម ភូមិភាគបូព៌ា (រួមបញ្ចូលទាំងការផ្លាស់ទីតាមរយៈរថភ្លើងពីភូមិភាគនិរតី និងភូមិភាគបស្ចិម ទៅកាន់ភូមិភាគពាយ័ព្យ)។ ការផ្លាស់ទីប្រជាជននេះពុំមានជូនដំណឹងជាមុនបានបង្កជាទុក្ខវេទនា និងភាពលំបាកលំបិនដល់ប្រជាជន និងសហគមន៍យ៉ាងខ្លាំង។

៣) ចាប់តាំងពីរបបខ្មែរក្រហមធ្វើសង្គ្រាមតាមព្រំដែនជាមួយប្រទេសវៀតណាម នៅចុងឆ្នាំ១៩៧៧ ខ្មែរក្រហមចាប់ផ្តើមលែងទុកចិត្តលើកម្មាភិបាល យុទ្ធជន និងប្រជាជននៅភូមិភាគបូព៌ា។ ប្រជាជនភូមិភាគបូព៌ាត្រូវបានខ្មែរក្រហមចោទប្រកាន់ថា ជាមនុស្សដែលមានក្បាលយួនខ្លួនខ្មែរ។ ប្រជាជនភូមិភាគបូព៌ាទាំងអស់ជាគោលដៅនៃការជម្លៀសដោយបង្ខំចេញពីភូមិភាគបូព៌ាទៅភូមិភាគពាយ័ព្យ ភូមិភាគកណ្តាល និងភូមិភាគឧត្តរ។ ការជម្លៀសដោយបង្ខំនេះ បានបណ្តាលឱ្យប្រជាជនភូមិភាគបូព៌ាជាច្រើនបានស្លាប់ដោយសារខ្មែរក្រហមសម្លាប់ អត់អាហារ និងមានជំងឺគ្មានថ្នាំព្យាបាល។

បន្ទាប់ពីការធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រខ្មែរក្រហមចប់ លោក ឡុង ដានី ក៏បានធ្វើបទបង្ហាញជាសង្ខេបអំពីដំណើរការអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សំណុំរឿង ០០១ និងសំណុំរឿង ០០២ (សំណុំរឿង០០២ វគ្គទី១ និងសំណុំ០០២ វគ្គទី២)។ និយមន័យអំពើប្រល័យពូជសាសន៍ ធាតុផ្សំនៃអំពើប្រល័យពូជសាសន៍ និងការទប់ស្កាត់។

នៅចុងបញ្ចប់នៃវេទិកាថ្នាក់រៀនលោក ឡុង ដានី បានស្នើសុំឱ្យសិស្សានុសិស្សបំពេញតារាងស្ទាបស្ទង់មតិ ម្តងទៀតដើម្បីចង់ដឹងអំពីចំណេះដឹង ទាក់ទងនឹងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និយមន័យអំពើប្រល័យពូជសាសន៍ និងការទប់ស្កាត់អំពើឃោរឃៅធ្ងន់ធ្ងរ បន្ទាប់ពីការសិក្សារៀនសូត្រ។

ខាងក្រោមនេះគឺជាចំណាប់អារម្មណ៍របស់សិស្សានុសិស្សដែលបានចូលរួមក្នុងវេទិកាថ្នាក់រៀន

ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)៖

ខ្ញុំឈ្មោះ **ភ័ណ ផល** ភេទប្រុស អាយុ១៩ឆ្នាំ គឺជាសិស្សថ្នាក់ទី១២ មកពីវិទ្យាល័យ ហ៊ុន សែន ប្រម៉ោយ។ ខ្ញុំសប្បាយចិត្ត និងរំភើបជាខ្លាំងនៅពេលដែលបានចូលរួមក្នុងវេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ វេទិកាថ្នាក់រៀនធ្វើឱ្យខ្ញុំយល់ដឹងអំពីប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជាកាន់តែច្រើនបន្ថែមទៀត ដូចជា ការសម្លាប់សត្រូវខាងក្នុង និងសត្រូវខាងក្រៅ ការអនុវត្តច្បាប់តាមគោលការណ៍ដឹកនាំរបស់លោក នួន ជា និង លោក ខៀវ សំផន ការកាត់ទោសលើមេដឹកនាំធំៗក្នុងរបបខ្មែរក្រហម និងការទប់ស្កាត់អំពើហិង្សានានា ដើម្បីកុំឱ្យរបបខ្មែរក្រហមវិលត្រឡប់មកវិញ។

ខ្ញុំឈ្មោះ **ប៉ែត ស្រីឡៀ** ភេទស្រី អាយុ១៧ឆ្នាំ គឺជាសិស្សថ្នាក់ទី១១ មកពីវិទ្យាល័យ ហ៊ុន សែន ប្រម៉ោយ។ នាងខ្ញុំសោមនស្សរីករាយយ៉ាងខ្លាំងដែលបានសិក្សាពីប្រវត្តិសាស្ត្រក្នុងរបបខ្មែរក្រហម និងទទួលបានចំណេះដឹងបន្ថែមពីការចូលរួមវេទិកាថ្នាក់រៀននេះ។ ខ្ញុំយល់ដឹងកាន់តែច្បាស់ជាងមុនទាក់ទងទៅនឹងការជម្លៀសប្រជាជនទាំងបីដំណាក់កាល ស្ថានភាពរស់នៅ ការហូបចុក ការធ្វើការងារដោយប្រើកម្លាំងរបស់ប្រជាជនក្នុងរបបខ្មែរក្រហម។

ខ្ញុំឈ្មោះ **ពឿន យុនន្ទ** ភេទស្រី អាយុ១៧ឆ្នាំ គឺជាសិស្សថ្នាក់ទី១១ មកពីវិទ្យាល័យ ហ៊ុន សែន ប្រម៉ោយ។ ខ្ញុំសប្បាយរីករាយដែលបានចូលរួមវេទិកាថ្នាក់រៀនដែលរៀបចំដោយមជ្ឈមណ្ឌលផ្សះផ្សាវាលវែង។ បន្ទាប់ពីបានស្តាប់បទបង្ហាញរបស់លោកគ្រូ ឡុង ដានី រួចមក ខ្ញុំទទួលបានចំណេះដឹងទាក់ទងនឹងការជម្លៀសប្រជាជនដោយបង្ខំពីកន្លែងមួយទៅកន្លែងមួយទៀត ដោយធ្វើដំណើរតាមរយៈរថភ្លើងតាមរថយន្តនិងតាមទូកក្នុងរបបខ្មែរក្រហម។ ពិសេស ខ្ញុំទទួលបានចំណេះដឹងអំពីការទប់ស្កាត់មិនឱ្យរបបប្រល័យពូជសាសន៍វិលត្រឡប់មកវិញ។



សិស្សមកពីវិទ្យាល័យប្រម៉ោយ ចូលរួមវេទិកាថ្នាក់រៀន ស្តីពី «សារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» នៅការិយាល័យមជ្ឈមណ្ឌលផ្សះផ្សាវាលវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងរៀបចំវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដល់សិស្សមកពីអនុវិទ្យាល័យថ្លាត

**លី សុខឃាង**







សិស្សមកពីអនុវិទ្យាល័យថ្លាត ចូលរួមវេទិកាថ្នាក់រៀនស្តីពី «សារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» នៅការិយាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២៥ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានរៀបចំវេទិកាថ្នាក់រៀនស្តីពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ដល់សិស្សានុសិស្សចំនួន៧ នាក់ មកពីអនុវិទ្យាល័យថ្លាត ស្រុកអន្លង់វែង។ គោលបំណងនៃការរៀបចំវេទិកាថ្នាក់រៀននេះ គឺដើម្បីចូលរួមលើកកម្ពស់ការអប់រំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិប-តេយ្យ និងទប់ស្កាត់កុំឱ្យមានអំពើប្រល័យពូជសាសន៍កើតឡើងសារជាថ្មីនាពេលអនាគត។ ដើម្បីឆ្លើយតបទៅនឹងគោលបំណងនៃវេទិកាថ្នាក់រៀន ដំបូងគ្រូខ្ទេសបានលើកពាក្យគន្លឹះចំនួនពីរមកធ្វើជាប្រធានបទពិភាក្សាគឺ៖ អំពើហិង្សា និងការអត់ឱនអធ្យាស្រ័យឱ្យគ្នា។

ក្រោមបទពិភាក្សាក្នុងវេទិកាថ្នាក់រៀនសិស្សា-នុសិស្សបានឱ្យនិយមន័យ «អំពើហិង្សា» ថា ជាការវាយដំ ការប្រតាយប្រតប់ ការឈ្លោះប្រកែកគ្នា និងរូបភាពនៃការគំរាមកំហែងទាំងផ្លូវចិត្ត និងរូបរាងកាយ។ ចំណែកឯពាក្យ «ការអត់ឱន» គឺជាការអត់ទោសឱ្យគ្នាទៅវិញទៅមក និងការផ្សះផ្សាជម្លោះដោយសន្តិវិធី។ អំពើប្រល័យពូជសាសន៍ក្នុងប្រទេសកម្ពុជាបានបញ្ចប់ទៅ ការអប់រំ និងការផ្សះផ្សាសង្គមចាប់ផ្តើមកើតមានឡើង រហូតដល់

មានការបង្កើតតុលាការស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ។ យុវជនជំនាន់ក្រោយមិនអាចដឹងបានទេថា អនាគតនឹងមានរឿងអ្វីកើតឡើង ប្រសិនបើមិនមានការអប់រំ និងមិនមានការសិក្សាឈ្វេងយល់។

វេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ បានច្រៀចយកចំណុចសំខាន់ៗពីរឿងហេតុ ដើមទងនៃអំពើហិង្សារហូតឈានដល់មានអំពើប្រល័យពូជសាសន៍ ជាចំណុចយល់ដឹង ដើម្បីជំរុញឱ្យមានការឆ្លុះបញ្ចាំងឱ្យមានការអត់ឱនឱ្យគ្នា។ ទាក់ទងនឹងអំពើប្រល័យពូជសាសន៍ ដោយសារតែមិនមានការអត់ឱន និងការសណ្តោសប្រណីដល់គ្នាទៅវិញទៅមក ទើបអំពើប្រល័យពូជសាសន៍កើតឡើងជាបន្តបន្ទាប់ក្រោយអនុសញ្ញាស្តីពី «ការបង្ការ និងផ្តន្ទាទោសលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍» ដែលបានចូលជាធរមានចាប់តាំងពីថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៤៨ មករួមមាន៖ ប្រទេសអាមេនី, ប្រទេសអាល្លឺម៉ង់, ប្រទេសកម្ពុជា, ប្រទេសបូស្នី-ហឺហ្សេហ្គោវីន និងប្រទេសរ៉្វាន់ដា។

បន្ទាប់មក លោកបណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានជ្រើសរើសបទបង្ហាញអំពី៖ «ជីវិតរស់នៅប្រចាំថ្ងៃក្នុងរបបកម្ពុជាប្រជាធិបតេយ្យ» ដែលបង្ហាញអំពីទិដ្ឋភាពការងារដោយបង្ខំក្នុងការដ្ឋាន, ការធ្វើទារុណកម្ម និងការធ្វើបន្សុទ្ធកម្ម ជាដើម ដើម្បីជាដើមចមនៃប្រវត្តិសាស្ត្រដ៏សោកសង្រេងរបស់កម្ពុជា។ របបខ្មែរក្រហមបានឡើងកាន់អំណាចចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ របបខ្មែរក្រហមបានឆក់យកជីវិតមនុស្សប្រមាណជិត ២លាននាក់ តាមរយៈអំពើឃោរឃៅ អំពើប្រល័យពូជសាសន៍ ការបង្អត់អាហារ និងជំងឺ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលហៅកាត់ថា អ.វ.ត.ក ឬសាលាក្តីខ្មែរក្រហមបានរកឃើញថា របបខ្មែរក្រហមបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ តាមរយៈបទឧក្រិដ្ឋដែលរកឃើញទៅលើមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតក្នុងរបបខ្មែរក្រហម។ នៅផ្នែកចុងបញ្ចប់សិស្សានុសិស្សបានបង្ហាញ ចំណាប់អារម្មណ៍ផ្ទាល់ខ្លួនដូចខាងក្រោម៖

**យុទ្ធ ភ័ក្រា** ភេទស្រី អាយុ១៥ឆ្នាំ យល់ឃើញថា ការសិក្សារៀនសូត្រពីជីវភាពរស់នៅប្រចាំថ្ងៃ




បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ធ្វើបទបង្ហាញអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ដល់សិស្សមកពីអនុវិទ្យាល័យថ្នាត។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅក្នុងរបបខ្មែរក្រហមបានឱ្យខ្ញុំដឹងពីស្ថានភាពលំបាកវេទនា ភាពអត់ឃ្លាន និងការធ្វើការហួសកម្លាំង។ នៅក្នុងវេទិកាថ្នាក់រៀន ខ្ញុំឃើញរូបថតអ្នកទោសឈ្មោះ ចាន់ គីមស្រ៊ុន បីកូនជាមួយទឹកមុខក្រៀមក្រំ និងអស់សង្ឃឹម។ ខ្ញុំគិតថា អំពើហិង្សានៅក្នុងសង្គមនាពេលបច្ចុប្បន្ននេះ មិនមែនបន្តកើតមានតាំងពីរបបខ្មែរក្រហមទេ គឺអំពើហិង្សាកើតចេញមកពីខ្លួនឯងផ្ទាល់និងការខ្វះការគិតពិចារណា។ អំពើហិង្សាមិនអាចកើតមានទេ ប្រសិនបើមានការអត់ឱនឱ្យគ្នា និងចេះដោះស្រាយបញ្ហាដោយសន្តិវិធី»។

**រឿន រចនា** ភេទស្រី អាយុ១៨ឆ្នាំ បានរៀបរាប់ថា ការសិក្សារៀនសូត្រពីជីវភាពរស់នៅប្រចាំថ្ងៃក្នុងរបបខ្មែរក្រហម បានបង្ហាញឱ្យឃើញពីភាពព្រៃផ្សៃ ភាពឃោរឃៅដែលខ្មែរក្រហមប្រព្រឹត្តលើប្រជាជនខ្មែរ ហើយសូម្បីតែពេលឈឺថ្កាត់ក៏គ្មានថ្នាំសម្រាប់ព្យាបាលដែរ ដែលផ្ទុយពីសម័យបច្ចុប្បន្ន។ ខ្ញុំយល់ថាអំពើហិង្សាមិនអាចកើតមានឡើងទេ ប្រសិនបើមានការអត់ឱនឱ្យគ្នា និងចេះអធ្យាស្រ័យគ្នា។ ជាក់ស្តែង ពេលខ្ញុំមានជម្លោះជាមួយមិត្តភក្តិ ខ្ញុំតែងតែមានការលើកលែង និងការដោះស្រាយគ្នាដោយសន្តិវិធីដើម្បីបញ្ចប់ជម្លោះ»។

**បៀក រតនា** ភេទប្រុស អាយុ១៦ឆ្នាំ លើកឡើងថា ការសិក្សារៀនសូត្រពីជីវភាពរស់នៅប្រចាំថ្ងៃគឺធ្វើឱ្យខ្ញុំបានយល់ដឹងអំពីភាពលំបាកវេទនា ការបែកបាក់គ្រួសារ ភាពខ្វះខាត និងការប្រើមនុស្សឱ្យធ្វើការហួសកម្លាំង។ ខ្ញុំបានដឹងពីការធ្វើទារុណកម្មដើម្បីសួរចម្លើយ និងការកាប់សម្លាប់ប្រជាជនខ្មែរដែរ។

**ស៊ីន ទ៉ាន់ដា** ភេទប្រុស អាយុ១៦ឆ្នាំ បានឱ្យដឹងថា ការសិក្សារៀនសូត្រពីជីវភាពរស់នៅប្រចាំថ្ងៃធ្វើឱ្យខ្ញុំដែលជាក្មេងជំនាន់ក្រោយបានយល់ដឹងពីការរស់នៅរបស់ប្រជាជនក្នុងរបបខ្មែរក្រហម ដូចជាភាពអត់ឃ្លាន និងលំបាកវេទនា។ បន្ទាប់ពីចូលរួមវេទិកាថ្នាក់រៀនរួច ខ្ញុំនៅតែចងចាំអំពីអ្នកទោសដែលជាប់ឃុំឃាំងនៅសន្តិសុខមន្ទីរស-២១។ ខ្ញុំយល់ថា មនុស្សខ្វះការសណ្តោសប្រណី និងខ្វះការគិតពិចារណាអាចនាំឱ្យកើតមានអំពើហិង្សា ពីព្រោះនៅពេលមនុស្សខ្វះការគិតពិចារណាធ្វើឱ្យរឿងតូចក្លាយទៅជារឿងធំ ហើយឈានទៅដល់ការកាប់សម្លាប់គ្នា។






សិស្សមកពីអនុវិទ្យាល័យថ្នាតៗ
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)













# ការិយាល័យព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន សិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍អំពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្សទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លងនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ ១១ ផ្លូវលេខ ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង រស់ សំពៅ អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៨៨២ ៥០៥ ឬ

អ៊ីម៉ែល ៖ truthsampeou.r@dccam.org

សូមអរគុណ!














# បងៗរបស់ខ្ញុំ៣នាក់ អង្គការស្នើយកទៅរៀនសូត្រ ចំនួន៣ថ្ងៃ តែបាត់ខ្លួនរហូតដល់បច្ចុប្បន្ន

សាំង ចាន់ធូ

ឡឿន សម្បត្តិ អាយុ៦១ឆ្នាំ កើតនៅភូមិដៀស ឃុំថ្មពេជ្រ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម។ សព្វថ្ងៃ សម្បត្តិផ្លាស់ទីលំនៅមកភូមិត្នោតលើ ឃុំបុស្សឫស្សីស្រុក ស្រុកស្រីសន្ធរ ខេត្តកំពង់-ចាម។ សម្បត្តិ គឺជាកូនស្រីពៅក្នុងចំណោមបងប្អូនប្រុសស្រីចំនួន៦នាក់។ រឿងរ៉ាវដែល សម្បត្តិមិនអាចបំភ្លេចបានក្នុងរបបខ្មែរក្រហម គឺបងៗចំនួន៣នាក់ បានបាត់ខ្លួនក្រោយពេលអង្គការស្នើសុំឱ្យទៅរៀនសូត្រចំនួន៣ថ្ងៃ នៅក្នុងរបបខ្មែរក្រហម។



ឡឿន សម្បត្តិ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រស់នៅភូមិត្នោតលើ ឃុំបុស្សឫស្សីស្រុក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម

កាលពីកុមារភាព សម្បត្តិ មិនបានចូលរៀនសូត្រនៅសាលាទេ ពីព្រោះតែប្រទេសកំពុងចលាចលដោយសារសង្គ្រាម។ ចាប់ពីឆ្នាំ១៩៧១ ដល់ ឆ្នាំ១៩៧៣ ឪពុកម្តាយរបស់ សម្បត្តិ ត្រូវរត់គៀសខ្លួនពីកន្លែងមួយទៅកន្លែងមួយ គេចចេញពីការវាយប្រយុទ្ធគ្នារវាងទាហានលន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម។ ពីឆ្នាំ១៩៧៤ ដល់ឆ្នាំ១៩៧៥ សភាពការណ៍សង្គ្រាមបានស្ងប់ស្ងៀម ទើបក្រុមគ្រួសាររបស់ សម្បត្តិវិលមករស់នៅក្នុងភូមិកំណើតវិញ។ អំឡុងសង្គ្រាមជិត៥ឆ្នាំ បានបណ្តាលឱ្យក្រុមគ្រួសាររបស់ សម្បត្តិ និងប្រជាជនក្នុងភូមិបាត់បង់សមាជិកគ្រួសារ ខូចខាតផ្ទះសម្បែង និងរស់នៅលំបាកវេទនា ព្រោះមិនអាចចេញទៅប្រកបរបររកស៊ី និងធ្វើស្រែចម្ការ។

នៅពេលដែលកងទ័ពខ្មែរក្រហមឡើងគ្រប់គ្រងប្រទេសទាំងស្រុង ក្រុមគ្រួសាររបស់ សម្បត្តិបន្តរស់នៅក្នុងភូមិដដែល។ បន្ទាប់មក សម្បត្តិឃើញប្រជាជនជម្លៀសមកពីទីក្រុងភ្នំពេញមកសុំស្នាក់នៅក្រោមផ្ទះប្រជាជនក្នុងភូមិដៀស។ គ្រួសារខ្លះបន្តដំណើរទៅភូមិផ្សេងទៀត។ មិនយូរប៉ុន្មានគ្រួសារប្រជាជនថ្មីទាំងអស់ធ្លាក់ខ្លួនឈឺ និងស្លាប់ជាបន្តបន្ទាប់ ដោយសារខ្មែរក្រហមបង្ខំឱ្យធ្វើការងារហួសកម្លាំង និងមិនមានអាហារគ្រប់គ្រាន់។ ប្រជាជនថ្មីដែលនៅសេសសល់ត្រូវបានសន្តិសុខខ្មែរក្រហមចាប់យកទៅសម្លាប់។ តាមឯកសារស្រាវជ្រាវនៃគម្រោងផែនទីវាលពិឃាតរបស់មជ្ឈ-មណ្ឌលឯកសារកម្ពុជា បានបញ្ជាក់អំពីរណ្តៅសាកសពរួម ស្ថិតនៅស្រុកស្រីសន្ធរ មានចំនួន៦ទីតាំង ៖ ១) វត្តជ័យមង្គល (ហៅវត្តជ្រៃ), ២) មន្ទីរសន្តិសុខតាដួង (ស្ថិតនៅវត្តប្រាសាទវដ្តី ហៅវត្តត្បូង), ៣) មន្ទីរសន្តិសុខព្រៃតាបិះ, ៤) វិទ្យាល័យស្រីសន្ធរ, ៥) វត្តព្រែកពោធិមង្គល និង ៦) ទីតាំងសម្លាប់រង្គាលឡាពាង។ ប្រជាជនថ្មីទាំងនោះអាចត្រូវបានសម្លាប់នៅវត្តប្រាសាទវដ្តី ឬហៅវត្ត

ត្បូង ឬវត្តជ័យមង្គល (ហៅវត្តជ្រៃ)។

ក្នុងរបបខ្មែរក្រហម សម្បត្តិ មានអាយុប្រមាណ១០ឆ្នាំ ហេតុនេះ ខ្មែរក្រហមចាត់តាំងឱ្យគាត់ចូលធ្វើការងារនៅកងកុមារ។ ការងាររបស់ សម្បត្តិ គឺត្រូវងើបពីព្រឹកព្រហាម ទៅកើបអាចម៍គោតាមផ្ទះប្រជាជនទីមួយៗ ទុកធ្វើជីដាក់ស្រែ។ បន្ទាប់មក សម្បត្តិ ទៅរៀនបូកលេខ ដកលេខ គុណចែកលេខ និងរៀនអក្សរ នៅក្រោមដើមឈើ ដែលមានគ្រូឈ្មោះ សេង ហាន គឺជាអ្នកបង្រៀន។ សម្បត្តិ រៀនរហូតដល់ម៉ោង១១ព្រឹក ទើបឈប់សម្រាក។ បន្ទាប់ពីហូបអាហារថ្ងៃត្រង់នៅរោងបាយសហករណ៍ហើយ ប្រធានកងចាត់តាំង សម្បត្តិ ឱ្យទៅធ្វើការងារផ្នែកសង្គមកិច្ច។ ការងារសង្គមកិច្ចរបស់អង្គការគឺធ្វើជីសម្រាប់ដាក់ស្រូវ និងកាប់ដីក្រហម។ អង្គការបានកំណត់ផែនការឱ្យ សម្បត្តិ ក្នុងមួយម៉ោង គឺត្រូវធ្វើជីឱ្យបានចំនួន៣០បង្គី។ បន្ទាប់ពីធ្វើជីរួចហើយ សម្បត្តិ ត្រូវទៅកាប់ដី និងលើកយកមកចាក់បំពេញកន្លែងផ្សេងៗ។ ប្រសិនបើធ្វើមិនទាន់គ្រប់ផែនការទេ សម្បត្តិ ត្រូវកាប់ដី និងរែកដីនៅថ្ងៃស្អែកបន្តទៀត។

ការហូបចុកនៅក្នុងរបបខ្មែរក្រហម គឺមិនបានគ្រប់គ្រាន់ឡើយ។ ក្នុងរយៈពេលមួយឆ្នាំ សម្បត្តិ ទទួលបានរបបអាហារហូបឆ្អែតគ្រប់គ្រាន់ចំនួនប្រហែលត្រឹមតែពីរទៅបីថ្ងៃតែប៉ុណ្ណោះ ស្ថិតនៅរដូវច្រូតកាត់។ ដោយសារមិនបានហូបគ្រប់គ្រាន់ សម្បត្តិ ពេលដើរតាមផ្លូវ គាត់បានលួចដកដំឡូងអង្គការ ក៏ត្រូវឈ្លបតាមទាន់។ ខណៈនោះ មេភូមិមិនបានយកទោស ឬធ្វើទារុណកម្មទៅលើគាត់ទេ ពីព្រោះការលួចនេះគឺជាកំហុសលើកទីមួយ។ ទោះបីជាអង្គការមិនយកទោសកំហុសលើ សម្បត្តិ ប៉ុន្តែអង្គការបានយកករណីលួចរបស់ សម្បត្តិ ទៅប្រជុំរួមជាមួយកុមារៗផ្សេងទៀត ដើម្បីជាសារព្រមានកុំឱ្យយកគំរូតាម។

នៅឆ្នាំ១៩៧៧ កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីចូលមកគ្រប់គ្រងភូមិភាគបូព៌ា។ បងស្រី និងបងប្រុសចំនួន៣នាក់ ត្រូវបានអង្គការយកទៅរៀនសូត្រ។ បងស្រីរបស់ សម្បត្តិធ្វើការងារនៅកងឈ្លបនារី បងប្រុសចំនួនពីរគឺម្នាក់ធ្វើជាមេកង និងម្នាក់ទៀតគឺជាគ្រូពេទ្យ។ មុនការចាប់ខ្លួនបងរបស់គាត់យកទៅ កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីបានប្រាប់ សម្បត្តិ និងឪពុកម្ដាយថា ស្នើសុំយកទៅរៀនសូត្រចំនួន៣ថ្ងៃ។ រហូតមកដល់ពេលនេះ សម្បត្តិនៅតែមិនទាន់ឃើញបងប្រុសបងស្រីរបស់ខ្លួនត្រឡប់មកវិញ។ សម្បត្តិ ដឹងថា បងៗរបស់ខ្លួនត្រូវខ្មែរក្រហមមកពីភូមិភាគនិរតីយកទៅសម្លាប់ហើយ។ ឪពុករបស់សម្បត្តិ មានបញ្ហាផ្លូវចិត្តនៅពេលបាត់បង់កូនៗ។

រឿងរ៉ាវដែល សម្បត្តិនៅតែចងចាំ គឺការបាត់បង់បងប្រុសបងស្រីជាមួយ និងពាក្យកុហករបស់ខ្មែរក្រហមថា «យកទៅរៀនសូត្រ»។ សម្បត្តិ ចង់ឱ្យក្មេងៗជំនាន់ក្រោយចងចាំពីទុក្ខលំបាក និង ការឈឺចាប់របស់ប្រជាជនកម្ពុជាក្នុងរបបខ្មែរក្រហម និងមិនចង់ឱ្យរបបខ្មែរក្រហមកើតឡើងម្ដងទៀតទេ។



ចម្ការដំណាំនៅបណ្ដោយដងទន្លេមេគង្គ ក្នុងស្រុកស្រីសន្ធរ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របមុខ៖
ប្រជាជនកម្ពុជាវិលត្រឡប់មកស្រុកកំណើតវិញ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ៖
អដ្ឋិធាតុរបស់ជនរងគ្រោះពីរបបខ្មែរក្រហមនៅខេត្តស្វាយរៀង ត្រូវបានអាជ្ញាធរភូមិឃុំគាស់ដើម្បីរៀបចំ
ធ្វើបុណ្យទៅតាមប្រពៃណីព្រះពុទ្ធសាសនា នៅអំឡុងទសវត្សរ៍ ឆ្នាំ១៩៨០។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




**មជ្ឈមណ្ឌលឯកសារកម្ពុជា៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ៧៨ ៦៩៨ ៣៣៣

DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chatomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 1110

Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 301, January 2025 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.